GENERAL DEPARTMENT OF TAXATION

# ព្រឹត្តិបត្រពន្ធដារ

ត្រីមាសទី៤ ឆ្នាំ២០២៤













លេខ៖ ១២

តុលា - ធ្នូ ២០២៤

# អារម្ភកថា



រាជរដ្ឋាភិបាលថ្មីអាណត្តិទី៧ ដែលមានសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដំបូង នីតិកាលទី៧ នៃរដ្ឋសភា នៅថ្ងៃព្រហស្បតិ៍ ទី២៤ ខែសីហា ឆ្នាំ២០២៣ និងបានប្រកាសដាក់ចេញនូវ "**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**" ដើម្បីជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាសមធម៌ បង្កើនប្រសិទ្ធភាព និងរក្សាចីរភាព សំដៅឆ្លើយតបនឹងបំណងប្រាថ្នាប្រជាជន ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ ជាប្រទេសមានចំណូលខ្ពស់។

ភាគីពាក់ព័ន្ធទាំងស្ថាប័នរដ្ឋ និងវិស័យឯកជននៃរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងគាំទ្រនិងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលថ្មីអាណត្តិទី៧ ដើម្បីសម្រេចបាននូវបំណងប្រាថ្នាទាំងពីរខាងលើ។ ស្របជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានអគ្គនាយកដ្ឋានពន្ធដារជាសេនាធិការ និងមានតួនាទីប្រមូលនិងគ្រប់គ្រងចំណូលពន្ធផ្ទៃក្នុងដែលជាផ្នែកមួយដ៏សំខាន់នៃថវិកាសម្រាប់អភិវឌ្ឍជាតិ ក៏បាននិងកំពុងបន្តប្តេជ្ញាយកចិត្តទុកដាក់លើការកែទម្រង់ទាំងគោលនយោបាយនិងរដ្ឋបាលសារពើពន្ធ ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធ ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការប្រមូលចំណូលពន្ធប្រកបដោយចីរភាព ក្នុងគោលដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។ ជាមួយគ្នានេះ ក្នុងទិសដៅផ្តល់សេវាគ្រប់មធ្យោបាយជូនអ្នកជាប់ពន្ធឱ្យកាន់តែប្រសើរ និងទទួលបានព័ត៌មានត្រឹមត្រូវនិងទាន់ពេលវេលា អគ្គនាយកដ្ឋានពន្ធដារបានរៀបចំបោះពុម្ពព្រឹត្តិបត្រពន្ធដារប្រចាំត្រីមាសចំនួន ១១ លេខ តាំងពីដើមឆ្នាំ២០២២ និងបន្តចងក្រងបោះពុម្ព សម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៤ ទៀត ជាមួយនឹងមាតិកា រួមមាន ព្រឹត្តិការណ៍សំខាន់ៗ, ស្ថានភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ, វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូលនិងមុខងារគាំទ្រ, បច្ចុប្បន្នភាពច្បាប់លិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងគោលនយោបាយសារពើពន្ធ, កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ និងការផ្សព្វផ្សាយនិងបញ្ជ្រាបវប្បធម៌បង់ពន្ធ។

ក្នុងនាមជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ខ្ញុំមានជំនឿថាលោក លោកស្រី សាធារណជន និងស្ថាប័នជាតិ-អន្តរជាតិ នឹងជ្រាបកាន់តែច្បាស់អំពីស្ថានភាពគ្រប់គ្រងការប្រមូលចំណូលពន្ធនិងវឌ្ឍនភាពថ្មីៗ ជាពិសេសកិច្ចខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិនិងទំនើបកម្មរដ្ឋបាលសារពើពន្ធនិងប្រព័ន្ធបច្ចេកវិទ្យាស្របតាមគោលនយោបាយ ទស្សនវិស័យ និងទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ចេញតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៕

ថ្ងៃចន្ទ ១៤ រោច ខែបុស្ស ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

# ព្រឹត្តិបត្រពន្ធដារ

## ត្រីមាសទី៤ ឆ្នាំ២០២៤

## សមាសភាពទទួលបន្ទុកតាក់តែង និពន្ធ និងបោះពុម្ពព្រឹត្តិបត្រពន្ធដារ

| | | |
|---|---|---|
| និពន្ធនាយក | ៖ | ឯកឧត្តម **គង់ វិបុល** |
| គណៈដឹកនាំ | ៖ | លោក **វៀម វឌ្ឍា** និងលោក **កែ ឈុំបញ្ញា** |
| អ្នករៀបរៀងអត្ថបទ | ៖ | លោកស្រី **សេង ច័ន្ទមុន្នី** លោកស្រី **ដេត ពុទ្ធាវី** និងលោក **រិន ណារ៉ូ** |
| អ្នករចនា | ៖ | លោក **លីម សិទ្ធិ** កញ្ញា **ឈៀង សុខឡេង** និងលោក **សារិន ម៉េងហៀង** |
| អ្នកផ្តល់រូបភាព | ៖ | លោក **ឌិត្យ ចំរើនបញ្ញា** លោក **សុន្ទរៈ ត្រដឹម** និងលោក **ឥន្ទ វាសនា** |
| អ្នកស្រាវជ្រាវ | ៖ | លោក **ជុំ សូលីវណ្ណ** លោក **សំរិទ្ធ មករា** លោក **រិទ្ធ តីណា**<br>កញ្ញា **សុធីរ វឌ្ឍនា** លោកស្រី **សាវិន វីនីហ្សា**<br>និងលោក **អាន ចាន់ថាណារិទ្ធ** |
| អ្នកកែសម្រួលអក្ខរាវិរុទ្ធ | ៖ | លោក **អ៊ិន សំបុក** និងលោក **ជា ពិសិដ្ឋ** |
| អ្នកបោះពុម្ព | ៖ | លោក **ស៊ុនលី ជីនី** |
| អ្នកផ្សព្វផ្សាយព័ត៌មាន និងចែកចាយ | ៖ | លោកស្រី **ឌីពៅ ឌិត្យធីយ៉ា** លោកស្រី **ថុង ស្រីពៅ** លោក **មូ សុភ័ក្ត្រ**<br>និងលោក **ឡាង តក្រ្កា** |

# មាតិកា


ព្រឹត្តិការណ៍សំខាន់ៗ.....៦

## ផ្នែកទី១៖ ស្ថានភាពនៃការគ្រប់គ្រងការប្រមូលចំណូលពន្ធ

១. លទ្ធផលការងារប្រមូលចំណូលពន្ធ.....២៧
២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ.....២៧
៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ.....២៨
៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ.....២៩

## ផ្នែកទី២៖ វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រ

១. ការចុះបញ្ជីពន្ធដារ.....៣៣
២. ការផ្តល់សេវាអ្នកជាប់ពន្ធ.....៣៣
៣. ការចាត់ចែងលិខិតប្រកាសពន្ធ.....៣៨
៤. ការធ្វើសវនកម្មពន្ធដារ.....៤០
៥. ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា.....៤០
៦. បច្ចេកវិទ្យាព័ត៌មាន.....៤១

## ផ្នែកទី៣៖ បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ

១. អនុក្រឹត្យ.....៤៩
២. ប្រកាស.....៥០
៣. សេចក្តីជូនដំណឹង.....៥២
៤. សេចក្តីជូនណែនាំ.....៥៤

## ផ្នែកទី៤៖ កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ

១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ.....៥៩
២. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ.....៦៧
៣. កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA).....៧២

## ផ្នែកទី៥៖ ការផ្សព្វផ្សាយ និងបព្វជ្ជាវប្បធម៌បង់ពន្ធ

១. កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ.....៧៦
២. ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ.....៧៨
៣. សិក្ខាសាលាសំខាន់ៗ.....៧៩

## ទស្សនវិស័យ

អគ្គនាយកដ្ឋានពន្ធដារ ជាស្ថាប័នសាធារណៈ
ដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើ
គុណភាពនិងជំនាញ ក្នុងការប្រមូលចំណូលពន្ធក្នុងស្រុក
ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព

## បេសកកម្ម

អគ្គនាយកដ្ឋានពន្ធដារ ពង្រឹងការអនុវត្តច្បាប់
និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងផ្តល់សេវាប្រកបដោយ
ស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងសុចរិតភាព ដើម្បីធានាបាននូវប្រសិទ្ធភាព
នៃការប្រមូលចំណូលពន្ធ និងលើកកម្ពស់អនុលោមភាពដោយស្ម័គ្រចិត្ត

## គុណតម្លៃ

អគ្គនាយកដ្ឋានពន្ធដារបំពេញបេសកកម្ម និង
ធ្វើប្រតិបត្តិការរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវគុណតម្លៃ ដូចខាងក្រោម ៖

| ការអនុវត្ត | វិជ្ជាជីវៈ | ស័ក្តិសិទ្ធិភាព | សុចរិតភាព | ភាពបត់បែន |
|---|---|---|---|---|
| អនុវត្តច្បាប់ គាំទ្រអ្នកជាប់ពន្ធដែលមានអនុលោមភាព តែម៉ឺងម៉ាត់ចំពោះអ្នកជាប់ពន្ធដែលមិនមានអនុលោមភាព | ប្រើប្រាស់ក្រមសីលធម៌វិជ្ជាជីវៈ និងជំនាញ ដើម្បីផ្តល់នូវសេវាដែលមានភាពសាមញ្ញ ងាយស្រួល ឆ្លាតវៃ និងនវានុវត្តន៍ | ប្រើប្រាស់ធនធានដោយសន្សំសំចៃ ទាន់ពេលវេលា និងចំគោលដៅ | ផ្តល់សេវាអ្នកជាប់ពន្ធដោយស្មើភាព តម្លាភាព និងស្អាតស្អំ | ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន |

## គោលបំណង

អគ្គនាយកដ្ឋានពន្ធដារបានកំណត់ចេញនូវគោលបំណងជាយុទ្ធសាស្ត្រសំខាន់ៗ
ចំនួន៣ សម្រាប់ជាត្រីវិស័យក្នុងការតម្រង់ទិសនៃកំណែទម្រង់រដ្ឋបាលសារពើពន្ធ

| គោលបំណងទី១ | គោលបំណងទី២ | គោលបំណងទី៣ |
|---|---|---|
| បង្កើនអនុលោមភាពសារពើពន្ធ តាមរយៈការលើកកម្ពស់គុណភាព ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវា និងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ | បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក | បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ |

# “យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១”

## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព
## កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

### បាវចនា ៥៖

កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និងចីរភាព

### អាទិភាពគន្លឹះ ៥៖

មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យាឌីជីថល

### គោលដៅយុទ្ធសាស្ត្រ ៥៖

១.កំណើនសេដ្ឋកិច្ច ៧% ប្រចាំឆ្នាំ ២.បង្កើនការងារ (បរិមាណ និងគុណភាព) ៣.កាត់បន្ថយភាពក្រីក្រ ៤.ពង្រឹងប្រសិទ្ធភាពការងារ និង៥.ចីរភាពនៃការអភិវឌ្ឍសង្គមជាតិនិងការកសាងភាពធន់

### ស្នូលនៃយុទ្ធសាស្ត្រ ៥៖ អភិបាលកិច្ច

១. ការកែទម្រង់ស្ថាប័ន
២. ការពង្រឹងប្រសិទ្ធភាពការងារ
៣. ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ
៤. ការពង្រឹងប្រសិទ្ធភាពច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង
៥. អភិបាលកិច្ចវិស័យឯកជន

### បរិស្ថានគ្របដណ្តប់ ៥៖

១.ការបន្តពង្រឹងសន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
២.ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យផ្អែកច្បាប់និងឈ្លាសវៃ
៣.ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
៤.ការកសាងភាពជាដៃគូ និង
៥.ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅក្នុងតំបន់ និងសកលលោក

### បញ្ចកោណយុទ្ធសាស្ត្រ ៥៖

**បញ្ចកោណទី១៖** ការអភិវឌ្ឍមូលធនមនុស្ស
**បញ្ចកោណទី២៖** ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង
**បញ្ចកោណទី៣៖** ការអភិវឌ្ឍវិស័យឯកជន និងការងារ
**បញ្ចកោណទី៤៖** ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន
**បញ្ចកោណទី៥៖** ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល

### កម្មវិធីគោលនយោបាយអាទិភាព ៦ សម្រាប់ចាប់ផ្តើមអនុវត្តភ្លាមក្នុងឆ្នាំ២០២៣៖

១.ការពង្រីកសេវាថែទាំសុខភាព ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល ២.ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ៣.ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម សម្រាប់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យនៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និងគ្រាមានអាសន្ន ៤.ការដាក់ចេញយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ (ចូលរួមក្នុងប្រព័ន្ធនិងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ) ៥.ការដាក់ចេញនូវយន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ និង៦.ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស។

### វិធានការគន្លឹះ ៥៖

១.ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ (ពង្រឹងគុណភាព ប្រសិទ្ធភាពនិងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន) ២.ការលើកកម្ពស់គុណភាពអប់រំ (ពង្រឹងគុណភាពសាលារដ្ឋពីថ្នាក់មត្តេយ្យដល់មធ្យមសិក្សា-K12) ៣.ការលើកកម្ពស់គុណភាពសេវាសុខាភិបាល (ពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមនៅមូលដ្ឋាន) ៤.ការពង្រឹងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព (កាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀននៅក្នុងសហគមន៍) និង៥.ការពង្រឹងនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។

# ព្រឹត្តិការណ៍សំខាន់ៗ



ការលើកទឹកចិត្តនិងអនុគ្រោះពន្ធដារ

សូមអានពិស្តារនៅទំព័រទី ៨



កម្ពុជា-ឡាវ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង DTA នៅចំពោះមុខប្រមុខដឹកនាំរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ

សូមអានពិស្តារនៅទំព័រទី ១២



**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** វាយតម្លៃខ្ពស់ចំពោះក្រុមការងារអគ្គនាយកដ្ឋានពន្ធដារ ដែលបានធ្វើកិច្ចសហការល្អជាមួយវិស័យឯកជន ក្នុងការដោះស្រាយបញ្ហាប្រឈមនានា

សូមអានពិស្តារនៅទំព័រទី ១៤



អគ្គនាយកដ្ឋានពន្ធដារ ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ លើកទី៥៣ របស់ក្រុមសិក្សាស្តីពីរដ្ឋបាលសារពើពន្ធ អាស៊ីប៉ាស៊ីហ្វិកនិងការស្រាវជ្រាវ (SGATAR)

សូមអានពិស្តារនៅទំព័រទី ១៥



វេទិកាពន្ធដារ ២០២៤ សហការរៀបចំដោយ សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC)

សូមអានពិស្តារនៅទំព័រទី ១៨




កម្មវិធីប្រគល់វិញ្ញាបនបត្រភ្នាក់ងារសេវាកម្មពន្ធដារ ជំនាន់ទី១៣ ដល់ទី១៤ និងវិញ្ញាបនបត្រជំនាញ វិជ្ជាជីវៈពន្ធដារជំនាន់ទី១៥

សូមអានពិស្តារនៅទំព័រទី ២២

# ការលើកទឹកចិត្តនិងអនុគ្រោះពន្ធដារ



## ១.ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្តអនុវត្តវិធានការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍ នៅខេត្តសៀមរាប និងការកែតម្រូវលិខិតប្រកាសពន្ធ រហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៥

ក្នុងគោលបំណងផ្តល់ការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាប ស្របតាមវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដើម្បីជួយស្តារវិស័យទេសចរណ៍ឱ្យវិលទៅរកភាពល្អប្រសើរឡើងវិញ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញប្រកាសលេខ ៦២៦ សហវ.ប្រក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ ដោយផ្តល់ការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនទេសចរណ៍ ដែលបានចុះបញ្ជីពន្ធដារ និងមានសកម្មភាពអាជីវកម្មនៅខេត្តសៀមរាប ដូចខាងក្រោម៖

១. លើកលែងការបង់ពន្ធអាករប្រចាំខែគ្រប់ប្រភេទ វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករលើការស្នាក់នៅ គិតចាប់ពីខែកក្កដា ឆ្នាំ២០២៤ រហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៥។

២. លើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២៤។ ចំពោះប្រាក់រំដោះពន្ធលើប្រាក់ចំណូល ដែលសហគ្រាសបានបង់រួច នឹងត្រូវអនុញ្ញាតជាឥណទានពន្ធសម្រាប់កាត់កងជាមួយពន្ធលើប្រាក់ចំណូលឆ្នាំ២០២៥។

៣. មិនទទួលរងការធ្វើសវនកម្មពន្ធដារ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៤។

ជាមួយគ្នានេះ ក្នុងគោលបំណងផ្តល់ពេលវេលាបន្ថែមដល់សហគ្រាសដែលមានបំណងស្នើសុំកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានចេញប្រកាសលេខ ៦២៥ សហវ.ប្រក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ ដើម្បីផ្តល់ការលើកទឹកចិត្តដល់អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដែលស្នើសុំធ្វើការកែតម្រូវបញ្ជីគណនេយ្យ និងលិខិតប្រកាសពន្ធឡើងវិញដោយស្ម័គ្រចិត្ត តាមរយៈការលើកលែងទណ្ឌកម្មរដ្ឋបាល រួមមាន ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ទាំងស្រុង រហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៥ ដូចខាងក្រោម៖

១. ចំពោះការស្នើសុំកែតម្រូវបញ្ជីគណនេយ្យ និងលិខិតប្រកាសពន្ធឡើងវិញលើប្រតិបត្តិការដែលកើតឡើងមុនការិយបរិច្ឆេទខែសីហា ឆ្នាំ២០២៤ តែប៉ុណ្ណោះ។ ដោយឡែកការស្នើសុំកែតម្រូវលិខិតប្រកាសពន្ធលើប្រតិបត្តិការដែលកើតឡើងចាប់ពីខែសីហា ឆ្នាំ២០២៤ តទៅ មិនត្រូវទទួលបានការលើកលែងទណ្ឌកម្មរដ្ឋបាលនេះឡើយ។

២. ចំពោះការស្នើសុំកែតម្រូវបញ្ជីគណនេយ្យ និងលិខិតប្រកាសពន្ធឡើងវិញក្នុងអំឡុងពេលរងសវនកម្មពន្ធដារដែលការកែតម្រូវនោះ បានធ្វើឡើងមុនពេលសវនករពន្ធដាររកឃើញកំហុសរបស់អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកតែប៉ុណ្ណោះ (ក្នុងករណីសវនករពន្ធដារមិនទាន់បានបង្ហាញ និងគ្មានកំណត់ហេតុបញ្ជាក់ពីលទ្ធផលសវនកម្ម)៕

## ២.ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវបានព្យួរការអនុវត្តដល់ដំណាច់ឆ្នាំ២០២៤ ខណៈចាប់ពីឆ្នាំ២០២៥ តទៅ ការអនុវត្តត្រូវបានភ្ជាប់ជាមួយលក្ខខណ្ឌបន្ធូរបន្ថយ និងលើកលែងជាច្រើន

យោងតាមសេចក្តីជូនដំណឹងលេខ ០១៤ សហវ.ស.ជ.ណ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបន្ត និងបន្ថែមការលើកទឹកចិត្តពន្ធដារចំពោះវិស័យអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបានព្យួរការអនុវត្តរហូតដល់ដំណាច់ឆ្នាំ២០២៤ មានន័យថាកម្មសិទ្ធិករ ឬអ្នកកាន់កាប់ ឬអ្នកទទួលប្រយោជន៍ចុងក្រោយ ពុំមានកាតព្វកិច្ចប្រកាសបង់ពន្ធរហូតដល់ដំណាច់ឆ្នាំ២០២៤។ សម្រាប់ការអនុវត្តចាប់ពីឆ្នាំ២០២៥ តទៅ ត្រូវបានបន្ធូរបន្ថយលក្ខខណ្ឌលើកលែងពន្ធនេះដូចខាងក្រោម៖

ក. ដីដែលជាកម្មវត្ថុនៃពន្ធលើដីធ្លីមិនបានប្រើប្រាស់ សំដៅដល់ដីដែលនៅក្រៅតំបន់ជាប់ពន្ធលើអចលនទ្រព្យ។

ខ. ដីដែលជាកម្មវត្ថុនៃពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញ ៥ហិកតា ក្នុងដីមួយកន្លែង។

គ. ចំពោះដីដែលលើសពី ៥ហិកតា គឺអាចរួចពន្ធលើដីធ្លីមិនបានប្រើប្រាស់ ស្របតាមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

- ដីកសិកម្មកំពុងបង្កបង្កើនផលដោយមានការបញ្ជាក់ពីគណៈកម្មការ ឬអនុគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ដីកំពុងបម្រើសកម្មភាពសេដ្ឋកិច្ចរបស់រូបវន្តបុគ្គលឬនីតិបុគ្គល ដែលបានចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ
- ដីមានសំណង់ ឬគ្មានសំណង់ស្ថិតក្រោមកិច្ចសន្យាជួល
- ដីដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល
- ដីសម្បទានសេដ្ឋកិច្ចដែលជួលពីរដ្ឋ, ដីធ្លីរបស់សហគមន៍
- ដីជាកម្មសិទ្ធិរបស់រដ្ឋ ដែលបានជួលទៅឱ្យនីតិបុគ្គល ឬរូបវន្តបុគ្គលណាមួយ សម្រាប់ប្រើប្រាស់ជាសកម្មភាពសេដ្ឋកិច្ចផ្សេងៗតាមកិច្ចសន្យា ឬកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ
- ដីដែលស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបម្រើផ្ទាល់ដល់សកម្មភាពកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម
- ដីដែលត្រូវបានចុះបញ្ជីជាទ្រព្យសម្បត្តិរបស់សហគ្រាសក្នុងវិស័យអប់រំ សិក្សាធិការ និងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់គោលដៅបម្រើការងារក្នុងវិស័យដូចបានរៀបរាប់ខាងដើម។ ក្នុងករណីដែលដីនេះត្រូវបានលក់ឬមិនត្រូវបានប្រើប្រាស់តាមគោលដៅខាងលើត្រូវបំពេញកាតព្វកិច្ចពន្ធដារតាមច្បាប់ជាធរមាន។

គួរបញ្ជាក់ផងដែរថា រាល់ការលើកលែង ការអនុគ្រោះ និងការព្យួរការអនុវត្តខាងលើនេះ ពុំមានអានុភាពប្រតិសកម្មចំពោះប្រាក់ពន្ធ រួមទាំងទណ្ឌកម្មរដ្ឋបាល (ពន្ធបន្ថែម និងការប្រាក់) ដែលបានបង់រួចហើយនោះទេ៕

## ៣. សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាពមួយចំនួនដែលចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ

ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធចំពោះសហគ្រាសក្នុងវិស័យអាទិភាពមួយចំនួន រាជរដ្ឋាភិបាលកម្ពុជាសម្រេចផ្ដល់ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសធុនតូច និងមធ្យម ដែលចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត និងប្រកបអាជីវកម្មដូចជា ១.លក់ដុំ លក់រាយ និងជួសជុល ២.សេវាកម្មស្នាក់នៅនិងអាហារ ៣.សិប្បកម្ម និង ៤.សហគមន៍កសិកម្ម។ នេះបើយោងតាមអនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលការលើកទឹកចិត្តផ្នែកពន្ធដារទាំងនោះមានដូចខាងក្រោម៖

១. ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០២៤-២០២៨ សម្រាប់សហគ្រាសធុនតូច ត្រូវបានលើកលែងពិន័យទោសទណ្ឌ និងបំណុលពន្ធចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជី លើកលែងកម្រៃសេវាចុះបញ្ជីពន្ធដារនិងកម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មាន និងលើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមាសម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជី។

២. ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០២៤-២០២៥ សម្រាប់សហគ្រាសធុនមធ្យម ត្រូវបានលើកលែងពិន័យទោសទណ្ឌ និងបំណុលពន្ធចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជី និងលើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា សម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជី។

៣. ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០២៤-២០២៥ សម្រាប់សហគ្រាសធុនតូច និងមធ្យម ត្រូវបានលើកលែងការបង់ពន្ធប៉ាតង់ សម្រាប់រយៈពេល ២ឆ្នាំ បន្ទាប់ពីទទួលបានការសម្រេចឱ្យចុះបញ្ជី។

អនុក្រឹត្យនេះក៏បានបញ្ជាក់ផងដែរថា សហគ្រាសធុនតូច និងមធ្យម ដែលទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ត្រូវកាន់បញ្ជិកាគណនេយ្យ និងដាក់លិខិតប្រកាសសារពើពន្ធតាមការកំណត់ជូនរដ្ឋបាលសារពើពន្ធស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារជាធរមាន៕



## ៤.គម្រោងវិនិយោគជាង ២០០ គម្រោង នៅខេត្តព្រះសីហនុ ទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ក្នុងក្របខ័ណ្ឌកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៤

ខេត្តព្រះសីហនុត្រូវបានរាជរដ្ឋាភិបាលកម្ពុជា កំណត់អាទិភាពក្នុងការពន្លឿនការអភិវឌ្ឍខេត្តនេះឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង និងជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចសម្រាប់កម្ពុជា។ ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ដោយផ្តល់ការលើកទឹកចិត្ត ការអនុគ្រោះ និងការសម្រួលនីតិវិធីនានា រួមទាំងការលើកទឹកចិត្តផ្នែកពន្ធដារផងដែរ។ តាមរយៈវិធានការដែលដាក់ឱ្យអនុវត្តនៅក្នុងកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុនេះ គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច ៤ប្រភេទ រួមមាន៖ ទី១.គម្រោងវិនិយោគពាក់ព័ន្ធនឹងអគារកំពុងជាប់គាំង ទី២.គម្រោងវិនិយោគដែលអាចចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ ២០២៤ ទី៣.ការពង្រីកគម្រោងដែលមានស្រាប់ និងទី៤.គម្រោងវិនិយោគ/ធុរកិច្ចដែលមានស្រាប់ នឹងទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ដែលក្នុងនោះរួមមានការលើកលែងនូវប្រភេទពន្ធអាករសំខាន់ៗមួយចំនួន ការលើកលែងកម្រៃសេវាចុះបញ្ជី ការសម្រួលនីតិវិធីបង់ពន្ធជាកញ្ចប់តាមដំណាក់កាល ការលើកលែងទណ្ឌកម្មរដ្ឋបាលចំពោះការធ្វើសវនកម្មពន្ធដារ ព្រមទាំងការផ្តល់ការលើកទឹកចិត្តដោយពន្ធអាករជាបន្ទុករបស់រដ្ឋលើការផលិត និង/ឬការផ្សព្វផ្សាយអំពីផលិតផលទេសចរណ៍គោលដៅទេសចរណ៍ក្នុងខេត្តព្រះសីហនុ។

គួរបញ្ជាក់ផងដែរថា ក្នុងកិច្ចប្រជុំលើកទី១២ របស់ក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ដើម្បីពិនិត្យគម្រោងវិនិយោគ និងធុរកិច្ច ដែលបានស្នើការលើកទឹកចិត្ត ការអនុគ្រោះ និងការសម្រួលនីតិវិធី ក្នុងក្របខ័ណ្ឌ **"កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ២០២៤"** បានសម្រេចជាគោលការណ៍ផ្តល់ការលើកទឹកចិត្តពិសេស ដល់គម្រោងចំនួន **៤៨ គម្រោង** ក្នុងនោះ គម្រោងពាក់ព័ន្ធនឹងអគារជាប់គាំង ចំនួន **១៦ គម្រោងថ្មី** ចំនួន **២៨** និងការពង្រីកគម្រោង ចំនួន **៤** ដែលមានទុនវិនិយោគសរុប **៤៨៧ លានដុល្លារ**។ តាមរយៈលទ្ធផលនៃកិច្ចប្រជុំនេះផងដែរ បើគិតត្រឹមខែធ្នូ ឆ្នាំ២០២៤ នេះ គម្រោងវិនិយោគនៅខេត្តព្រះសីហនុចំនួន **២១៣ គម្រោង** ទទួលបានការលើកទឹកចិត្តពិសេស ដែលក្នុងនោះរួមមាន គម្រោងពាក់ព័ន្ធនឹងអគារជាប់គាំងមានចំនួន **១០១ គម្រោងថ្មី** មានចំនួន **៨៩** ការពង្រីកគម្រោងមានចំនួន **១៩** និងគម្រោងមានស្រាប់មានចំនួន **៤**។



បញ្ហពិគ្រោះយោបល់ផ្នែកពន្ធដារ




លោកអ្នកអាចអញ្ជើញមកកាន់បញ្ជរពិគ្រោះយោបល់ផ្នែកពន្ធដារនៃសាខាពន្ធដារខេត្តព្រះសីហនុ

(ទីតាំងសាខាពន្ធដារខេត្តព្រះសីហនុ)

សូមស្កេន ដើម្បីទស្សនាវីដេអូការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់ខេត្តព្រះសីហនុ

# កម្ពុជា-ឡាវ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង DTA នៅចំពោះមុខប្រមុខដឹកនាំរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ




*ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) កម្ពុជា-ឡាវ*

កាលពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) កម្ពុជា-ឡាវ ត្រូវបានចុះហត្ថលេខា ដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម SANTIPHAB PHOMVIHANE រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ក្នុងនាមរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**ឯកឧត្តមបណ្ឌិត** SONEXAY SIPHANDONE នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ។ កិច្ចព្រមព្រៀង DTA កម្ពុជា-ឡាវ នេះ ជាកិច្ចព្រមព្រៀង DTA ទី១២ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាជាមួយយុត្តាធិការដៃគូ និងជាសមិទ្ធផលថ្មីមួយទៀតក្នុងចំណោមសមិទ្ធផលសំខាន់ៗជាច្រើន ដែលរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិត និងភាពប៉ិនប្រសប់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សម្រេចបាន។ ទន្ទឹមនឹងនេះ កម្ពុជា បាននិងកំពុងធ្វើការចរចាលើកិច្ចព្រមព្រៀងនេះ ជាមួយបណ្តាយុត្តាធិការដៃគូមួយចំនួនទៀត ដូចជា ជប៉ុន មីយ៉ាន់ម៉ា ម៉ារ៉ុក អេមីរ៉ាតអារ៉ាប់រួម បារាំង និងកាតា ជាដើម។

កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) មិនគ្រាន់តែបង្កើតឡើងដើម្បីលុបបំបាត់ការយកពន្ធត្រួតគ្នានោះទេ ដែលកិច្ចព្រមព្រៀងនេះ ក៏បានចូលរួមចំណែកក្នុងការធ្វើឱ្យកើនឡើងនូវការវិនិយោគផ្ទាល់ពីបរទេសនិងបង្កើនភាពប្រកួតប្រជែងអន្តរជាតិ ព្រមទាំងផ្តល់ទំនុកចិត្ត និងភាពប្រាកដប្រជាដល់វិនិយោគិនបរទេសតាមរយៈការផ្តល់វិធានច្បាស់លាស់ក្នុងការកំណត់សិទ្ធិយកពន្ធរវាងភាគីនៃកិច្ចព្រមព្រៀង, ការលើកលែង ឬបន្ធូរបន្ថយលើការអនុវត្តចំពោះប្រភេទពន្ធមួយចំនួន, លុបបំបាត់ការរើសអើងពន្ធ, ផ្តល់យន្តការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ និងដោះស្រាយបញ្ហាការគេចវេះពន្ធនិងការបន្ថយមូលដ្ឋានពន្ធ តាមរយៈការផ្លាស់ប្តូរព័ត៌មានរវាងភាគីនៃកិច្ចព្រមព្រៀង។

រហូតមកទល់ពេលនេះ កម្ពុជាមានកិច្ចព្រមព្រៀង DTA ចំនួន **១១** បានចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្ត ដូចខាងក្រោម៖

- សាធារណរដ្ឋសិង្ហបុរី (មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨)
- សាធារណរដ្ឋប្រជាមានិតចិន (មានប្រសិទ្ធភាពអនុវត្តនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩)
- ព្រះរាជាណាចក្រថៃ (មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨)
- ព្រុយណេដារូសាឡាម (មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩)
- សាធារណរដ្ឋសង្គមនិយមវៀតណាម (មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០)
- សាធារណរដ្ឋឥណ្ឌូណេស៊ី (មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១)
- តំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន (មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០)
- ម៉ាឡេស៊ី (មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២១)
- សាធារណរដ្ឋកូរ៉េ (មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២)
- តំបន់រដ្ឋបាលពិសេសម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន (មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤)
- សាធារណរដ្ឋតួកគី (មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤)៕



*សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត***
*នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*



*ឯកឧត្តមបណ្ឌិត **SONEXAY SIPHANDONE***
*នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ*




*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **SANTIPHAB PHOMVIHANE** រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ក្នុងនាមរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ*

# ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ វាយតម្លៃខ្ពស់ ចំពោះក្រុមការងារអគ្គនាយកដ្ឋានពន្ធដារ ដែលបានធ្វើកិច្ចសហការល្អ ជាមួយវិស័យឯកជនក្នុងការដោះស្រាយបញ្ហាប្រឈមនានា



*អង្គប្រជុំក្រុមការងារ "ឃ" ផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច រវាងរាជរដ្ឋាភិបាលជាមួយវិស័យឯកជន*

យោងតាមសេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីអង្គប្រជុំក្រុមការងារ "ឃ" ផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច រវាងរាជរដ្ឋាភិបាលជាមួយវិស័យឯកជន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានវាយតម្លៃខ្ពស់ចំពោះក្រុមការងារអគ្គនាយកដ្ឋានពន្ធដារ ដែលកន្លងមកបានធ្វើកិច្ចសហការល្អក្នុងការដោះស្រាយបញ្ហាប្រឈម សំណូមពរ និងក្តីកង្វល់ពាក់ព័ន្ធនឹងការធ្វើធុរកិច្ច ព្រមទាំងអនុញ្ញាតឱ្យមានការពិភាក្សាដោយបើកចំហជាមួយវិស័យឯកជន។

កិច្ចប្រជុំក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច "ក្រុម ឃ" ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិនិត្យពិភាក្សាលើបញ្ហាប្រឈម និងសំណូមពរនានា ដើម្បីដាក់ចេញវិធានការដោះស្រាយសមស្របជូនវិស័យឯកជនដែលកំពុងធ្វើធុរកិច្ចនៅប្រទេសកម្ពុជា។ កិច្ចប្រជុំនេះ មានរបៀបវារៈចំនួន ៣ គឺ ទី១.ការស្នើសុំកិច្ចអន្តរាគមន៍បន្ទាន់ពីរាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចនៅកម្ពុជា ទី២.ពន្ធលើការនាំចេញនៃការប្រមូលរ៉ែទង់ដែង និងទី៣.អត្រាការប្រាក់ចំពោះការកំណត់ពន្ធឡើងវិញ។

គួរបញ្ជាក់ផងដែរថា ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ក៏ដូចថ្នាក់ដឹកនាំ និងអង្គភាពក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ តែងតែផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការគាំទ្រដល់ការបំពេញកាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធ។

ការរៀបចំឱ្យមានវេទិកាពន្ធដារ សិក្ខាសាលា ការបណ្តុះបណ្តាលផ្សេងៗ ព្រមទាំងកិច្ចប្រជុំជាមួយវិស័យឯកជន អង្គការសមាគម បានផ្តល់ឱកាសដល់អ្នកជាប់ពន្ធលើកឡើងពីបញ្ហាប្រឈមដែលបានជួបប្រទះក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធដែលជាមូលដ្ឋានសម្រាប់អគ្គនាយកដ្ឋានពន្ធដារ ដាក់ចេញនូវវិធានការនានា ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា៕

# អគ្គនាយកដ្ឋានពន្ធដារ ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី ៥៣ របស់ក្រុមសិក្សាស្តីពីរដ្ឋបាលសារពើពន្ធអាស៊ីប៉ាស៊ីហ្វិក និងការស្រាវជ្រាវ ( SGATAR )



ចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ តបតាមការអញ្ជើញរបស់រដ្ឋបាលសារពើពន្ធនៃសាធារណរដ្ឋកូរ៉េ ( National Tax Services ) ក្នុងនាមជាប្រធានផ្លាស់វេន នៃរដ្ឋបាលសារពើពន្ធអាស៊ីប៉ាស៊ីហ្វិកនិងការស្រាវជ្រាវ ( Study Group on Asia-Pacific Tax Administration and Research - SGATAR ) ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អមដោយ ឯកឧត្តម **អ៊ុំ សីហា** អគ្គនាយករង លោក **លឹម ជីលុច** អគ្គនាយករង លោក **លឹម ហ៊ុយជីវ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោក **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ លោក **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ និងលោក **ស្រ៊ុន អង្គរ៉េន** ប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីជំនាញពាក់ព័ន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី៥៣ នៃក្រុមសិក្សាស្តីពីរដ្ឋបាលសារពើពន្ធអាស៊ីប៉ាស៊ីហ្វិក និងការស្រាវជ្រាវ ( Study Group on Asia-Pacific Tax Administration and Research - SGATAR )។

កិច្ចប្រជុំ SGATAR ប្រចាំឆ្នាំលើកទី៥៣ បានប្រព្រឹត្តទៅនិងប្រកាសបើកកម្មវិធីជាផ្លូវការក្រោមអធិបតីភាព ឯកឧត្តម Song Eon Seok ប្រធានគណៈកម្មាធិការយុទ្ធសាស្ត្រនិងហិរញ្ញវត្ថុ នៃរដ្ឋសភាជាតិនៃសាធារណរដ្ឋកូរ៉េ និងឯកឧត្តម Kang Minsu អគ្គនាយកនៃរដ្ឋបាលសារពើពន្ធសាធារណរដ្ឋកូរ៉េ ដែលជាប្រធានផ្លាស់វេននៃកិច្ចប្រជុំ SGATAR លើកទី ៥៣ ដោយមានវត្តមានអ្នកចូលរួមសរុបចំនួន **១៦៦ រូប** ក្នុងនោះមាន ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយករង និងមន្ត្រីពាក់ព័ន្ធនៃរដ្ឋបាលសារពើពន្ធជាសមាជិក SGATAR ចំនួន **១៨ ប្រទេស** រួមមានរដ្ឋបាលសារពើពន្ធនៃសាធារណរដ្ឋកូរ៉េ អូស្ត្រាលី កម្ពុជា ចិន ហុងកុង ឥណ្ឌូនេស៊ី ជប៉ុន ឡាវ ម៉ាកាវ ម៉ាឡេស៊ី ម៉ុងហ្គោលី ណូវ៉ែលសេឡង់ ប៉ាពួញូហ្គីណេ ហ្វីលីពីន សឹង្ហបុរី តៃវ៉ាន់ ថៃ និងវៀតណាម ព្រមទាំងសមាជិកអង្កេតការនិងវាគ្មិនសំខាន់ៗមកពីស្ថាប័នអន្តរជាតិចំនួន **១០** រួមមាន Asia Initiative, ធនាគារអភិវឌ្ឍន៍អាស៊ី ( ADB ), Asia Oceania Tax Consultants Association ( AOTCA ), Belt and Road Initiative Tax Administration Cooperation

Mechanism (BRITACOM), Inter-American Center of Tax Administration (CIAT), Global Forum, International Bureau of Fiscal Documentation (IBFD), Organization for Economic Cooperation and Development (OECD), មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងធនាគារពិភពលោក (World Bank)។

ក្នុងកិច្ចប្រជុំនេះ បានរៀបចំបែងចែកជា ២ កម្រិត គឺ កម្រិតប្រធានគណៈប្រតិភូ (Head of Delegates) និងកម្រិតក្រុមការងារបច្ចេកទេស (Working Group)។

ក្នុងកិច្ចប្រជុំកម្រិតប្រធានគណៈប្រតិភូ (Head of Delegates) បានប្រជុំនិងវាយតម្លៃលើការអនុវត្តផែនការសកម្មភាពការងារ ដោយបានដាក់ចេញកាលពីកិច្ចប្រជុំ SGATAR លើកទី៥២ នៅព្រះរាជាណាចក្រថៃ នាឆ្នាំកន្លងមក ហើយកិច្ចប្រជុំបានបន្តជជែកពិភាក្សាផ្លាស់ប្តូរយោបល់ មេរៀន បទពិសោធ ការអនុវត្តល្អៗ និងបញ្ហាប្រឈមនានា លើប្រធានបទសំខាន់ៗចំនួន ៣ រួមមាន៖ ទី១.យន្តការប្រកបដោយប្រសិទ្ធភាពសម្រាប់ការបង្ការ និងដោះស្រាយវិវាទពន្ធដារ (Effective mechanism for dispute prevention and resolution), ទី២.បរិវត្តកម្មឌីជីថលនៃរដ្ឋបាលសារពើពន្ធ (Digital transformation of tax administration) និងទី៣.ការងារកែទម្រង់រដ្ឋបាលសារពើពន្ធ (Tax reform updates across jurisdictions)។ ក្នុងឱកាសនោះដែរ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានចូលរួមធ្វើជាវាគ្មិននៅកម្រិតប្រធានគណៈប្រតិភូ និងធ្វើបទបង្ហាញអំពី"ការងារកែទម្រង់រដ្ឋបាលសារពើពន្ធ" ដោយឯកឧត្តមបានចែករំលែកនូវមេរៀន បទពិសោធ និងដំណើរវិវត្តន៍នៃការកែទម្រង់ពន្ធដារកម្ពុជា ទាំងទិដ្ឋភាពគោលនយោបាយបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធកម្ពុជា ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ដែលជំរុញឱ្យរដ្ឋបាលសារពើពន្ធកម្ពុជាអាចដើរទាន់សភាពការណ៍និងនិន្នាការនៃរដ្ឋបាលសារពើពន្ធក្នុងតំបន់ និងអន្តរជាតិផងដែរ។ ឯកឧត្តម ក៏បានគូសបញ្ជាក់ថា អភិបាលកិច្ចល្អ (Good Governance) គឺជាគោលការណ៍ស្នូលនៃកំណែទម្រង់និងទំនើបភាវូបនីយកម្ម និងឌីជីថលូបនីយកម្ម នៃអគ្គនាយកដ្ឋានពន្ធដារ ឈានទៅបង្កើតប្រព័ន្ធពន្ធដាររឹងមាំ ដើម្បីបង្កភាពងាយស្រួលដល់អ្នកជាប់ពន្ធ ក្នុងការបង់ពន្ធប៉ុន្តែពិបាកក្នុងការគេចពន្ធ។

ដោយឡែក សម្រាប់កម្រិតក្រុមការងារបច្ចេកទេស (Working Group) មានបែងចែកជា ៣ ក្រុម ក្នុងនោះ ក្រុមការងារទី១.ការផ្ទេរថ្លៃនៃប្រតិបត្តិការហិរញ្ញវត្ថុ (Transfer Pricing of Financial Transactions), ក្រុមការងារទី២.ការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃទិន្នន័យស្តង់ដាររបាយការណ៍រួមក្នុងគោលដៅផ្លាស់ប្តូរព័ត៌មាន (Improving the Quality of Common Reporting Standard Data) និងក្រុមការងារទី៣.ការប្រយុទ្ធប្រឆាំងការគេចវេះពន្ធ និងបទល្មើសពន្ធដារ (Combating Tax Evasion and Tax Crimes)។

ជារួម បន្ទាប់ពីកិច្ចប្រជុំពិភាក្សានិងផ្លាស់ប្តូរយោបល់យ៉ាងមមាញឹក និងក្នុងស្មារតីកិច្ចសហប្រតិបត្តិការខ្ពស់ សម្រាប់កិច្ចប្រជុំប្រចាំឆ្នាំលើកទី៥៣ របស់ SGATAR ក្រុមការងារប្រធានគណៈប្រតិភូ (Head of Delegate) បានបូកសរុបលទ្ធផលការងារសំខាន់ៗ និងដាក់ចេញនូវវិធានការអនុវត្តបន្ត ដូចខាងក្រោម៖

- កិច្ចប្រជុំប្រចាំឆ្នាំលើកទី៥៣ បានបញ្ចប់ដោយជោគជ័យ ដែលទទួលធ្វើជាម្ចាស់ផ្ទះរៀបចំដោយរដ្ឋបាលសារពើពន្ធនៃសាធារណរដ្ឋកូរ៉េ
- សម្រាប់ឆ្នាំ២០២៥ និងធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំប្រចាំឆ្នាំលើកទី៥៤ របស់ SGATAR ឆ្នាំ២០២៥ ដែលគ្រោងនឹងរៀបចំឡើងនៅទីក្រុង Brisbane រដ្ឋ Queensland ប្រទេសអូស្ត្រាលី
- ការអនុម័តលើរបាយការណ៍ស្តីពីការអនុវត្តផែនការកសាងសមត្ថភាពសម្រាប់ឆ្នាំ២០២៤ សម្រេចបាន **៩ លើក** តាមរយៈកិច្ចសហការបណ្តុះបណ្តាលជាមួយស្ថាប័នអន្តរជាតិ ក្នុងគោលដៅចែករំលែកជំនាញ និងមេរៀនបទពិសោធជូនដល់រដ្ឋបាលសារពើពន្ធជាសមាជិក
- បានពិនិត្យនិងឯកភាពឱ្យអនុវត្តនូវផែនការកសាងសមត្ថភាពសម្រាប់ឆ្នាំ២០២៥ ដែលគ្រោងនឹងរៀបចំកម្មវិធី

បណ្តុះបណ្តាលសរុបចំនួន **១១ លើក** បន្តទៀត

- បានពិនិត្យនិងឯកភាពលើរបាយការណ៍នៃលទ្ធផលដែលសម្រេចបានក្នុងឆ្នាំកន្លងមក (២០២៣-២០២៤) របស់ក្រុមការងារ SGATAR Taskforce បានគាំទ្រឱ្យក្រុមការងារ SGATAR Taskforce ពិនិត្យលើការត្រៀមបង្កើតនូវវេទិកា SGATAR Competent Authority Forum មួយ ព្រមទាំងតាមដាននិងពិចារណាបន្ថែមទៀតការរៀបចំកិច្ចប្រជុំកម្រិតអ្នកជំនាញផ្នែកព័ត៌មានវិទ្យា (IT Experts) ដើម្បីពិភាក្សាអំពីបញ្ហាប្រឈមនានាពេលអនាគត បានអនុម័តលើរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសទាំង **៣ ក្រុម** (3 Working Groups)។

ក្នុងដំណើរបេសកកម្មរបស់គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារដឹកនាំដោយឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានបញ្ចប់ប្រកបដោយលទ្ធផលផ្លែផ្កាជាមួយនឹងការទទួលបានជាគំនិតច្នៃប្រឌិតថ្មីៗ បទពិសោធ និងឧត្តមានុវត្តន៍ សំខាន់ៗសម្រាប់ធ្វើជាមូលដ្ឋានក្នុងការសិក្សា ឈ្វេងយល់ និងបង្កើនសមត្ថភាពរដ្ឋបាលសារពើពន្ធឱ្យកាន់តែប្រសើរឡើង៕
















# វេទិកាពន្ធដារ ២០២៤ សហការរៀបចំដោយសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC)




នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៤ ខែតុលា ឆ្នាំ២០២៤ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា មានរៀបចំនូវវេទិកាពន្ធដារ ២០២៤ (Tax Forum 2024) ដែលសហការរៀបចំដោយអគ្គនាយកដ្ឋានពន្ធដារ និងសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងលោក Enjoy Ho អនុប្រធានសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC) ដោយមានការចូលរួមពីលោកអគ្គនាយករង ថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានចូលរួមរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកានៃ TAFTAC ដែលជាម្ចាស់សហគ្រាស និងអ្នកតំណាងសហគ្រាស ប្រមាណ **៥០០ រូប**។

ជាកិច្ចចាប់ផ្តើម លោក Enjoy Ho បានមានមតិស្វាគមន៍និងថ្លែងអំណរគុណចំពោះឯកឧត្តម **គង់ វិបុល** និងថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ ដែលតែងតែផ្តល់ការយកចិត្តទុកដាក់គាំទ្រ និងផ្តល់កិច្ចសហប្រតិបត្តិការល្អដល់វិស័យឯកជនតាមរយៈការចូលរួមក្នុងវេទិកាពន្ធដារនានា។ វេទិកាថ្ងៃនេះ មានការចូលរួមភាគច្រើនពីសំណាក់រោងចក្រ ដែលជាសមាជិក TAFTAC និងមួយចំនួនទៀតពីក្រុមហ៊ុនឯកជនផ្សេងៗ ដែលការចូលរួមនេះ គឺបង្ហាញពីសារៈសំខាន់នៃប្រធានបទពន្ធដារក្នុងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុននីមួយៗ។ លោកបានលើកឡើងទៀតថា វេទិកានេះ គឺជាឱកាសដ៏មានតម្លៃសម្រាប់អ្នកចូលរួមក្នុងការទទួលបាននូវចំណេះដឹង បទពិសោធ និងវឌ្ឍនភាពថ្មីៗពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធនៅកម្ពុជា ការលើកទឹកចិត្តផ្នែកពន្ធដារ ក៏ដូចជាទិដ្ឋភាពនានាពាក់ព័ន្ធនឹងកិច្ចការសវនកម្ម និងការបង្វិលសងអាករលើតម្លៃបន្ថែម។

ជាកិច្ចបន្ទាប់ ឯកឧត្តម **គង់ វិបុល** បានថ្លែងសុន្ទរកថា និងអរគុណចំពោះសមាគម TAFTAC ដែលបាន

ផ្តួចផ្តើមរៀបចំវេទិកានេះឡើង ក្នុងគោលដៅលើកកម្ពស់ការយល់ដឹងពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងជាការចូលរួមលើកកម្ពស់វប្បធម៌បង់ពន្ធនៅកម្ពុជា។ ក្នុងរយៈពេល១០ ឆ្នាំចុងក្រោយមកនេះ អគ្គនាយកដ្ឋានពន្ធដារកត់សម្គាល់ឃើញថាកម្រិតអនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធមានការកើនឡើង។ ការចូលរួមរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា គឺជាការឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងអនុលោមភាពសារពើពន្ធ និងអភិបាលកិច្ចរបស់វិស័យឯកជន។ អគ្គនាយកដ្ឋានពន្ធដារ តែងតែខិតខំផ្សព្វផ្សាយ តាមរយៈការរៀបចំ សិក្ខាសាលា វេទិកាពន្ធដារ វគ្គបណ្តុះបណ្តាល ការផ្តល់សេវាពិគ្រោះយោបល់តាមរយៈទូរស័ព្ទ (GDT Call Center 1277) និងការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" (GDT Facebook Live) ដើម្បីពន្យល់និងដោះស្រាយបញ្ហាប្រឈមនិងចម្ងល់របស់អ្នកជាប់ពន្ធ។ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា ការចូលរួមពង្រឹងអនុលោមភាពសារពើពន្ធ តាមរយៈការបង្កើននូវតម្លាភាពនៃការប្រកាសបង់ពន្ធរបស់សហគ្រាស គឺជាការចូលរួមជំរុញនិងទាក់ទាញការវិនិយោគនៅកម្ពុជា ព្រោះជាក់ស្តែងប្រសិនបើសហគ្រាសមានផលចំណេញ ក៏ប៉ុន្តែបែរជាប្រកាសខាត នឹងជះឥទ្ធិពលអវិជ្ជមានចំពោះអ្នកវិនិយោគដែលតែងតែមានចំណាប់អារម្មណ៍ក្នុងការវិនិយោគនៅកម្ពុជា ដោយយល់ឃើញថាការវិនិយោគនៅកម្ពុជានឹងមិនមានផលចំណេញ ប៉ុន្តែទិដ្ឋភាពជាក់ស្តែងសហគ្រាសមួយចំនួននៅតែមានវត្តមាននៅកម្ពុជាបានជាង ២០ឆ្នាំ មកហើយ។

**ខ្លឹមសារសំខាន់ៗនៃសុន្ទរកថាគន្លឹះរបស់ឯកឧត្តម គង់ វិបុល រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

- ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ២០២៣ មានគោលបំណងចម្បងចំនួន ៥ គឺ៖ ១.ប្រមូលផ្តុំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន ២.កែសម្រួល និងបំពេញបន្ថែមនូវបទប្បញ្ញត្តិដែលមានភាពខ្វះចន្លោះ ៣.ដាក់បញ្ចូលនូវគោលការណ៍ទន់ភ្លន់ ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ៤.បើកផ្លូវឱ្យមានការចូលរួមអនុវត្តក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា និង៥.គិតគូរជានាឱ្យមានសង្គតិភាពជាមួយច្បាប់ពាក់ព័ន្ធនានា
- ការរៀបចំច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ២០២៣ បានរៀបចំឡើងដោយឆ្លងកាត់ការពិភាក្សាពិគ្រោះយោបល់និងទទួលធាតុចូលពីវិស័យឯកជននិងភាគីពាក់ព័ន្ធជាច្រើនលើកច្រើនសា មុននឹងរៀបចំចេញជាសេចក្តីព្រាងច្បាប់ឆ្លងការពិនិត្យនិងផ្តល់ធាតុចូលពីក្រសួងស្ថាប័នពាក់ព័ន្ធ ដាក់ឆ្លងគណៈរដ្ឋមន្ត្រី ស្ថាប័ននីតិប្បញ្ញត្តិ មានរដ្ឋសភា និងព្រឹទ្ធសភា
- ពីមុនយើងកត់សម្គាល់ឃើញថា ការពង្រឹងអនុលោមភាពសារពើពន្ធក្នុងចំណោមសហគ្រាស ដែលជារោងចក្រនានាមានបញ្ហាលំបាកនៅក្នុងការស្វែងរកសេវាគាំទ្រផ្នែកពន្ធដារ ក៏ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះមានការពង្រឹងនូវភ្នាក់ងារសេវាកម្មពន្ធដារ តាមរយៈសាលាជាតិពន្ធដារ និងវិស័យឯកជនបានចូលរួមនិងដើរតួនាទីយ៉ាងសំខាន់
- សូមលើកទឹកចិត្តឱ្យសមាជិកសមាគម TAFTAC បន្តពង្រឹងនូវការអនុវត្តនូវយន្តការ CMT ដែលនឹងអាចឆ្លើយតបនូវបញ្ហាប្រឈមនានានៅក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ
- វិស័យវាយនភណ្ឌគឺជាវិស័យមួយដែលចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ ហើយកន្លងមករាជរដ្ឋាភិបាលតែងតែបានលើកទឹកចិត្តទាំងផ្នែកពន្ធដារនិងពន្ធគយដើម្បីចូលរួមជំរុញនិងគាំទ្រលើវិស័យនេះ
- អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងបន្តអនុវត្តការងារ ព្រមទាំងការបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធ ដើម្បីធានាថាការអនុវត្តតួនាទីភារកិច្ចប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងគោលដៅឆ្លើយតបអំពីកង្វល់នានាជាមួយនឹងការព្យាករដែលមានពាក់ព័ន្ធនឹងពន្ធដារ (tax predictability)
- បន្តពង្រឹងការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ តាមគ្រប់រូបភាព ជាពិសេសតាមរយៈ

ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងវេទិកាពន្ធដារនានា ដោយគិតត្រឹមរយៈពេល ៩ខែ ឆ្នាំ២០២៤ សរុបបានចំនួន **៦៥០ លើក** មានសិក្ខាកាមចូលរួមចំនួន **៨២ ២៨៩ រូប**

- ជំរុញនិងលើកទឹកចិត្តឱ្យសមាជិក TAFTAC បំពេញកាតព្វកិច្ចសារពើពន្ធ និងទទួលបានអនុលោមភាពកម្រិតមាស ព្រមទាំងក្លាយទៅជាសហគ្រាសដែលទទួលបាននូវការធ្វើសវនកម្មពីអង្គភាពសវនកម្មពន្ធដារពិសេស ដែលនឹងត្រូវអនុវត្តតែរៀងរាល់ ៣ ឆ្នាំម្តង
- បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងកម្មវិធីប្រកបដោយស្មារតីបុរេសកម្មតាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រនិងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីបន្តជំរុញបង្កើនកម្រិតអនុលោមភាពសារពើពន្ធ ដោយធ្វើយ៉ាងណាឱ្យមានភាពងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធដារ ប៉ុន្តែពិបាកក្នុងការគេចវេះ តាមរយៈការបន្តអភិវឌ្ឍបន្ថែមនូវមុខងារមួយចំនួន តាមធាតុចូលដែលទទួលបានពីអ្នកប្រើប្រាស់គ្រប់មជ្ឈដ្ឋាន ដើម្បីឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ និងងាយស្រួលក្នុងការអនុវត្ត
- ជាចក្ខុវិស័យ អគ្គនាយកដ្ឋានពន្ធដារ នឹងបង្កើតនូវ Cambodia Tax Application (CTA) ដែលជាផ្នែកមួយសម្រាប់អ្នកជាប់ពន្ធនិងសាធារណជនចូលរួមនៅក្នុងការប្រើប្រាស់សេវា និងបំពេញកាតព្វកិច្ចសារពើពន្ធ
- អគ្គនាយកដ្ឋានពន្ធដារនៅតែបន្តធ្វើកំណែទម្រង់ និងទំនើបកម្ម ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវការផ្តល់សេវាអ្នកជាប់ពន្ធជាប្រចាំ។

វេទិកាពន្ធដារ នាថ្ងៃនោះ មានវាគ្មិនជំនាញពាក់ព័ន្ធមកពីអគ្គនាយកដ្ឋានពន្ធដារធ្វើបទបង្ហាញនិងពន្យល់ឱ្យបានក្បោះក្បាយអំពីច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធក្នុងដំណើរការអាជីវកម្មនៅកម្ពុជារួមមាន៖ ១.បទបង្ហាញអំពី "ការលើកទឹកចិត្តផ្នែកពន្ធដារក្រោមច្បាប់វិនិយោគថ្មី" ដោយលោក **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ដែលផ្តោតសំខាន់ទៅលើ គម្រោងពង្រីកនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់, វិធីកំណត់ឬគណនារយៈពេលលើកលែងពន្ធលើប្រាក់ចំណូលក្រោមច្បាប់វិនិយោគថ្មី និងនីតិវិធីនិងលក្ខខណ្ឌលម្អិតក្នុងការអនុវត្ត ដើម្បីទទួលបានការកាត់កងចំណាយក្នុងអត្រា ១៥០% ដូចមានចែងក្នុងមាត្រា ២៧ នៃច្បាប់នេះ, ២.បទបង្ហាញអំពី "អាករលើតម្លៃបន្ថែម និងការបង្វិលសងអាករលើតម្លៃបន្ថែម" ដោយលោក **ឯក ពិសិដ្ឋ** ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ដែលផ្តោតសំខាន់ទៅលើ បែបបទនិងនីតិវិធីនៃការព្យួរនិងការផ្តល់ឡើងវិញនូវសុពលភាពវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម, ការបង្វិលសងអាករលើតម្លៃបន្ថែម ចំណុចគន្លឹះនិងបញ្ហាផ្សេងៗដែលអ្នកជាប់ពន្ធឧស្សាហ៍ជួបប្រទះ, ៣.បទបង្ហាញអំពី "កាតព្វកិច្ចសារពើពន្ធនៃសហគ្រាស ដែលមានប្រតិបត្តិការ CMT និង FOB" ដោយលោក **សុង កុសល** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ដែលផ្តោតសំខាន់ទៅលើចំណុចគន្លឹះ និងបញ្ហាផ្សេងៗដែលអ្នកជាប់ពន្ធឧស្សាហ៍ជួបប្រទះ, ៤.បទបង្ហាញអំពី "ការធ្វើសវនកម្មពន្ធដារ និងបែបបទនិងនីតិវិធីថ្មីការធ្វើសវនកម្មពន្ធដារ" ដោយលោក **ជួរ សែ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស ដែលផ្តោតសំខាន់ទៅលើចំណុចគន្លឹះ និងបញ្ហាផ្សេងៗដែលអ្នកជាប់ពន្ធឧស្សាហ៍ជួបប្រទះ, និង៥.បទបង្ហាញអំពី "ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ" ដោយ លោក **ស្រ៊ុន អង្គរ៉េន** ប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ដែលផ្តោតសំខាន់ទៅលើចំណុចគន្លឹះ និងបញ្ហាផ្សេងៗដែលអ្នកជាប់ពន្ធឧស្សាហ៍ជួបប្រទះ។

ក្នុងគោលដៅផ្តល់ឱកាសដល់អ្នកចូលរួមទាំងអស់ឈ្វេងយល់អំពីបញ្ហានានាលើប្រធានបទពាក់ព័ន្ធ វេទិកានាថ្ងៃនេះក៏បានរៀបចំនូវកិច្ចពិភាក្សាជាក្រុម (Panel Discussion) រួមមាន៖

កិច្ចពិភាក្សាជាក្រុមទី១ ផ្តោតលើប្រធានបទទី១ និងទី២ ដោយមានវគ្គមានលោក **អេង រតនា** ប្រធាននាយកដ្ឋាន

គ្រប់គ្រងអ្នកជាប់ពន្ធធំ, លោក **ឯក ពិសិដ្ឋ** ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ, ឧកញ៉ា **តាន់ ឃីម៉េង** នាយកគ្រប់គ្រងនៃក្រុមហ៊ុន បេកឃើរធីលលី ខេមបូឌា, លោកស្រី **ឈុន សុធី** អ្នកគ្រប់គ្រងជាន់ខ្ពស់នៃ ខេ ប្រីហ្វេសិនណល អឹខោនថិន និងលោក **ខេស៊ី បាណោត** នាយកវិទ្យាស្ថានខេមអេជ ជាអ្នកសម្របសម្រួលកម្មវិធី។

កិច្ចពិភាក្សាជាក្រុមទី២ ផ្តោតលើប្រធានបទទី៣ ទី៤ និងទី៥ ដោយមានវត្តមាន លោក **ស្រ៊ុន អង្គរ៉េន** ប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ, លោក **ជួរ សែ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស, លោក **សុង កុសល** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ, លោក **ឃុន ដារិទ្ធ** នាយកគ្រប់គ្រងនៃក្រុមហ៊ុននៃ ខេ ប្រីហ្វេសិនណល អឹខោនថិន, លោក **ទេព សិដ្ឋាន់ណា** អ្នកគ្រប់គ្រងទូទៅនៃ អ៊ីស្ត វីង អឌីធីង & ខនសាល់ធីង និងលោកបណ្ឌិត **ខេន លូ** អគ្គលេខាធិការនៃ សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា ជាអ្នកសម្របសម្រួលកម្មវិធី៕








*លោក **Enjoy Ho** អនុប្រធានសមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC)*




*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*



# កម្មវិធីប្រគល់វិញ្ញាបនបត្រ ភ្នាក់ងារសេវាកម្មពន្ធដារ ជំនាន់ទី១៣ ដល់ទី១៤ និងវិញ្ញាបនបត្រជំនាញវិជ្ជាជីវៈពន្ធដារ ជំនាន់ទី១៥




នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១០ ខែតុលា ឆ្នាំ២០២៤ នៅសាលាជាតិពន្ធដារ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំកម្មវិធីប្រគល់វិញ្ញាបនបត្រភ្នាក់ងារសេវាកម្មពន្ធដារជំនាន់ទី១៣ ដល់ទី១៤ និងវិញ្ញាបនបត្រជំនាញវិជ្ជាជីវៈពន្ធដារជំនាន់ទី១៥ ជូនសិក្ខាកាមជ័យលាភីចំនួន **៣៣៧ រូប** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីឯកឧត្តម-លោកអគ្គនាយករង ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងសិក្ខាកាមជ័យលាភី។

ឆ្លៀតក្នុងឱកាសនោះផងដែរ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីបានសម្តែងនូវអំណរសាទរចំពោះបេក្ខជនជ័យលាភីទាំង **៣៣៧ រូប** និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការសិក្សារៀនសូត្រនូវជំនាញវិជ្ជាជីវៈពន្ធដារនេះ ដែលជាជំនាញមួយមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងអាជីវកម្មរបស់ខ្លួន ឬបំពេញការងារជាបុគ្គលិកទទួលបន្ទុកកិច្ចការពន្ធដាររបស់ក្រុមហ៊ុន ជាពិសេសអាចប្រើប្រាស់វិញ្ញាបនបត្រនោះក្នុងការស្នើសុំអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដារពីអគ្គនាយកដ្ឋានពន្ធដារ ដើម្បីប្រកបអាជីវកម្ម។ ទន្ទឹមនឹងនេះផងដែរ ឯកឧត្តមក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការពន្ធដារ និងលោកគ្រូ-អ្នកគ្រូនៅសាលាជាតិពន្ធដារ ដែលបានខិតខំប្រឹងប្រែង លះបង់ទាំងកម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ក្នុងការផ្តល់សេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារជូនដល់មន្ត្រីពន្ធដារ និងសាធារណជនទូទៅ រហូតទទួលបានលទ្ធផលល្អប្រសើរ។ ឯកឧត្តម បានគូសរំលេចជូនដល់សិក្ខាកាមជ័យលាភីផងដែរថា ចំណូលពន្ធដារជាចំណូលជាតិមួយដ៏ធំសម្រាប់ទ្រទ្រង់ដល់ចំណាយរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះភ្នាក់ងារសេវាកម្មពន្ធដារក៏បានចូលរួមចំណែកមួយយ៉ាងសំខាន់ក្នុងការផ្តល់សេវាពាក់ព័ន្ធនឹងពន្ធដារជូនដល់អ្នកជាប់ពន្ធផងដែរ។ បច្ចុប្បន្ន ភ្នាក់ងារសេវាកម្មពន្ធដារដែលទទួលបានអាជ្ញាបណ្ណជាភ្នាក់ងារសេវាកម្មពន្ធដារពីអគ្គនាយកដ្ឋានពន្ធដារមានប្រមាណជាង **៤០០ ក្រុមហ៊ុន** តែប៉ុណ្ណោះ ហេតុនេះហើយ ក្នុងនាមជាអង្គភាព

គ្រប់គ្រងប្រមូលចំណូលពន្ធដារ អគ្គនាយកដ្ឋានពន្ធដារចង់ឃើញចំនួនភ្នាក់ងារសេវាកម្មពន្ធដារកើនឡើង សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ដែលដឹកនាំដោយ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

**អនុសាសន៍ណែនាំរបស់ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ជូនអង្គពិធីទាំងមូលដូចខាងក្រោម៖**

- ជំរុញនិងលើកទឹកចិត្តឱ្យសិក្ខាកាមជ័យលាភីទាំងអស់ស្នើសុំអាជ្ញាបណ្ណភ្នាក់ងារសេវាកម្មពន្ធដារពីអគ្គនាយកដ្ឋានពន្ធដារ ដើម្បីប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ សំដៅចូលរួមចំណែកជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការជួយពន្យល់ណែនាំ និងផ្តល់សេវាពាក់ព័ន្ធនឹងពន្ធដារជូនអ្នកជាប់ពន្ធ
- ភ្នាក់ងារសេវាកម្មពន្ធដារដែលទទួលបានអាជ្ញាបណ្ណពីអគ្គនាយកដ្ឋានពន្ធដាររួចរាល់ហើយ ត្រូវផ្តល់សេវាជូនអ្នកជាប់ពន្ធប្រកបដោយក្រមសីលធម៌ និងវិជ្ជាជីវៈ ចៀសវាងការចូលរួមជាមួយអ្នកជាប់ពន្ធក្នុងសកម្មភាពគេងបន្លំប្រាក់ពន្ធ
- ភ្នាក់ងារសេវាកម្មពន្ធដារត្រូវជួយពន្យល់ណែនាំអ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធ និងជួយអ្នកជាប់ពន្ធឱ្យបង់ពន្ធបានត្រឹមត្រូវ និងទាន់ពេលវេលា
- សិក្ខាកាមជ័យលាភីទាំងអស់ រួមទាំងភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវបន្តធ្វើបច្ចុប្បន្នភាពចំណេះដឹងរបស់ខ្លួនជាប្រចាំទាំងក្របខ័ណ្ឌនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ
- សាលាជាតិពន្ធដារត្រូវបន្តពង្រឹងគុណភាពបណ្តុះបណ្តាលទាំងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលមន្ត្រី និងការបណ្តុះបណ្តាលសាធារណជនអំពីចំណេះដឹងពាក់ពន្ធនឹងពន្ធដារ ជាពិសេសការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានពន្ធដារ សំដៅធ្វើយ៉ាងណាឱ្យស្របតាមកំណែទម្រង់រដ្ឋបាលសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចបញ្ចប់ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីបានសម្តែងនូវការអបអរសាទរសាជាថ្មីជូនដល់បេក្ខជនជ័យលាភីទាំងអស់ និងថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារដែលបានចូលរួមក្នុងកម្មវិធីនេះ និងបានកោតសរសើរចំពោះលោកគ្រូ-អ្នកគ្រូនៃសាលាជាតិពន្ធដារ ដែលចំណាយពេលវេលាផ្ទាល់ខ្លួនចូលរួមជាមួយសាលាជាតិពន្ធដារ ក្នុងការបណ្តុះបណ្តាល និងបានជូនពរដល់អង្គពិធីទាំងមូលសូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕



# ផ្នែកទី១
# ស្ថានភាពនៃការគ្រប់គ្រងការប្រមូលចំណូលពន្ធ

១. លទ្ធផលការងារប្រមូលចំណូលពន្ធ
២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ
៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ
៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ

# ๒

# ១. លទ្ធផលការងារប្រមូលចំណូលពន្ធ

សរុបរយៈពេល ១២ខែ ឆ្នាំ២០២៤ ចំណូលពន្ធអាករ ដែលប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន **១៣ ៨៩៤,៥៣ ប៊ីលានរៀល** (ប្រមាណជា **៣ ៤៣០,៧៥ លានដុល្លារ**) ស្មើនឹង **៨២,៣៩%** នៃផែនការដែលបានកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

**ចំណូលពន្ធអាករគ្រប់ប្រភេទ រយៈពេល ១២ខែ ឆ្នាំ២០២៤**




| | | | | | |
|---|---|---|---|---|---|
| ឆ្នាំ២០២៤ | ១០ ៦៨៩,១៨ | ១ ០៧៣,៥៤ | ១ ១១៥,៩១ | ១ ០០៦,១៨ | ១៣ ៨៩៤,៥៣ |

# ២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ

**ចំណូលពន្ធអាករតាមប្រភេទអ្នកជាប់ពន្ធ រយៈពេល ១២ខែ ឆ្នាំ២០២៤**



សរុបរយៈពេល ១២ខែ ឆ្នាំ២០២៤ ចំណូលពន្ធអាករតាមប្រភេទអ្នកជាប់ពន្ធ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានក្នុងនោះរួមមាន៖

- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធធំ ចំនួន **១០ ២៤៨,៧៤ ប៊ីលានរៀល** ស្មើនឹង **៧៣,៧៦%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធមធ្យម ចំនួន **២ ២៨៥,៨៤ ប៊ីលានរៀល** ស្មើនឹង **១៦,៤៥%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធតូច ចំនួន **៩៤,៣៣ ប៊ីលានរៀល** ស្មើនឹង **០,៦៨%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីប្រភេទពន្ធផ្សេងៗ (ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើអចលនទ្រព្យ និងពន្ធផ្សេងៗ) ចំនួន **១ ២៦៥,៦២ ប៊ីលានរៀល** ស្មើនឹង **៩,១១%** ធៀបនឹងចំណូលពន្ធអាករសរុប។

## ៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ

**ចំណូលពន្ធអាករតាមប្រភេទអ្នកជាប់ពន្ធ រយៈពេល ១២ខែ ឆ្នាំ២០២៤**




សរុបរយៈពេល ១២ខែ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលតាមប្រភេទពន្ធសំខាន់ៗរួមមាន៖

- ពន្ធលើប្រាក់ចំណូលចំនួន **៣ ៧៩៣,៥៨ ប៊ីលានរៀល**
- អាករលើតម្លៃបន្ថែមចំនួន **៣ ៣៧៥,៤២ ប៊ីលានរៀល**
- អាករពិសេសចំនួន **៩២៩,០២ ប៊ីលានរៀល**
- ពន្ធលើប្រាក់បៀវត្សចំនួន **១ ៣៩៧,៩៩ ប៊ីលានរៀល**
- ពន្ធប្រថាប់ត្រាសរុប (ផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ) ចំនួន **៦៨០,៣១ ប៊ីលានរៀល**
- ពន្ធកាត់ទុកទូទៅចំនួន **២ ៧៨៤,១៣ ប៊ីលានរៀល**
- ផ្សេងៗចំនួន **៩៣៤,០៨ ប៊ីលានរៀល**។

# ៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ

ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៤ ចំណូលពន្ធពីសកម្មភាពកម្មន្តសាល សកម្មភាពសេវាហិរញ្ញវត្ថុនិងធានារ៉ាប់រង និង អាហារ៍ណេ-នីហារ៍ណេ គឺជាចំណូលពន្ធចម្បង និងលេចធ្លោជាងគេ។ ជាក់ស្តែង ចំណូលពន្ធអាករពីចំណូលពន្ធពី សកម្មភាពកម្មន្តសាលមានចំនួន **៣ ០៨១,៩៥ ប៊ីលានរៀល**, សកម្មភាពសេវាហិរញ្ញវត្ថុនិងធានារ៉ាប់រងមានចំនួន **២ ៧២០,៣៧ ប៊ីលានរៀល** និងចំណូលពន្ធអាករពីសកម្មភាពនីហារ៍ណេ-អាហារ៍ណេមានចំនួន **២ ០៩៣,២៣ ប៊ីលានរៀល**។ ទន្ទឹមនឹងនេះ ចំណូលពន្ធពីសកម្មភាពដែលកើនឡើងគួរឱ្យកត់សម្គាល់សម្រាប់ ១២ខែ ឆ្នាំ២០២៤ គឺចំណូលពន្ធអាករ បានមកពីសកម្មភាពកម្មន្តសាល បើធៀបនឹងរយៈពេលនិងសកម្មភាពដូចគ្នានៃឆ្នាំ២០២៣ កើនឡើងចំនួន **៦៧,៦៥ ប៊ីលានរៀល** ស្មើនឹង **២,២៥ %**។ តារាងចំណូលពន្ធអាករ តាមសកម្មភាពអាជីវកម្មសំខាន់ៗដែល អគ្គនាយកដ្ឋានពន្ធដារ ប្រមូលបានជាក់ស្តែង ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៤ មានបង្ហាញដូចខាងក្រោម៖

**តារាងចំណូលពន្ធអាករតាមសកម្មភាពអាជីវកម្មសំខាន់ៗ រយៈពេល ១២ខែ ឆ្នាំ២០២៤**

(តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ)

| បរិយាយ | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ | សរុប១២ខែ |
|---|---|---|---|---|
| អាហារ៍ណេ-នីហារ៍ណេ (រួមបញ្ចូលការលក់ផលិតផលកសិកម្ម) | ១៥៨,៩១ | ១៤២,៧១ | ១៧៩,៦៩ | ២ ០៩៣,២៣ |
| សេវាហិរញ្ញវត្ថុ និងធានារ៉ាប់រង | ១៥៦,៧៥ | ១៥១,៨០ | ១៥៨,៤៨ | ២ ៧២០,៣៧ |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៥,៨៧ | ៩,៣៤ | ៨,៩៨ | ១២៣,៩៣ |
| ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ | ៦,៥៨ | ៥,៧៣ | ៦,៣៥ | ១៧២,០៧ |
| កម្មន្តសាល | ២៥០,៥៨ | ២០៥,៤៨ | ២២៥,៤១ | ៣ ០៨១,៩៥ |
| សកម្មភាពអចលនវត្ថុ | ៣៤,៧៦ | ៤៦,៣៦ | ៥០,៧២ | ៦៤០,២៩ |
| ការដឹកជញ្ជូន និងការស្តុកទុក | ៦០,៤០ | ៥០,៧៥ | ៥២,៤២ | ៧២៨,៣៥ |
| ព័ត៌មានវិទ្យា និងទូរគមនាគមន៍ | ១០១,៣៨ | ៥៩,០០ | ៥៨,៧១ | ៩១៦,៨៤ |
| ការអប់រំ | ១០,៥៧ | ៨,០៧ | ៨,៣៩ | ១០៦,២៦ |
| សេវាកម្មស្នាក់នៅ និងអាហារ | ២៤,៧២ | ២៨,១៣ | ៣១,៨៣ | ៣៥១,៧៥ |
| ការសាងសង់ | ៤៨,៣១ | ៤៦,១១ | ៥៣,៥៧ | ៦៦៨,៨៣ |

* សម្គាល់ ៖ ចំណូលឯកតាគិតជាប៊ីលានរៀល។

# ផ្នែកទី២

# វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រ

១. ការចុះបញ្ជីពន្ធដារ

២. ការផ្តល់សេវាអ្នកជាប់ពន្ធ

៣. ការចាត់ចែងលិខិតប្រកាសពន្ធ

៤. ការធ្វើសវនកម្មពន្ធដារ

៥. ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា

៦. បច្ចេកវិទ្យាព័ត៌មាន

# ๒

## ១.ការចុះបញ្ជីពន្ធដារ

ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានអនុញ្ញាតឱ្យចុះបញ្ជីសរុបចំនួន **១០ ៤៤២ សហគ្រាស** **(ពន្ធធំ ៦៨៩ ពន្ធមធ្យម ៤ ៩៧៤ និងពន្ធតូច ៤ ៧៧៩) ក្នុងនោះតាមថ្នាលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចំនួន ៩ ៧៣៧ សហគ្រាស (ពន្ធធំ ៦៤៥ ពន្ធមធ្យម ៤ ៦៥១ និងពន្ធតូច ៤ ៤៤១)**។ ដោយឡែក ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៤ ចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានសហគ្រាសអនិវាសនជនចុះបញ្ជីអាករលើតម្លៃបន្ថែមសាមញ្ញចំនួន **១២ សហគ្រាស** (គិតចាប់ពីឆ្នាំ២០២២ ដល់ខែធ្នូ ឆ្នាំ២០២៤ សរុបចំនួន **៩៦ សហគ្រាស**)។

## ២.ការផ្តល់សេវាអ្នកជាប់ពន្ធ

### មជ្ឈមណ្ឌលពិគ្រោះយោបល់

ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានផ្តល់សេវាអ្នកជាប់ពន្ធសរុបចំនួន **៩៨ ៦១៨ ករណី** បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ ឃើញថាថយចុះ **-១៨ ១៤៩ ករណី** ស្មើនឹង **-១៥,៥៤%** ក្នុងនោះមានការថយចុះគ្រប់ករណីនៃការផ្តល់សេវាទាំងអស់ ការថយចុះច្រើនជាងគេគឺការផ្តល់សេវាតាមរយៈបណ្តាញសង្គម Facebook ថយចុះ ៤៦,៣៤% និងតាមរយៈតេឡេក្រាម "ព័ត៌មានពន្ធដារកម្ពុជា" ថយចុះ ៤៣,៧២%។ ការថយចុះនៃការផ្តល់សេវានេះ គឺជាការថយចុះនៃការសាកសួរសំណួរតាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធដែលឆ្លុះបញ្ចាំងអំពីការយល់ដឹងរបស់អ្នកជាប់ពន្ធមានការកើនឡើង។

**ការផ្តល់សេវាពិគ្រោះយោបល់ រយៈពេល ១២ខែ ឆ្នាំ២០២៣និងឆ្នាំ២០២៤**

| បរិយាយ | ១២ខែ ឆ្នាំ២០២៣ | ១២ខែ ឆ្នាំ២០២៤ | %ថយ |
|---|---|---|---|
| ទូរស័ព្ទ (១២៧៧) | ៧៣ ៦៦១ | ៦៣ ៩៨៦ | -១៣,១៣% |
| GDT Live Chat | ៣៣ ០០៣ | ២៩ ១១៩ | -១១,៧៧% |
| បណ្តាញសង្គម Facebook | ៧ ៧១៤ | ៤ ១៣៩ | -៤៦,៣៤% |
| កម្មវិធី "ពន្ធដារកម្ពុជា" | ៤៨ | ៤៤ | -៨,៣៣% |
| កម្មវិធី "រៀនអំពីពន្ធដារតាមអនឡាញ" | ៤៧ | ៣៩ | -១៧,០២% |
| តេឡេក្រាម "ព័ត៌មានពន្ធដារកម្ពុជា" | ២ ២៩៤ | ១ ២៩១ | -៤៣,៧២% |
| **សរុបរួម** | ១១៦ ៧៦៧ | ៩៨ ៦១៨ | -១៥,៥៤% |

* សម្គាល់ ៖ ឯកតាគិតជាចំនួនករណី។

### ការផ្តល់សេវាអ្នកជាប់ពន្ធចំពោះ "ការគាំទ្រប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ (e-Tax Service)"

ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានផ្តល់សេវាដោះស្រាយបញ្ហាប្រឈមនានា ក្នុងការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីតាមរយៈអនឡាញ (e-Tax Service) សរុបចំនួន **៣៥ ៤៨២ ដង** ដែលក្នុងនោះការស្នើសុំតាមរយៈ GDT Live Chat ចំនួន **១៣ ០៥៩ ដង**, សារអេឡិចត្រូនិក (E-Mail) ចំនួន **៤៩៧ ដង**, ទូរស័ព្ទ (១២៧៧) ចំនួន **១៣ ៧៥៣ ដង**, ហ្វេសប៊ុកចំនួន **៦ ដង** និងក្រុមតេឡេក្រាម (Telegram) ចំនួន **៨ ១៦៧ ដង**។

# កម្មវិធីពន្ធដារកម្ពុជា

កម្មវិធីពន្ធដារកម្ពុជា គឺជាកម្មវិធីដែលអគ្គនាយកដ្ឋានពន្ធដារបានរៀបចំឡើងដើម្បីចែករំលែកចំណេះដឹង ព័ត៌មានទាក់ទងនឹងពន្ធដារ ជាពិសេសផ្តល់ឱកាសឱ្យសាធារណជនចូលរួមមតិយោបល់ ឬលើកឡើងនូវចម្ងល់នានាពាក់ព័ន្ធនឹងប្រធានបទនីមួយៗ ដែលធ្វើការផ្សាយផ្ទាល់តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ រៀងរាល់ថ្ងៃព្រហស្បតិ៍ វេលាម៉ោង ១១:០០ ដល់ម៉ោង ១២:០០ថ្ងៃត្រង់។ កម្មវិធីនេះ ទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកជាប់ពន្ធ និងសាធារណជន ដែលទស្សនិកជនអាចផ្តល់មតិយោបល់ ឬសួរសំណួរតាមរយៈទូរស័ព្ទមកលេខ ១២៧៧ ដោយឥតគិតថ្លៃ ឬអាចចូលទៅផ្តល់មតិយោបល់ (Comment) នៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារភ្លាមៗក្នុងពេលផ្សាយផ្ទាល់ នោះវាគ្មិននឹងធ្វើការឆ្លើយតបផ្ទាល់ក្នុងកម្មវិធីតែម្តង។ ក្នុងករណីខកខានមិនបានទស្សនាការផ្សាយផ្ទាល់ ទស្សនិកជនក៏អាចទស្សនាឡើងវិញ ព្រមទាំងអាចសួរសំណួរតាមរយៈ Comments ក្នុងវីដេអូនោះ ក្រុមការងារ GDT Call Center របស់អគ្គនាយកដ្ឋានពន្ធដារ នឹងធ្វើការឆ្លើយតបជូនតាមលំដាប់លំដោយ។ ក្រៅពីការចូលទៅទស្សនាឡើងវិញនៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ ទស្សនិកជនក៏អាចចូលទៅទស្សនាក្នុងបណ្តាញយូធូប (YouTube) "General Department of Taxation, Cambodia" របស់អគ្គនាយកដ្ឋានពន្ធដារផងដែរ។

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកម្មវិធីពន្ធដារកម្ពុជាសរុបចំនួន **៩ លើក** ដោយផ្តោតលើប្រធានបទសំខាន់ៗរួមមាន ១.បំណុលពន្ធ ២.នីតិវិធីនៃការបិទសហគ្រាសជាស្ថាពរ ៣.កាតព្វកិច្ចសារពើពន្ធក្នុងអំឡុងពេលផ្អាកសកម្មភាពអាជីវកម្ម ៤.កាតព្វកិច្ចសារពើពន្ធរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ៥.សវនកម្មពន្ធដារ ៦.កាតព្វកិច្ចបង់ពន្ធអាករចំពោះការផ្គត់ផ្គង់ទំនិញដោយមានការថែមទំនិញឬផ្តល់ជារង្វាន់របស់សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុក ៧.ពន្ធលើមធ្យោបាយដឹកជញ្ជូន ៨.ការស្នើសុំលិខិតបញ្ជាក់ស្ថានភាពសារពើពន្ធនិងការស្នើសុំលិខិតអនុញ្ញាតឱ្យបង់ជាដំណាក់កាល និង៩.បច្ចុប្បន្នភាពបទប្បញ្ញត្តិស្តីពីពន្ធដារនិងពន្ធលើប្រាក់ចំណូល៕



## កម្មវិធីពន្ធដារកម្ពុជាស្តីពី “បំណុលពន្ធ”

កម្មវិធីនេះមានលោក **បាច ពេជតិរុណ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងលោក **តាំង ភុកសេង** ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ១២ អ្នកចូលទស្សនាចំនួន ២៨ ០០០ ដង និងមានការចែករំលែកបន្តចំនួន ១០៩ ដង៕




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្តីពី “នីតិវិធីនៃការបិទសហគ្រាសជាស្ថាពរ”

កម្មវិធីនេះមានលោក **ជួរ សៃ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស និងលោក **ហេង សុវណ្ណារ័ត្ន** ប្រធានការិយាល័យនៃនាយកដ្ឋានសវនកម្មសហគ្រាស ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៧ ខែតុលាឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៣២ អ្នកចូលទស្សនាចំនួន ២១ ២០០ ដង និងមានការចែករំលែកបន្តចំនួន ៩៩ ដង៕




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្តីពី “ភាតព្វកិច្ចសារពើពន្ធក្នុងអំឡុងពេលផ្អាកសកម្មភាពអាជីវកម្ម”

កម្មវិធីនេះមានលោក **ភុល ម៉ារ៉ាដុល្លា** ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ស៊ីម ស៊ុនហួច** អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ២៨ អ្នកចូលទស្សនាចំនួន ២៣ ៧០០ ដង និងមានការចែករំលែកបន្តចំនួន ១២២ ដង៕




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ភាតព្វកិច្ចសារពើពន្ធរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល"




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ម៉ៅ ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងលោក **ខែន គីម** អនុប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៤២ អ្នកចូលទស្សនាចំនួន ២២ ៥០០ ដង និងមានការចែករំលែកបន្តចំនួន ១០២ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "សវនកម្មពន្ធដារ"




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានឯកឧត្តម **រ័ត្ន មុនី** អគ្គនាយករង និងលោក **ជួរ សៃ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ២៣ អ្នកចូលទស្សនាចំនួន ២៥ ១០០ ដង និងមានការចែករំលែកបន្តចំនួន ១៤៩ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ភាតព្វកិច្ចបង់ពន្ធអាករចំពោះការផ្គត់ផ្គង់ទំនិញដោយមានការថែមទំនិញឬផ្តល់ជារង្វាន់របស់សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុក"




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ម៉ឹង សុខឡៅ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២១ ខែវិច្ឆិកាឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៤១ អ្នកចូលទស្សនាចំនួន ២៤ ២០០ ដង និងមានការចែករំលែកបន្តចំនួន ១៧២ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី “ពន្ធលើមធ្យោបាយដឹកជញ្ជូន”




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ខ៊ែត ឆៃលាង** អនុប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ និងលោក **យិន សុធាវី** ប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៥ អ្នកចូលទស្សនាចំនួន ១៨ ៤០០ ដង និងមានការចែករំលែកបន្តចំនួន ៧១ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី “ការស្នើសុំលិខិតបញ្ជាក់ស្ថានភាពសារពើពន្ធ និងការស្នើសុំលិខិតអនុញ្ញាតឱ្យបង់ជាដំណាក់កាល”




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ម៉ូ សណ្តាប់** អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ និងលោក **ខួន សិទ្ធីគុណ** មន្ត្រីនៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ១៥ អ្នកចូលទស្សនាចំនួន ២២ ០០០ ដង និងមានការចែករំលែកបន្តចំនួន ១៣២ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី “បច្ចុប្បន្នភាពបទប្បញ្ញត្តិស្តីពីពន្ធដារ និងពន្ធលើប្រាក់ចំណូល”




សូមស្កេនដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ និងលោក **ឆាយ ជាហេង** អនុប្រធានអង្គភាពសវនកម្មពន្ធដារពិសេស ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៣៩ អ្នកចូលទស្សនាចំនួន ២៨ ៤០០ ដង និងមានការចែករំលែកបន្តចំនួន ២០៩ ដង៕

# ៣.ការចាត់ចែងលិខិតប្រកាសពន្ធ

**ការកែសម្រួលប្រការ៣ នៃប្រកាសលេខ ០៧១ សហវ.ប្រក.អពដ**
**ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត**

នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៦២៥ សហវ.ប្រក ស្តីពីការកែសម្រួលប្រការ៣ នៃប្រកាសលេខ ០៧១ សហវ.ប្រក.អពដ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត ដែលមានខ្លឹមសារដូចខាងក្រោម៖

១. អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដែលស្នើសុំធ្វើការកែតម្រូវបញ្ជីគណនេយ្យ និងលិខិតប្រកាសពន្ធឡើងវិញដោយស្ម័គ្រចិត្ត ត្រូវទទួលបានការលើកលែងទណ្ឌកម្មរដ្ឋបាល រួមមាន ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ទាំងស្រុង ដោយទុករយៈពេលរហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៥ ដូចខាងក្រោម៖

ក. ចំពោះការស្នើសុំកែតម្រូវបញ្ជីគណនេយ្យ និងលិខិតប្រកាសពន្ធឡើងវិញលើប្រតិបត្តិការដែលកើតឡើងមុនការិយបរិច្ឆេទខែសីហា ឆ្នាំ២០២៤ តែប៉ុណ្ណោះ។ ដោយឡែក ការស្នើសុំកែតម្រូវលិខិតប្រកាសពន្ធលើប្រតិបត្តិការដែលកើតឡើងចាប់ពីខែសីហា ឆ្នាំ២០២៤ តទៅ មិនត្រូវទទួលបានការលើកលែងទណ្ឌកម្មរដ្ឋបាលនេះឡើយ។

ខ. ចំពោះការស្នើសុំកែតម្រូវបញ្ជីគណនេយ្យ និងលិខិតប្រកាសពន្ធឡើងវិញក្នុងអំឡុងពេលរងសវនកម្មពន្ធដារ ដែលការកែតម្រូវនោះបានធ្វើឡើងមុនពេលសវនករពន្ធដាររកឃើញកំហុសរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកតែប៉ុណ្ណោះ (ក្នុងករណីសវនករមិនទាន់បានបង្ហាញ និងគ្មានកំណត់ហេតុបញ្ជាក់ពីលទ្ធផលសវនកម្ម)។

២. ប្រសិនបើការកែតម្រូវលិខិតប្រកាសពន្ធលើលទ្ធផលសវនកម្មដែលសវនករបានរកឃើញក្នុងអំឡុងពេលរងសវនកម្មពន្ធដារ អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវទទួលរងពន្ធបន្ថែម ១០ (ដប់) ភាគរយ និងការប្រាក់ ១,៥ (មួយក្បៀសប្រាំ) ភាគរយ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។ ករណីនេះ អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក នឹងត្រូវទទួលរងពន្ធបន្ថែមនិងការប្រាក់ តាមនីតិវិធីនិងលទ្ធផលនៃការធ្វើសវនកម្មពន្ធដារ ដោយពន្ធបន្ថែម និងការប្រាក់ដែលបានបង់រួច តាមរយៈការកែតម្រូវលិខិតប្រកាសពន្ធ ដោយស្ម័គ្រចិត្ត ត្រូវអនុញ្ញាតឱ្យកាត់កងជាមួយនឹងពន្ធបន្ថែម និងការប្រាក់ដែលជាលទ្ធផលនៃការធ្វើសវនកម្ម៕

អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងដាក់ឱ្យប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូចលើទូរស័ព្ទដៃ ឈ្មោះ GDT Tax Prefiling App (មានមុខងារ ១.កត់ត្រាទិន្នន័យទិញ-លក់ ២.ប្រកាសពន្ធប្រចាំខែ-ប្រចាំឆ្នាំ ៣.មើលប្រវត្តិប្រកាសពន្ធ-ប្រវត្តិបង់ប្រាក់ពន្ធ និង៤.ពិនិត្យមើលបំណុលពន្ធរបស់ក្រុមហ៊ុន) ដែលលោកអ្នកអាចចូលទៅទាញយកនៅក្នុង Play Store ឬ App Store។ សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំ ចាប់តាំងពីខែកញ្ញា ឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (e-Filing) និងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) ដែលមានលក្ខណៈពេញលេញភ្ជាប់ជាមួយនឹងមុខងារទូទាត់ប្រាក់ពន្ធតាមរយៈប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធធនាគារ ដើម្បីផ្តល់ភាពងាយស្រួលជូនអ្នកជាប់ពន្ធកាត់បន្ថយពេលវេលា និងដោះស្រាយបញ្ហាប្រឈមក្នុងការបំពេញលិខិតប្រកាសនិងទូទាត់ប្រាក់ពន្ធ។ បន្ថែមពីនេះ នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារ បានចេញសេចក្តីណែនាំលេខ ៤៥៤១៧ អពដ ស្តីពីនីតិវិធីនៃការកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែតាមអនឡាញ ក្នុងគោលបំណងផ្តល់ជូនអ្នកជាប់ពន្ធក្នុងការកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែកន្លងមក ដែលបានប្រកាសខុសទិន្នន័យដោយផ្អែកលើមូលដ្ឋាននៃការភាន់ច្រឡំ ឬភ្លាំងភ្លាត់ ឬមានបំណងធ្វើបច្ចុប្បន្នភាពទិន្នន័យ ព្រមទាំងបញ្ចូលមុខងារថ្មីរួមមានការភ្ជាប់លិខិតផ្ទេរសិទ្ធិនិងប័ណ្ណសម្គាល់សម្រាប់គណនីប្រើប្រាស់ជាភ្នាក់ងារសេវាកម្មពន្ធដារនិងតំណាងសហគ្រាស ភ្ជាប់របាយការណ៍ហិរញ្ញវត្ថុ និងការកែតម្រូវលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដែលបានប្រកាសរួចរាល់៕

## ការចាប់រង្វាន់ផ្សងសំណាងពីកម្មវិធីវិក្កយបត្រនាំសំណាង GDT Lucky Draw App របស់អគ្គនាយកដ្ឋានពន្ធដារ




នាព្រឹកថ្ងៃពុធ ទី៦ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅក្រុមហ៊ុន MAZDA CAMBODIA មហាវិថីសម្តេចហ៊ុនសែន ៦០ម៉ែត្រ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំការចាប់រង្វាន់ផ្សងសំណាងពីកម្មវិធី "វិក្កយបត្រនាំសំណាង (GDT Lucky Draw App)" ដើម្បីផ្តល់សំណាងដល់សាធារណជន ក្រោមអធិបតីភាពឯកឧត្តម **គង់ វិបុល** រដ្ឋមន្រ្តីប្រតិភូអមនាយករដ្ឋមន្រ្តី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្រ្តីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងអ្នកឧកញ៉ា ឧកញ៉ា លោក-លោកស្រី ដែលជាដៃគូសហការគាំទ្រក្នុងកម្មវិធី។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **គង់ វិបុល** បានថ្លែងក្នុងកម្មវិធីនាវេលានោះ ដោយបានលើកឡើងពីអត្ថប្រយោជន៍នៃការប្រើប្រាស់កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App) និងជំរុញការប្រើប្រាស់កម្មវិធី GDT Lucky Draw នេះ តាមរយៈការបញ្ចូលវិក្កយបត្រឱ្យបានច្រើន ដើម្បីជាការរួមចំណែកមួយក្នុងការពង្រឹងការប្រមូលចំណូលពន្ធដារ ពង្រឹងកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវ តម្លាភាព អនុលោមភាពសារពើពន្ធ កាត់បន្ថយការគេចវេះពន្ធ តាមរយៈការចេញវិក្កយបត្រ ជានាថាការចេញវិក្កយបត្រទាំងអស់របស់អ្នកផ្គត់ផ្គង់ទំនិញឬសេវា បានបំពេញកាតព្វកិច្ចសារពើពន្ធត្រឹមត្រូវតាមច្បាប់។ ទន្ទឹមនឹងការរួមចំណែក ជាមួយអគ្គនាយកដ្ឋានពន្ធដារ សាធារណជនក៏មានឱកាសឈ្នះរង្វាន់ជាច្រើនផងដែរ។ ដូច្នេះ ការចាប់រង្វាន់ផ្សងសំណាងនេះ គឺសម្រាប់សាធារណជនទាំងឡាយណាដែលបានបញ្ចូលវិក្កយបត្រចំណាយរបស់ខ្លួន តាមរយៈកម្មវិធីវិក្កយបត្រនាំសំណាង GDT Lucky Draw App ដែលអាចធ្វើការដោនឡូត (Download) កម្មវិធីនេះតាមរយៈ App Store ឬ Play Store បានដោយឥតគិតថ្លៃ។ ក្នុងនោះការចាប់រង្វាន់ផ្សងសំណាងត្រូវបានធ្វើឡើងចំនួន **២ លើក** រួចមកហើយ ដែលរង្វាន់រួមមានដូចជា រថយន្តសេរីទំនើប ម៉ូតូ Honda សេរីថ្មី ទូរស័ព្ទដៃ ទូរទស្សន៍ ទូទឹកកក និងរង្វាន់ផ្សេងៗជាច្រើនទៀត។ សូមសាធារណជនទាំងអស់ បន្តបញ្ចូលវិក្កយបត្រឱ្យបានច្រើនតាមកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App) នឹងអាចមានសំណាងឈ្នះរង្វាន់ធំៗជាច្រើនសន្ធឹកសន្ធាប់សម្រាប់ការចាប់រង្វាន់បន្ទាប់។

កម្មវិធីថ្ងៃនេះ គឺជាការចាប់រង្វាន់ផ្សងសំណាងលើកទី៣ ដែលអគ្គនាយកដ្ឋានពន្ធដារបានរៀបចំចាប់រង្វាន់ផ្សងសំណាងជូនសាធារណជន ដែលបានបញ្ចូលវិក្កយបត្រចំណាយរបស់ខ្លួន តាមរយៈកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)។ គួរបញ្ជាក់ផងដែរថា ការចាប់រង្វាន់ផ្សងសំណាងនាថ្ងៃនេះ អគ្គនាយកដ្ឋានពន្ធដារបានរកឃើញអ្នកដែលមានសំណាងឈ្នះរង្វាន់ ចំនួន ៤០ រង្វាន់ រួមមានរថយន្ត Mazda CX-5 ចំនួន ១ រង្វាន់ ម៉ូតូ Honda Dream ចំនួន ៥ រង្វាន់ ទូរស័ព្ទ Iphone ចំនួន ៥ រង្វាន់ ទូរទស្សន៍ LG 43 អ៊ីញ ចំនួន ១០ រង្វាន់ ទូទឹកកក ចំនួន ៥ រង្វាន់ និងរង្វាន់លើកទឹកចិត្តផ្សេងៗទៀត ចំនួន ១៤ រង្វាន់ ហើយ ទីកន្លែង និងពេលវេលាក្នុងការប្រគល់រង្វាន់ អគ្គនាយកដ្ឋានពន្ធដារនឹងជូនដំណឹងនាពេលឆាប់ៗខាងមុខនេះ៕

## ៤.ការធ្វើសវនកម្មពន្ធដារ

ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មគ្រប់ប្រភេទលើសហគ្រាសសរុបបាន ចំនួន **១០ ៣៩០ ករណី** មានប្រាក់ពន្ធចំនួន **៤ ៦៩៥,៣៧ ប៊ីលានរៀល**។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ ឃើញថាការធ្វើសវនកម្មមានការថយចុះចំនួន **-២ ៦២៤ ករណី** ស្មើនឹង **-២០,១៦%**។

**ចំនួនករណី និងប្រាក់ពន្ធអាករ ដែលបានមកពីការធ្វើសវនកម្ម រយៈពេល ១២ខែ ឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២៣**

| បរិយាយ | ចំនួនករណី | ប្រាក់ពន្ធអាករ(ប៊ីលានរៀល) |
|---|---|---|
| ឆ្នាំ២០២៤ | ១០ ៣៩០ | ៤ ៦៩៥,៣៧ |
| ឆ្នាំ២០២៣ | ១៣ ០១៤ | ១១ ៧៩៤,៧០ |

## ៥.ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា

### ការប្រមូលបំណុលពន្ធ

ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៤ បំណុលពន្ធប្រមូលបានមានចំនួន **៥៨៨,២៨ ប៊ីលានរៀល** (ប្រមាណជា **១៤៥,២៥ លានដុល្លារ**) ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ មានចំនួន **៨៣៩,៩១ ប៊ីលានរៀល** (ប្រមាណជា **២០៧,៣៩ លានដុល្លារ**)។

**លទ្ធផលប្រមូលបំណុលពន្ធ រយៈពេល ១២ខែ ឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣**

ឯកតាគិតជាប៊ីលានរៀល

| បរិយាយ | រយៈពេល៩ខែ | តុលា | វិច្ឆិកា | ធ្នូ | សរុបរួម |
|---|---|---|---|---|---|
| ឆ្នាំ២០២៤ | ៤៧៦,៤៣ | ៣៧,៨០ | ៣៣,៣៩ | ៤០,៦៦ | **៥៨៨,២៨** |
| ឆ្នាំ២០២៣ | ៦៤៦,៣៦ | ៧២,១២ | ៦០,៥៦ | ៦០,៨៨ | **៨៣៩,៩១** |
| %ថយ | -២៦,២៩% | -៤៧,៥៩% | -៤៤,៨៦% | -៣៣,២១% | **-២៩,៩៦%** |

*សម្គាល់៖ តួលេខប្រមូលបំណុលពន្ធ "សរុបរួម" មានការកែតម្រូវឡើងវិញ និងកត់ត្រាបន្ថែមនូវតួលេខបំណុលពន្ធទារបានក្នុងខែតុលា-ធ្នូ មួយចំនួន ដោយអ្នកជាប់ពន្ធមិនបានយកបង្កាន់ដៃទូទាត់ប្រាក់ពន្ធទៅប្រកាស ដើម្បីកត់ត្រា។

### បណ្តឹងតវ៉ា

ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានដោះស្រាយសំណុំឯកសារបណ្តឹងតវ៉ា ចំនួន **៨៣០ ករណី** ប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ គឺមានការកើនឡើងចំនួន **៣៨៨ ករណី**។ ចំនួនទឹកប្រាក់បានបង់ចំពោះបណ្តឹងតវ៉ាដោះស្រាយបាន មានចំនួន **៣៣,៣៧ ប៊ីលានរៀល**។

# ៦.បច្ចេកវិទ្យាព័ត៌មាន

អគ្គនាយកដ្ឋានពន្ធដារបានបន្តធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានពន្ធដារ សម្រាប់គាំទ្រដល់ការគ្រប់គ្រងការប្រមូលចំណូលពន្ធ ការផ្តល់សេវាអ្នកជាប់ពន្ធ ចាប់ពីឆ្នាំ២០១៤ ដល់បច្ចុប្បន្នសរុបចំនួន **៨១ ប្រព័ន្ធ-កម្មវិធី** និងគេហទំព័រ៕

**ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ពីឆ្នាំ ២០១៤ ដល់បច្ចុប្បន្ន**

| បរិយាយ | ប្រព័ន្ធ | កម្មវិធី | គេហទំព័រ | សរុបរួម |
|---|---|---|---|---|
| ឆ្នាំ២០១៤ | ០៣ | ០១ | ០០ | ០៤ |
| ឆ្នាំ២០១៥ | ០៣ | ០២ | ០០ | ០៥ |
| ឆ្នាំ២០១៦ | ០៣ | ០១ | ០០ | ០៤ |
| ឆ្នាំ២០១៧ | ១០ | ០១ | ០១ | ១២ |
| ឆ្នាំ២០១៨ | ០៤ | ០៤ | ០០ | ០៨ |
| ឆ្នាំ២០១៩ | ០១ | ០០ | ០០ | ០១ |
| ឆ្នាំ២០២០ | ១៣ | ០៤ | ០១ | ១៨ |
| ឆ្នាំ២០២១ | ០៧ | ០២ | ០០ | ០៩ |
| ឆ្នាំ២០២២ | ១១ | ០៣ | ០០ | ១៤ |
| ឆ្នាំ២០២៣ | ០៣ | ០៣ | ០០ | ០៦ |
| ឆ្នាំ២០២៤ | ០០ | ០០ | ០០ | ០០ |
| **សរុបរួម** | ៥៨ | ២១ | ០២ | ៨១ |

## គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ (GDT Website)

អគ្គនាយកដ្ឋានពន្ធដារមានគេហទំព័រផ្លូវការមួយ (www.tax.gov.kh) ដើម្បីផ្សព្វផ្សាយព័ត៌មានថ្មីៗ ទាក់ទងនឹងអ្នកជាប់ពន្ធ សេវាសាធារណៈ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ទំនាក់ទំនងអន្តរជាតិ សេវាកម្មអេឡិចត្រូនិកពន្ធដារ និងកិច្ចការទាំងឡាយរបស់អង្គភាពពន្ធដារ ដែលតែងតែមានអ្នកជាប់ពន្ធចូលទស្សនាជាប្រចាំ។ ជាក់ស្តែងក្នុងខែធ្នូ ឆ្នាំ២០២៤ មានចំនួនអ្នកចូលទស្សនា **៥៤៨ ០៩៦ ដង** និងក្នុងរយៈពេល១២ខែ ឆ្នាំ២០២៤ មាន ចំនួនអ្នកចូលទស្សនាសរុប **២ ៩៣៣ ៤៣៥ ដង**៕

## ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ពីឆ្នាំ ២០១៤ ដល់បច្ចុប្បន្ន

### ឆ្នាំ២០១៤
១.កម្មវិធីគណនាពន្ធលើមធ្យោបាយដឹកជញ្ជូន
២.ប្រព័ន្ធគ្រប់គ្រងពន្ធមធ្យោបាយដឹកជញ្ជូន
៣.ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីសហគ្រាស
៤.ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស

### ឆ្នាំ២០១៥
៥.កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស
៦.កម្មវិធីប្រតិទិនពន្ធដារ
៧.ប្រព័ន្ធសុវត្ថិភាពច្រកចេញ-ចូល
៨.ប្រព័ន្ធគ្រប់គ្រងពន្ធអចលនទ្រព្យ និងប្រថាប់ត្រា
៩.ប្រព័ន្ធគ្រប់គ្រងពាក្យស្នើសុំប្រឡងចូលបម្រើការងារ

### ឆ្នាំ២០១៦
១០.កម្មវិធីអង្កេតសហគ្រាស
១១.ប្រព័ន្ធគ្រប់គ្រងសន្និធិបង្កាន់ដៃទទួលប្រាក់ពន្ធ
១២.ប្រព័ន្ធគ្រប់គ្រងការទទួលប្រាក់ពន្ធ
១៣.ប្រព័ន្ធគ្រប់គ្រងលើការជួលអចលនទ្រព្យ

### ឆ្នាំ២០១៧
១៤.គេហទំព័របញ្ជូនរបាយការណ៍ព័ត៌មាន (FATCA)
១៥.ប្រព័ន្ធត្រួតពិនិត្យពន្ធមធ្យោបាយតាម RFID
១៦.ប្រព័ន្ធគ្រប់គ្រងកម្មវិធីប្រជុំរបស់អពដ
១៧.ប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ
១៨.ប្រព័ន្ធគ្រប់គ្រងគណនីរបស់មន្ត្រីនិងដៃគូសហការ
១៩.ប្រព័ន្ធរក្សាទុកនិងចែកចាយឯកសារផ្ទៃក្នុង
២០.ប្រព័ន្ធគ្រប់គ្រងអ៊ីម៉ែលរបស់អពដ
២១.ប្រព័ន្ធគ្រប់គ្រងសន្លឹកតែមប្រិ៍បារី
២២.ប្រព័ន្ធគ្រប់គ្រងសវនកម្មសហគ្រាស
២៣.ប្រព័ន្ធគ្រប់គ្រងមជ្ឈមណ្ឌលពិគ្រោះយោបល់
២៤.ប្រព័ន្ធគ្រប់គ្រងការបង់ពន្ធតាមអនឡាញ
២៥.កម្មវិធីត្រួតពិនិត្យតែមប្រិ៍បារី

### ឆ្នាំ២០១៨
២៦.ប្រព័ន្ធគ្រប់គ្រងព័ត៌មានសហគ្រាស
២៧.ប្រព័ន្ធគ្រប់គ្រងព័ត៌មានបុគ្គល
២៨.ប្រព័ន្ធគ្រប់គ្រងតាមដានឯកសារ
២៩.ប្រព័ន្ធតាមដានចំណូលពន្ធដារ
៣០.កម្មវិធីព័ត៌មានស្តីពីពន្ធដារ
៣១.កម្មវិធីត្រួតពិនិត្យបេក្ខជនប្រឡង
៣២.កម្មវិធីជជែកជាមួយពន្ធដារ
៣៣.កម្មវិធីអង្កេតអចលនទ្រព្យ

### ឆ្នាំ២០១៩
៣៤.ប្រព័ន្ធគ្រប់គ្រងការស្នើសុំបង្វិលសង អតប

### ឆ្នាំ២០២០
៣៥.គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ
៣៦.ប្រព័ន្ធគ្រប់គ្រងរបាយការណ៍នៃការធ្វើសារខ្ទី
៣៧.ប្រព័ន្ធបញ្ជូនឯកសារលិខិតប្រកាសរបស់អពដ
៣៨.ប្រព័ន្ធសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធអពដ និងអគរក
៣៩.ប្រព័ន្ធសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធអពដ និងដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការនិងដឹកជញ្ជូន
៤០.ប្រព័ន្ធសន្ទានកម្មទិន្នន័យចំណូលពន្ធរវាង FMIS
៤១.ប្រព័ន្ធគ្រប់គ្រងស្នើសុំការលើកទឹកចិត្តពន្ធដារ
៤២.ប្រព័ន្ធគ្រប់គ្រងការសិក្សាពន្ធដារ
៤៣.ប្រព័ន្ធគ្រប់គ្រងគណនីអ្នកជាប់ពន្ធ
៤៤.ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ
៤៥.ប្រព័ន្ធគ្រប់គ្រងសន្និធិរបស់អគ្គនាយកដ្ឋានពន្ធដារ
៤៦.ប្រព័ន្ធគ្រប់គ្រងការបៀសវាងយកពន្ធត្រួតគ្នា
៤៧.ប្រព័ន្ធគ្រប់គ្រងចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យា
៤៨.ប្រព័ន្ធគ្រប់គ្រងបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត
៤៩.កម្មវិធីការប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច
៥០.កម្មវិធីត្រួតពិនិត្យនិងតាមដានឯកសារ
៥១.កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ
៥២.កម្មវិធីគ្រប់គ្រងលិខិតរដ្ឋបាលពន្ធដារ

### ឆ្នាំ២០២១
៥៣.ប្រព័ន្ធស្វ័យប្រវត្តិកម្មផ្ទៀងផ្ទាត់ការបង់ពន្ធ
៥៤.ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ពន្ធដារ
៥៥.ប្រព័ន្ធគ្រប់គ្រងសវនកម្មអាករលើតម្លៃបន្ថែម
៥៦.ប្រព័ន្ធគាំទ្រការបង់ពន្ធមធ្យោបាយដឹកជញ្ជូន
៥៧.ប្រព័ន្ធគ្រប់គ្រងការស្នើសុំលិខិតបញ្ជាក់និងវិញ្ញាបនបត្រ
៥៨.ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធ ToI អនឡាញ
៥៩.កម្មវិធីបញ្ជូនឯកសារអេឡិចត្រូនិក
៦០.កម្មវិធីដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ
៦១.កម្មវិធីផ្ទៀងផ្ទាត់ព័ត៌មាននិងប្រគល់ឯកសារពន្ធដារ

### ឆ្នាំ២០២២
៦២.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធតែមប្រិ៍
៦៣.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធមធ្យោបាយ
៦៤.ប្រព័ន្ធគ្រប់គ្រងគណនីអ្នកប្រើប្រាស់តាមអនឡាញ
៦៥.ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម
៦៦.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធអចលនទ្រព្យ
៦៧.ប្រព័ន្ធគ្រប់គ្រងអត្រាប្តូរប្រាក់
៦៨.ប្រព័ន្ធស្នូលនៃអគ្គនាយកដ្ឋានពន្ធដារ (CoreSystem)
៦៩.ប្រព័ន្ធគ្រប់គ្រងកម្មវិធីក្លាយបត្រនាំសំណាង
៧០.ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក
៧១.ប្រព័ន្ធគ្រប់គ្រងទិន្នន័យឧបករណ៍វាស់ចំណុះស្រាបៀរនិងភេសជ្ជៈ
៧២.ប្រព័ន្ធគ្រប់គ្រងចំណាត់ថ្នាក់ (MeritandDemerit_MDS)
៧៣.កម្មវិធីក្លាយបត្រនាំសំណាង
៧៤.កម្មវិធីសទ្ទានុក្រមពន្ធដារ
៧៥.កម្មវិធីផ្ទៀងផ្ទាត់ព័ត៌មានសិស្ស (សម្រាប់ការបណ្តុះបណ្តាល)

### ឆ្នាំ២០២៣
៧៦.កម្មវិធីអនុម័តតាមប្រព័ន្ធអេឡិចត្រូនិក
៧៧.ប្រព័ន្ធគ្រប់គ្រងការអនុម័តតាមប្រព័ន្ធអេឡិចត្រូនិក (សម្រាប់មន្ត្រី)
៧៨.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធលើផ្ទាំងផ្សព្វផ្សាយ
៧៩.ប្រព័ន្ធកំណត់ផែនការចំណូលពន្ធ
៨០.កម្មវិធីលិខិតរដ្ឋបាលអេឡិចត្រូនិក
៨១.កម្មវិធីផ្ទាំងព័ត៌មានលិខិតរដ្ឋបាលអេឡិចត្រូនិក

# QR Code វីដេអូណែនាំអំពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីទាក់ទងនឹងពន្ធដារ

## កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)




**ទស្សនាតាមផ្នែក៖**

- 03:49 : សម្រាប់បុគ្គលទូទៅ
- 07:33 : សម្រាប់ភ្នាក់ងារសេវាកម្មពន្ធដារ
- 11:46 : សម្រាប់អ្នកតំណាងសហគ្រាស

សូមស្កេន QR Code

## កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)




មុខងារបង់ពន្ធលើផ្ទាំងផ្សព្វផ្សាយ

**ទស្សនាតាមផ្នែក៖**

- 00:46 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 02:03 : ការចូលប្រើប្រាស់កម្មវិធី
- 02:38 : ការបំពេញលិខិតប្រកាសពន្ធលើផ្ទាំងផ្សព្វផ្សាយ

សូមស្កេន QR Code




មុខងារបន្ថែមយានយន្តថ្មី

**ទស្សនាតាមផ្នែក៖**

- 00:26 : ការចូលប្រើប្រាស់កម្មវិធី
- 02:03 : ការបំពេញបន្ថែមយានយន្តថ្មី

សូមស្កេន QR Code




មុខងារបង់ពន្ធអចលនទ្រព្យ រហ័ស

**ទស្សនាតាមផ្នែក៖**

- 01:00 : ការចូលប្រើប្រាស់កម្មវិធី
- 02:03 : របៀបបង់ពន្ធអចលនទ្រព្យ

សូមស្កេន QR Code

## ប្រព័ន្ធបង់ប្រាក់ពន្ធតាមអនឡាញ (E-Payment)




**ទស្សនាតាមផ្នែក៖**

- 00:30 : ការចូលប្រើប្រាស់កម្មវិធី
- 00:40 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 01:40 : របៀបបង់ពន្ធតាមអនឡាញ

សូមស្កេន QR Code

# QR Code វីដេអូណែនាំអំពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីទាក់ទងនឹងពន្ធដារ

## ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ សម្រាប់អ្នកជាប់ពន្ធមធ្យម និង ធំ (e-Filing)




**ទស្សនាតាមផ្នែក៖**

- 00:50 : ការចុះឈ្មោះដើម្បីប្រើប្រាស់ប្រព័ន្ធ
- 01:54 : ការចូលប្រើប្រាស់ប្រព័ន្ធ
- 07:05 : ការប្រកាសពន្ធប្រចាំខែ

សូមស្កេន QR Code




មុខងារ (Reverse Charge)

**ទស្សនាតាមផ្នែក៖**

- 00:50 : ការចូលប្រើប្រាស់ប្រព័ន្ធ
- 01:30 : ការប្រកាសពន្ធ

សូមស្កេន QR Code

## កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)




**ទស្សនាតាមផ្នែក៖**

- 00:50 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 02:10 : ការចូលប្រើប្រាស់កម្មវិធី

សូមស្កេន QR Code



មុខងារប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

**ទស្សនាតាមផ្នែក៖**

- 00:40 : ការចូលប្រើប្រាស់កម្មវិធី
- 00:50 : ការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

សូមស្កេន QR Code

## ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce Tax System)




( Khmer Version) ( English Version)

# QR Code វីដេអូណែនាំអំពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីទាក់ទងនឹងពន្ធដារ

## កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)




**ទស្សនាតាមផ្នែក៖**

- 00:20 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 01:50 : ការចូលប្រើប្រាស់កម្មវិធី
- 02:30 : ការបញ្ចូលវិក្កយបត្រថ្មី

សូមស្កេន QR Code

## ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ



មុខងារស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

**ទស្សនាតាមផ្នែក៖**

- 01:00 : ការបង្កើតគណនីថ្មី
- 02:20 : ការចូលប្រើប្រាស់ប្រព័ន្ធ
- 02:55 : ការដាក់ពាក្យស្នើសុំនិងបោះពុម្ពវិញ្ញាបនបត្រពន្ធដារ

សូមស្កេន QR Code



មុខងារស្នើសុំការផ្អាកអាជីវកម្ម ឬបើកដំណើរការឡើងវិញ

**ទស្សនាតាមផ្នែក៖**

- 00:45 : ការស្នើសុំផ្អាកសកម្មភាពអាជីវកម្មបណ្ដោះអាសន្ន
- 02:40 : បន្តស្នើសុំផ្អាកសកម្មភាពអាជីវកម្ម
- 05:00 : ស្នើសុំបើកដំណើរការឡើងវិញ

សូមស្កេន QR Code

## កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track) ជំនាន់ថ្មី




**ទស្សនាតាមផ្នែក៖**

- 00:20 : ការប្រើប្រាស់កម្មវិធី
- 00:45 : មុខងារផ្សេងៗ

សូមស្កេន QR Code

## កម្មវិធីសទ្ទានុក្រមពន្ធដារ (Tax Glossary App)




**ទស្សនាតាមផ្នែក៖**

- 00:40 : ការប្រើប្រាស់កម្មវិធី
- 02:00 : មុខងារផ្សេងៗ

សូមស្កេន QR Code

# ផ្នែកទី៣
# បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ

១. អនុក្រឹត្យ

២. ប្រកាស

៣. សេចក្តីជូនដំណឹង

៤. សេចក្តីណែនាំ

# បច្ចុប្បន្នភាពច្បាប់
# លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ

សរុបក្នុងរយៈពេល ១២ខែឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងកែលម្អគោលនយោបាយសារពើពន្ធ តាមរយៈការដាក់ចេញឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារ ដូចមានក្នុងតារាងនិងអត្ថបទខាងក្រោម៖

**បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ រយៈពេល ១២ខែឆ្នាំ២០២៤**

| បរិយាយ | រយៈពេល៩ខែ | ខែតុលា | ខែវិច្ឆិកា | ខែធ្នូ | សរុបរួម |
|---|---|---|---|---|---|
| ច្បាប់ | ០០ | ០០ | ០០ | ០០ | ០០ |
| អនុក្រឹត្យ | ០៥ | ០០ | ០១ | ០០ | ០៦ |
| ប្រកាស | ១៦ | ០៣ | ០០ | ០២ | ២១ |
| សារាចរណែនាំ | ០០ | ០០ | ០០ | ០០ | ០០ |
| សេចក្តីជូនដំណឹង | ០៩ | ០១ | ០១ | ០៤ | ១៥ |
| សេចក្តីណែនាំ | ០៨ | ០២ | ០០ | ០១ | ១១ |
| សេចក្តីសម្រេច | ០០ | ០០ | ០០ | ០០ | ០០ |
| **សរុបរួម** | ៣៨ | ០៦ | ០២ | ០៧ | ៥៣ |

## ១.អនុក្រឹត្យ

### អនុក្រឹត្យ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ២៧២ អនក្រ.បក ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ អនុក្រឹត្យនេះ មានគោលបំណងផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធចំពោះសហគ្រាសស្ថិតក្នុងវិស័យអាទិភាព និងជាសហគ្រាសធុនតូច និងមធ្យម ដែលចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ហើយប្រកបអាជីវកម្មរួមមាន លក់ដុំ លក់រាយ ជួសជុល សេវាកម្មស្នាក់នៅនិងអាហារ សិប្បកម្ម និងសហគមន៍កសិកម្ម។ សហគ្រាសធុនតូច និងសហគ្រាសធុនមធ្យមទាំងនោះ ត្រូវទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារ ដូចខាងក្រោម៖

១. ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០២៤-២០២៨ សម្រាប់សហគ្រាសធុនតូច ត្រូវបានលើកលែងពិន័យទោសទណ្ឌ និងបំណុលពន្ធចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជី លើកលែងកម្រៃសេវាចុះបញ្ជីពន្ធដារនិងកម្រៃសេវាធ្វើបច្ចុប្បន្នភាពព័ត៌មាន និងលើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា សម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជី។

២. ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០២៤-២០២៥ សម្រាប់សហគ្រាសធុនមធ្យម ត្រូវបានលើកលែងពិន័យទោសទណ្ឌ និងបំណុលពន្ធចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជី និងលើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា សម្រាប់រយៈពេល ២ឆ្នាំ ក្រោយការចុះបញ្ជី។

៣.ចំពោះការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ ២០២៤-២០២៥ សម្រាប់សហគ្រាសធុនតូច និងមធ្យម ត្រូវបានលើកលែងការបង់ពន្ធប៉ាតង់ សម្រាប់រយៈពេល ២ឆ្នាំ បន្ទាប់ពីទទួលបានការសម្រេចឱ្យចុះបញ្ជី៕

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

# ២.ប្រកាស

## ប្រកាស ស្តីពីការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាប

នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៦២៦ សហវ.ប្រក ស្តីពីការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាប។ ប្រកាសនេះ មានគោលបំណងផ្តល់ការលើកទឹកចិត្តពន្ធដារដល់សហគ្រាសក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាប ស្របតាមវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដើម្បីជួយស្តារវិស័យទេសចរណ៍ឱ្យបានល្អប្រសើរឡើងវិញ។ ចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍ រួមមាន សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងក្រុមហ៊ុនភ្នាក់ងារទេសចរណ៍ ដែលស្ថិតនៅខេត្តសៀមរាប ត្រូវទទួលបានការលើកទឹកចិត្តពន្ធដារដូចខាងក្រោម៖

១. លើកលែងការបង់ពន្ធអាករប្រចាំខែគ្រប់ប្រភេទ វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករលើការស្នាក់នៅ គិតចាប់ពីខែកក្កដា ឆ្នាំ២០២៤ រហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៥។

២. លើកលែងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២៤។ ចំពោះប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលសហគ្រាសបានបង់រួចនឹងត្រូវបានអនុញ្ញាតជាឥណទានពន្ធសម្រាប់កាត់កងជាមួយពន្ធលើប្រាក់ចំណូប្រចាំឆ្នាំ២០២៥។

៣. មិនទទួលរងការធ្វើសវនកម្មពន្ធដារ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៤៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីការកែសម្រួលប្រការ៣ នៃប្រកាសលេខ ០៧១ សហវ.ប្រក.អពដ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត

នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៦២៥ សហវ.ប្រក ស្តីពីការកែសម្រួលប្រការ៣ នៃប្រកាសលេខ ០៧១ សហវ.ប្រក.អពដ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តចំពោះការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត។ ការចេញប្រកាសនេះ គឺដើម្បីធ្វើការកែសម្រួលប្រការ៣ នៃប្រកាសលេខ ០៧១ សហវ.ប្រក.អពដ ដោយអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដែលស្នើសុំធ្វើការកែតម្រូវបញ្ជីគណនេយ្យ និងលិខិតប្រកាសពន្ធឡើងវិញដោយស្ម័គ្រចិត្ត ត្រូវទទួលបានការលើកលែងទណ្ឌកម្មរដ្ឋបាល រួមមាន ពន្ធបន្ថែមការប្រាក់ និងការផាកពិន័យជាប្រាក់ទាំងស្រុង ដោយទុករយៈពេលរហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០២៥៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន

នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៧៣៨ សហវ. ប្រក.អពដ ស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន។ ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន ដែលមានចែងអំពីការកំណត់កម្រិតប្រាក់ពន្ធ ការលើកលែងពន្ធ និងបែបបទនីតិវិធីនៃការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីការណែនាំអនុវត្តអនុក្រឹត្យ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

នាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៨១០ សហវ.ប្រក.អពជ ស្តីពីការណែនាំអនុវត្តអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ប្រកាសនេះមានគោលបំណងផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធចំពោះសហគ្រាសស្ថិតក្នុងវិស័យអាទិភាព និងជាសហគ្រាសធុនតូចនិងមធ្យម ដែលចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ហើយប្រកបអាជីវកម្មរួមមាន លក់ដុំ លក់រាយ ជួសជុល សេវាកម្មស្នាក់នៅនិងអាហារ សិប្បកម្ម និងសហគមន៍កសិកម្ម។ ក្នុងប្រកាសនេះផងដែរក៏មានចែងលម្អិតអំពីវិសាលភាព គោលដៅ ការលើកទឹកចិត្តផ្នែកពន្ធដារ លក្ខខណ្ឌទទួលបានការលើកទឹកចិត្ត និងការបំពេញកាតព្វកិច្ចចំពោះសហគ្រាសធុនតូចនិងមធ្យម ដែលទទួលបានការលើកទឹកចិត្តផ្នែកពន្ធដារនេះ៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ប្រកាស ស្តីពីការលើកលែងអាករពិសេស លើផលិតផលស៊ីម៉ងត៍ក្នុងស្រុកដោយចាត់ទុកជាបន្ទុករបស់រដ្ឋ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១០០០ សហវ.ប្រក.អពជ ស្តីពីការលើកលែងអាករពិសេសលើផលិតផលស៊ីម៉ងត៍ក្នុងស្រុកដោយចាត់ទុកជាបន្ទុករបស់រដ្ឋ។ ប្រកាសនេះ មានគោលបំណងលើកលែងអាករពិសេសលើផលិតផលស៊ីម៉ងត៍ក្នុងស្រុកដោយចាត់ទុកជាបន្ទុករបស់រដ្ឋ ដើម្បីចូលរួមគាំទ្រដល់ឧស្សាហកម្មផលិតស៊ីម៉ងត៍ក្នុងស្រុក ដែលមានអត្រា ៥ % សម្រាប់រយៈពេល ២ឆ្នាំ ចាប់ពីឆ្នាំ២០២៥ រហូតដល់ដំណាច់ឆ្នាំ២០២៦។ សហគ្រាសផលិតស៊ីម៉ងត៍ក្នុងស្រុកទាំងអស់ត្រូវអនុវត្តនូវកាតព្វកិច្ច ដូចខាងក្រោម៖

១. ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែនិងប្រចាំឆ្នាំ រួមទាំងពន្ធអាករដែលត្រូវបានចាត់ទុកជាបន្ទុករបស់រដ្ឋដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធតាមអនឡាញ (e-Filing)។

២. ត្រូវកាន់ កត់ត្រា និងថែរក្សាឯកសារបញ្ជិកាគណនេយ្យនិងព័ត៌មានដែលមានទាក់ទិននឹងសកម្មភាពអាជីវកម្មស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

៣. ត្រូវខិតខំបង្កើនការបណ្តុះបណ្តាល និងផ្ទេរចំណេះដឹងនិងបច្ចេកទេសទៅបុគ្គលិកក្នុងស្រុកឱ្យបានកាន់តែច្រើន និងល្អប្រសើរ ដើម្បីចូលរួមចំណែកអភិវឌ្ឍធនធានមនុស្ស។

៤. ត្រូវបំពេញកាតព្វកិច្ចចំពោះរដ្ឋឱ្យបានត្រឹមត្រូវ ដូចជា ការបង់ពន្ធអាករផ្សេងទៀត សួយសារអ៊ែ និងមូលនិធិបរិស្ថាននិងសង្គម ជាដើម។

៥. ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងថ្លៃដើម សមត្ថភាពផលិត ការប្រើប្រាស់វត្ថុធាតុដើម ការបណ្តុះបណ្តាល និងការផ្ទេរចំណេះដឹងនិងបច្ចេកទេសទៅបុគ្គលិកក្នុងស្រុក និងការចូលរួមកិច្ចការសង្គម៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

# ៣.សេចក្ដីជូនដំណឹង

## សេចក្ដីជូនដំណឹង ស្ដីពីការបន្ត និងបន្ថែមការលើកទឹកចិត្តពន្ធដារ ចំពោះវិស័យអចលនទ្រព្យ

នាថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្ដីជូនដំណឹងលេខ ០១៤ សហវ.ស.ជ.ណ ស្ដីពីការបន្ត និងបន្ថែមការលើកទឹកចិត្តពន្ធដារ ចំពោះវិស័យអចលនទ្រព្យ។ ក្នុងគោលដៅ ដើម្បីកាត់បន្ថយបន្ទុកចំណាយបង់ពន្ធដល់ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋាន និងប្រជាពលរដ្ឋជាម្ចាស់អចលនទ្រព្យ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់អចលនទ្រព្យ និងសាធារណជន អំពីការបន្តអនុវត្ត និងបន្ថែមគោលការណ៍លើកទឹកចិត្តពន្ធដារ ចំពោះវិស័យអចលនទ្រព្យ រួមមាន៖

- ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ
- ពន្ធលើចំណេញមូលធន
- ពន្ធលើអចលនទ្រព្យ
- ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## សេចក្ដីជូនដំណឹង ស្ដីពីការរំលឹកការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៤

នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្ដីជូនដំណឹងលេខ ៣៩៨០៩ អពដ ស្ដីពីការរំលឹកការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៤។ ការចេញសេចក្ដីជូនដំណឹងនេះ គឺដើម្បីក្រើនរំលឹកដល់ម្ចាស់យានយន្តទាំងអស់ដែលមិនទាន់បានបំពេញកាតព្វកិច្ចបង់ពន្ធ សូមរួសរាន់មកបង់ពន្ធឱ្យបានទាន់ពេលវេលាត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ ឬនៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅធនាគារពាណិជ្ជដៃគូដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ម្ចាស់យានយន្តក៏អាចបង់តាមរយៈកម្មវិធី GDT Taxpayer App ដែលអាចទាញយកចេញពី App Store ចំពោះ iOS ឬ Play Store ចំពោះ Android សម្រាប់យានយន្តដែលធ្លាប់បានប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនកន្លងមក។

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## សេចក្ដីជូនដំណឹង ស្ដីពីការលុបចោលអាជ្ញាប័ណ្ណ ភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន អេស.អេស.ភី.អេ សុភិន សឺវីស ប្រាយវេត អេជេន ឯ.ក

នាថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្ដីជូនដំណឹងលេខ ៤០៦៦០ អពដ ស្ដីពីការលុបចោលអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន អេស.អេស.ភី.អេ សុភិន សឺវីស ប្រាយវេត អេជេន ឯ.ក។ ការចេញសេចក្ដីជូនដំណឹងនេះ គឺដើម្បីជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ ឬសាធារណជនទូទៅទាំងអស់ ឱ្យបានជ្រាបថា ក្រុមហ៊ុននេះ ត្រូវបានលុបអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ និងត្រូវបានបាត់បង់នីតិសម្បទាជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលមិនអាចផ្ដល់សេវាពាក់ព័ន្ធនឹងពន្ធដារជូនអតិថិជន ឬជូនអ្នកជាប់ពន្ធទៀតទេ គិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតជូនដំណឹងនេះតទៅ។ ក្នុងន័យនេះ អ្នកជាប់ពន្ធ ឬសាធារណជនទូទៅដែលកំពុង ឬមានបំណងប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារពីក្រុមហ៊ុនខាងលើ ត្រូវផ្អាកឬកុំប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងក្រុមហ៊ុននេះ ដើម្បីចៀសវាងទទួលរងនូវការផាកពិន័យ និងទណ្ឌកម្មផ្សេងៗ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារជាធរមាន។

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## សេចក្ដីជូនដំណឹង ស្ដីពីការលុបចោលអាជ្ញាប័ណ្ណ ភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន ជុំពេជ្រ ខនសាល់ធីង ឯ.ក

នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្ដីជូនដំណឹងលេខ ៤២១១២ អពដ ស្ដីពីការលុបចោលអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន ជុំពេជ្រ ខនសាល់ធីង ឯ.ក។ ការចេញសេចក្ដីជូនដំណឹងនេះ គឺដើម្បីជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ ឬសាធារណជនទូទៅទាំងអស់ ឱ្យបានជ្រាបថា ក្រុមហ៊ុននេះ ត្រូវបានលុបអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ និងត្រូវបានបាត់បង់នីតិសម្បទាជាភ្នាក់ងារសេវាកម្មពន្ធដារដែលមិនអាចផ្ដល់សេវាពាក់ព័ន្ធនឹងពន្ធដារជូនអតិថិជន ឬជូនអ្នកជាប់ពន្ធទៀតទេ គិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតជូនដំណឹងនេះតទៅ។ ក្នុងន័យនេះ អ្នកជាប់ពន្ធ ឬសាធារណជនទូទៅដែលកំពុង ឬមានបំណងប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារពីក្រុមហ៊ុនខាងលើ ត្រូវផ្អាកឬកុំប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងក្រុមហ៊ុននេះ ដើម្បីចៀសវាងទទួលរងនូវការផាកពិន័យនិងទណ្ឌកម្មផ្សេងៗ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារជាធរមាន៕

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

## សេចក្ដីជូនដំណឹង ស្ដីពីការលើកលែងនិងអនុគ្រោះពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ សម្រាប់អ្នកទិញលំនៅឋាន និង/ឬ ផ្ទេរកម្មសិទ្ធិជាលើកដំបូង (First-Time Home Buyer) ដែលត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្ដីជូនដំណឹងលេខ ០២០ សហវ.ស.ជ.ណ ស្ដីពីការលើកលែងនិងអនុគ្រោះពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ សម្រាប់អ្នកទិញលំនៅឋាន និង/ឬ ផ្ទេរកម្មសិទ្ធិជាលើកដំបូង (First-Time Home Buyer) ដែលត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។ ក្នុងគោលដៅជួយសម្រួលដល់ប្រជាពលរដ្ឋដែលបានទិញលំនៅឋានពីក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋានដែលមានលក្ខណៈជាបុរី ឬអគារសហកម្មសិទ្ធិ (ខុនដូ) និងជួយដល់វិស័យអចលនទ្រព្យបន្ថែមទៀត។ នៅក្នុងសេចក្ដីជូនដំណឹងនេះដែរ បានជូនដំណឹងដល់ម្ចាស់អចលនទ្រព្យ និងសាធារណជន និងពន្យល់លម្អិតអំពីការលើកលែងនិងអនុគ្រោះពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យសម្រាប់អ្នកទិញលំនៅឋាន និង/ឬផ្ទេរកម្មសិទ្ធិជាលើកដំបូង (First-Time Home Buyer)៕

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

## សេចក្តីជូនដំណឹង
## ស្តីពីការលុបចោលអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ
## របស់ក្រុមហ៊ុន ស្កាយលីមីធីត អ៊ីខោនធីង (ខេមបូឌា) ខូ អិលធីឌី

នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ៤៣៥៥៦ អពដ ស្តីពីការលុបចោលអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដាររបស់ក្រុមហ៊ុន ស្កាយលីមីធីត អ៊ីខោនធីង (ខេមបូឌា) ខូ អិលធីឌី។ ការចេញសេចក្តីជូនដំណឹងនេះ គឺដើម្បីជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ ឬសាធារណជនទូទៅទាំងអស់ឱ្យបានជ្រាបថា ក្រុមហ៊ុននេះ ត្រូវបានលុបអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ និងត្រូវបានបាត់បង់នីតិសម្បទាជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលមិនអាចផ្តល់សេវាពាក់ព័ន្ធនឹងពន្ធដារជូនអតិថិជន ឬជូនអ្នកជាប់ពន្ធទៀតទេ គិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតជូនដំណឹងនេះតទៅ។ ក្នុងន័យនេះ អ្នកជាប់ពន្ធ ឬសាធារណជនទូទៅដែលកំពុង ឬមានបំណងប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារពីក្រុមហ៊ុនខាងលើ ត្រូវផ្អាកឬកុំប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងក្រុមហ៊ុននេះ ដើម្បីចៀសវាងទទួលរងនូវការផាកពិន័យ និងទណ្ឌកម្មផ្សេងៗ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន៕

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

# ៤.សេចក្តីណែនាំ

## សេចក្តីណែនាំ
## ស្តីពីសហគ្រាសស្ថិតនៅក្រោមការធ្វើសវនកម្មរបស់អង្គភាពសវនកម្មពន្ធដារពិសេស

នាថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីណែនាំលេខ ០២៤ សហវ.ស.ណ.ន ស្តីពីសហគ្រាសស្ថិតនៅក្រោមការធ្វើសវនកម្មរបស់អង្គភាពសវនកម្មពន្ធដារពិសេស។ ការចេញសេចក្តីណែនាំនេះ គឺដើម្បីធ្វើការណែនាំស្តីពីការអនុវត្តការជ្រើសរើសសហគ្រាសឱ្យស្ថិតនៅក្រោមការធ្វើសវនកម្មរបស់អង្គភាពសវនកម្មពន្ធដារពិសេស (អសពព) ត្រូវជាសហគ្រាសដែលទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទមាស ពីអគ្គនាយកដ្ឋានពន្ធដារ និងសហគ្រាសផ្សេងទៀតដែលត្រូវបានសម្រេចដោយអគ្គនាយកដ្ឋានពន្ធដារ ឬថ្នាក់ ដឹកនាំ។ ក្នុងសេចក្តីណែនាំនេះ ក៏បានណែនាំអំពីកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធ ការទទួលសេវាដទៃទៀត និងការធ្វើសវនកម្មពន្ធដារចំពោះសហគ្រាសដែលស្ថិតក្រោម អសពព ព្រមទាំងកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីឱ្យ អសពព ដំណើរការបានរលូន និងមានប្រសិទ្ធភាព៕

ដើម្បីទទួលបានឯកសារ
ឬអានលម្អិត សូមស្កេន QR Code

## សេចក្តីណែនាំ ស្តីពីកាតព្វកិច្ចបង់ពន្ធអាករចំពោះការផ្គត់ផ្គង់
## ទំនិញដោយមានថែមទំនិញ ឬផ្តល់ជារង្វាន់របស់សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុក

នាថ្ងៃទី១០ខែតុលា ឆ្នាំ២០២៤ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីណែនាំលេខ ០២៥ សហវ.ស.ណ.ន ស្តីពីកាតព្វកិច្ចបង់ពន្ធអាករចំពោះការផ្គត់ផ្គង់ទំនិញដោយមានថែមទំនិញ ឬផ្តល់ជារង្វាន់របស់សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុក។ ការចេញសេចក្តីណែនាំនេះ គឺដើម្បីឱ្យមានភាពច្បាស់លាស់ក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ និងក្នុងគោលបំណងពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធអាករ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងស័ក្តិសិទ្ធិភាព ចំពោះការផ្គត់ផ្គង់ទំនិញដោយមានថែមទំនិញ ឬផ្តល់ជារង្វាន់របស់សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុក ដែលបានកំណត់ពីចំណុចសំខាន់ៗ រួមមាន៖

- ការថែមទំនិញឬផ្តល់ជារង្វាន់នូវទំនិញជាស្តុកសម្រាប់លក់
- ការថែមទំនិញឬផ្តល់ជារង្វាន់នូវទំនិញដែលមិនមែនជាស្តុកសម្រាប់លក់ ឬរង្វាន់ផ្សេងៗក្រៅពីទំនិញ
- ការអនុញ្ញាតជាចំណាយ
- កាតព្វកិច្ចដទៃទៀតរបស់សហគ្រាស
- និងឧបសម្ព័ន្ធភ្ជាប់ ជាឧទាហរណ៍នៃការផ្គត់ផ្គង់ទំនិញ ឬផ្តល់ជារង្វាន់របស់សហគ្រាសផ្គត់ផ្គង់ទំនិញក្នុងស្រុក៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## សេចក្តីណែនាំ ស្តីពីការប្រើប្រាស់គណនីធនាគារ ជាប្រាក់រៀលសម្រាប់ការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម

នាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញសេចក្តីណែនាំលេខ ០៣០ សហវ.ស.ណ.ន ស្តីពីការប្រើប្រាស់គណនីធនាគារជាប្រាក់រៀល សម្រាប់ការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម។ ក្នុងគោលបំណង លើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិឱ្យកាន់តែប្រសើរឡើង និងដើម្បីធ្វើឱ្យការទូទាត់ថវិកាបង្វិលសងអាករលើតម្លៃបន្ថែមកាន់តែឆាប់រហ័ស ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។ សេចក្តីណែនាំនេះ ធ្វើការណែនាំដល់អ្នកជាប់ពន្ធធំ និងអ្នកជាប់ពន្ធមធ្យម រួមទាំងបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត សម្រាប់ការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ដូចខាងក្រោម៖

១. ត្រូវមានគណនីធនាគារជាប្រាក់រៀល ដែលបានបញ្ចូលនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ សម្រាប់ទទួលការទូទាត់ថវិកាបង្វិលសងអាករលើតម្លៃបន្ថែម។

២. ក្នុងករណីពុំទាន់មានគណនីធនាគារជាប្រាក់រៀល ត្រូវបើកបន្ថែមគណនីធនាគារជាប្រាក់រៀល និងត្រូវមកធ្វើបច្ចុប្បន្នភាពព័ត៌មានគណនីធនាគារ នៅអគ្គនាយកដ្ឋានពន្ធដារ៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code



សូមស្កេនដើម្បីចូលទៅកាន់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ

# ផ្នែកទី៤
# កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ

១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ

២. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ

៣. កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA)

# ១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ

## កម្មវិធីប្រគល់វិញ្ញាបនបត្រវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" (CIFRS FOR SMEs)



នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៣១ ខែតុលា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ និងនិយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកម្មវិធីប្រគល់វិញ្ញាបនបត្រវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" ក្រោមអធិបតីភាពលោកស្រី **នាន មូនី** អគ្គនាយករង នៃនិយ័តករគណនេយ្យនិងសវនកម្ម ជាតំណាងឯកឧត្តម **ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និងលោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ជាតំណាងឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការចូលរួមពីលោក **សាយ សុខខេង** អគ្គនាយក នៃក្រុមហ៊ុន DFC និងសិក្ខាកាមជាមន្ត្រីរាជការពន្ធដារដែលបានប្រឡងជាប់ជាស្ថាពរចំនួន **៨៩ រូប**។

បន្ទាប់ពី លោក **សាយ សុខខេង** អគ្គនាយក នៃក្រុមហ៊ុន DFC បានមានមតិស្វាគមន៍ជូនអង្គពិធីរួចមក លោក **ជ័យ រិទ្ធី** បានឡើងមានមតិស្វាគមន៍យ៉ាងកក់ក្តៅ និងបានថ្លែងអំណរគុណដល់ ឯកឧត្តមអគ្គនាយក លោកស្រីអគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងអគ្គនាយកក្រុមហ៊ុន DFC និងសហការីទាំងអស់ ព្រមទាំងបានសម្តែងនូវមូលវិចារណ៍ដ៏ថ្លៃថ្លាចំពោះសហការី នៃអគ្គនាយកដ្ឋានពន្ធដារ ដែលបានដឹកនាំសម្របសម្រួលការងារផ្តល់កិច្ចសហការជិតស្និទ្ធ ញុំាងឱ្យមានលទ្ធផលល្អជាផ្លែផ្កា។ ឆ្លៀតក្នុងឱកាសដ៏សែនមនោរម្យនេះផងដែរ លោកបានសម្តែងនូវការអបអរសាទរយ៉ាងក្លៀវក្លាចំពោះលោក-លោកស្រី នាងកញ្ញា ជាមន្ត្រីពន្ធដារទាំងអស់ ដែលបានខិតខំសិក្សា រៀនសូត្ររហូតសម្រេចបានលទ្ធផល ជោគជ័យជាទីមោទនៈ។ លោកបានបញ្ជាក់បន្ថែមទៀតថា របាយការណ៍ហិរញ្ញវត្ថុ គឺមានសារៈសំខាន់ណាស់សម្រាប់អ្នកប្រើប្រាស់ ដូចជា ម្ចាស់ភាគហ៊ុន ម្ចាស់បំណុល និយោជិត សាធារណជនរួមទាំងមន្ត្រីពន្ធដារខ្លួនឯងផង។ របាយការណ៍ហិរញ្ញវត្ថុ ក៏មានសារៈប្រយោជន៍ក្នុងការផ្តល់នូវតម្លាភាពព័ត៌មានសម្រាប់អ្នកសម្រេចចិត្ត ព័ត៌មានសម្រាប់តាមដានការអនុវត្តការងារ និងជាគោលដៅនៃការបង់ពន្ធថែមទៀតផង។ ចំណេះដឹងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យមនេះ គឺមានភាពប្រទាក់ក្រឡាគ្នាទៅនឹងការអនុវត្តច្បាប់ស្តីពីសារពើពន្ធ ជាក់ស្តែងដូចជា ការកត់ត្រាចំណូល ចំណាយ ប្រាក់ចំណេញនិយ័តកម្ម ការកាន់បញ្ជិកាគណនេយ្យ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ លើសពីនេះ របាយការណ៍ហិរញ្ញវត្ថុគឺជាប្រភពទិន្នន័យដ៏មានសក្តានុពលមួយដែលអាចយកទៅវិភាគ សម្រាប់ក្តាប់ឱ្យជាប់នូវស្ថានភាពអាជីវកម្ម កិច្ចដំណើរការពាក់ព័ន្ធរបស់ក្រុមហ៊ុន ឬអង្គភាព ដើម្បីមានវិធានការទាន់ពេលវេលា ឬសម្រាប់រាជរដ្ឋាភិបាលប្រើប្រាស់ដើម្បី

រៀបចំគោលនយោបាយពាក់ព័ន្ធ។ លោកសង្ឃឹមនិងជឿជាក់ថា សិក្ខាកាម ដែលទទួលបានជោគជ័យពីវគ្គបណ្តុះបណ្តាល នេះ នឹងយកពុទ្ធិ ជាចំណេះដឹង ចំណេះធ្វើ និងបទពិសោធដែលទទួលបានទាំងនេះ ធ្វើជាដើមទុនបន្ថែម និងមធ្យោបាយក្នុងការបំពេញការងារប្រចាំថ្ងៃប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដើម្បីបង្កើនផលិតភាពការងារ ទាំងកិច្ចការផ្ទាល់ខ្លួន និងទាំងកិច្ចការអង្គភាព។ បន្ថែមពីនេះទៅទៀត អាចយកពុទ្ធិនេះទៅធ្វើការផ្សព្វផ្សាយ ឬបណ្តុះបណ្តាលបន្តក្នុងក្របខ័ណ្ឌនៃការផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែល្អប្រសើរប្រកបដោយក្រមសីលធម៌ និងវិជ្ជាជីវៈខ្ពស់ ស្របតាមអភិក្រមការងារទាំង៤ របស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** រួមមាន៖ ១.អនុវត្តការងារប្រកបដោយវិជ្ជាជីវៈនិងគោរពក្រមសីលធម៌វិជ្ជាជីវៈ ២.ការអនុវត្តការងារជាក្រុម ៣.ការអនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និងគោលការណ៍ប្រសិទ្ធភាពថវិកា ៤.ការមិនត្រូវមើលរំលងកំហុសខ្លួនឯង។ ដូច្នេះ មន្ត្រីពន្ធដារគ្រប់រូប ដែលបានប្រឡងជាប់ក្នុងវគ្គបណ្តុះបណ្តាលនេះ ត្រូវខិតខំស្វែងយល់ និងបន្តពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែមទៀត ដើម្បីរួមចំណែកជាមួយអគ្គនាយកដ្ឋានពន្ធដារ ក្នុងការប្រមូលចំណូលពន្ធ ក៏ដូចជាការរួមចំណែកជួយអភិវឌ្ឍប្រទេសជាតិយើងស្របតាមប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា៖ "ធនធានមនុស្សប្រកបដោយមូលធនមនុស្សខ្ពស់ គឺជាកត្តាគន្លឹះសម្រាប់គ្រប់ដំណើរការនៃការអភិវឌ្ឍ"**។ អគ្គនាយក-ដ្ឋានពន្ធដារ ក្រោមការដឹកនាំដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី តែងតែយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពមន្ត្រីជាប្រចាំ។ គិតត្រឹមខែមករា ដល់ខែកញ្ញា ឆ្នាំ២០២៤ នេះ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីពន្ធដារបានចំនួន **២៣១ វគ្គ** ដែលមានមន្ត្រីចូលរួមសរុប **៣២ ៥៨៨ រូប**។ ការពង្រឹងស្ថាប័ន និងអភិបាលកិច្ចល្អ បានដើរតួយ៉ាងសំខាន់ក្នុងការកសាងសង្គមជាតិកម្ពុជាទំនើប តាមគន្លងនយោបាយស្នូលនៃ «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**» គឺការពង្រឹងអភិបាលកិច្ច ក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ លទ្ធផលជាក់ស្តែង អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងអភិវឌ្ឍសមត្ថភាពមន្ត្រីពន្ធដារបានល្អ ដោយស្តែងចេញតាមរយៈការចូលរួមអនុវត្តកម្មវិធីកំណែទម្រង់វិស័យពន្ធដារកម្ពុជា សម្រេចបានជោគជ័យ ទាំងការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាជូនអ្នកជាប់ពន្ធ តាមរយៈការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ទាំងការពង្រឹងបាននូវអភិបាលកិច្ច និងទាំងការសម្រេចបាននូវកំណើនចំណូលពន្ធដារខ្ពស់មិនធ្លាប់មាន។

ជាកិច្ចបន្ទាប់ លោកស្រី **នាន បូនី** អគ្គនាយករង នៃនិយ័តករគណនេយ្យនិងសវនកម្ម បានមានមតិស្វាគមន៍ និងថ្លែងសុន្ទរកថា បើកកម្មវិធីប្រគល់វិញ្ញាបនបត្រជូនសិក្ខាកាម ដែលជាមន្ត្រីរាជការពន្ធដារ ដោយបានវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់សិក្ខាកាមទាំងអស់ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលដ៏មានសារៈសំខាន់មួយនេះ ដែលឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅអំពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម។ ទន្ទឹមនឹងនេះ លោកស្រីអគ្គនាយករង ក៏បានថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះអគ្គនាយកដ្ឋានពន្ធដារ ក្រុមការងារនិយ័តករគណនេយ្យនិងសវនកម្ម និងក្រុមហ៊ុន DFC ដែលបានសហការគ្នារៀបចំវគ្គបណ្តុះបណ្តាលនេះឡើងដោយជោគជ័យ។ ជារៀងរាល់ឆ្នាំ និយ័តករគណនេយ្យនិងសវនកម្ម តែងតែរៀបចំវគ្គបណ្តុះបណ្តាលនេះ ជូនដល់សាធារណជន។ សម្រាប់ឆ្នាំ២០២៤នេះ និយ័តករគណនេយ្យនិងសវនកម្ម បានបន្តបេសកកម្មផ្សព្វផ្សាយនិងបណ្តុះបណ្តាលជូនវិនិយោគិន ធុរជន និងតំណាងសហគ្រាស ដែលជាបេសកកម្មរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាងមូលធនមនុស្សប្រកបដោយគុណវុឌ្ឍិខ្ពស់ស្របតាមផែនការ និងការណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយអនុលោមតាមគោលដៅនិងវិធានការរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងឧត្តុង្គឧត្តមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**៕

## ការចូលរួមវគ្គសិក្សារយៈពេលខ្លី ស្តីពី "Emerging Leader Program" នៅ University of New South Wales (UNSW)




នាថ្ងៃទី១២ដល់១៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ថ្នាក់ដឹកនាំនៃនាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក ចំនួន **៣ រូប** ដែលដឹកនាំដោយលោក **ហ៊ឹម ម៉ុនធឿន** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក និងមានការចូលរួមដោយ លោក **ឆាយ វង្ហោ** អនុប្រធាននាយកដ្ឋាន និងលោក **ពៅ បូណា** ប្រធានការិយាល័យបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ធនធានមនុស្ស នៃនាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម **គន់ ទិព្វរុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ឱ្យចូលរួមវគ្គសិក្សារយៈពេលខ្លីស្តីពី "Emerging Leader Program" ដែលរៀបចំដោយ Australian Graduate School of Management (AGSM) របស់ University of New South Wales (UNSW) ក្នុងរយៈពេល ៤ថ្ងៃ នៅទីក្រុងស៊ីដនី នៃប្រទេសអូស្ត្រាលី។ ការផ្តល់ឱកាសឱ្យចូលរួមវគ្គសិក្សានេះ គឺជាគំនិតផ្តួចផ្តើមប្រកបដោយទស្សនវិស័យដ៏វែងឆ្ងាយក្នុងការវិនិយោគលើការអភិវឌ្ឍ និងបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ។ គោលបំណងនៃការចូលរួមវគ្គសិក្សារយៈពេលខ្លីនេះ គឺដើម្បីទទួលបានចំណេះដឹង បទពិសោធ និងឧត្តមានុវត្តន៍អន្តរជាតិថ្មីៗ (International Best Practices) នៃកម្មវិធីបណ្តុះបណ្តាលស្តីពីជំនាញភាពជាអ្នកដឹកនាំ សម្រាប់ការចែករំលែកចំណេះដឹង និងប្រើប្រាស់ជាធាតុចូលក្នុងការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីរាជការពន្ធដារពាក់ព័ន្ធនឹងការងារដឹកនាំនិងគ្រប់គ្រងទៅតាមអង្គភាពពន្ធដារ។ វគ្គសិក្សានេះ គឺជាជំនាញចាំបាច់សម្រាប់មន្ត្រីរាជការពន្ធដារ ដែលមានតួនាទីជាអ្នកគ្រប់គ្រងកម្រិតថ្នាក់កណ្តាល ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យា និងនិន្នាការវិវត្តនៃសង្គម-សេដ្ឋកិច្ច ក្នុងការចូលរួមនិងគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ ២០២៤-២០២៨ និងយុទ្ធសាស្ត្រនានាដែលដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាលកម្ពុជា។

ក្នុងអំឡុងពេល ៤ថ្ងៃនេះ វគ្គសិក្សាបានផ្តល់នូវវិធីសាស្ត្រ និងបទពិសោធផ្តោតលើការផ្លាស់ប្តូរតួនាទីពីអ្នកចូលរួមចំណែកទៅជាអ្នកដឹកនាំ ដោយអភិវឌ្ឍជំនាញភាពជាអ្នកដឹកនាំជាមូលដ្ឋាន។ អ្នកចូលរួមបានរៀនពីរបៀបនៃការគ្រប់គ្រងការធ្វើឱ្យមានតុល្យភាពរវាងការងារនិងការរស់នៅ និងការអនុវត្តវិធីសាស្ត្រនៃភាពវៃឆ្លាតផ្នែកអារម្មណ៍ ដើម្បីជំរុញកិច្ចសហការនិងពង្រឹងទំនួលខុសត្រូវ។ វគ្គសិក្សានេះ បានប្រព្រឹត្តទៅដោយមានបទបង្ហាញដោយអ្នកជំនាញអំពីគោលគំនិតសំខាន់ៗ វគ្គចែករំលែកបទពិសោធ និងវគ្គបង្វឹកហាត់ក្នុងការជ្រើសយកវិធីសាស្ត្រមកដោះស្រាយបញ្ហា

ការងារ ព្រមទាំងមានការងារជាក្រុមផ្អែកលើឧទាហរណ៍និងករណីសិក្សាជាក់ស្តែង ដើម្បីឱ្យអ្នកចូលរួមមានសមត្ថភាពក្នុងការយកយុទ្ធសាស្ត្ររបស់អង្គភាពទៅបំបែកជាគោលបំណងការងារសម្រាប់ក្រុម និងបុគ្គលម្នាក់ៗ និងជាពិសេសការអនុវត្តប្រព័ន្ធគ្រប់គ្រងលទ្ធផលការងារ ដើម្បីលើកកម្ពស់ការចូលរួម និងសម្រេចបានជោគជ័យ។ ការចូលរួមវគ្គសិក្សានេះបានអភិវឌ្ឍភាពជាអ្នកដឹកនាំ ដែលផ្តល់ឱ្យអ្នកចូលរួមនូវជំនាញ និងយុទ្ធសាស្ត្រនៃភាពជាអ្នកដឹកនាំតាមបែបសម័យទំនើបដោយផ្តោតលើ៖

១. ការផ្លាស់ប្តូរកែលម្អភាពជាអ្នកដឹកនាំ៖ វិធីសាស្ត្រនៃការដោះស្រាយបញ្ហាប្រឈមចំពោះមុខសម្រាប់ក្រុម និងអង្គភាព និងការចាប់យកឱកាសនៃការផ្លាស់ប្តូរទៅជាតួនាទីជាអ្នកដឹកនាំ ដោយអនុវត្តវិធីសាស្ត្រ និងផ្នត់គំនិតថ្មីៗនៃការដឹកនាំ។

២. ការកសាងក្រុម ការទំនាក់ទំនង និងកិច្ចសហការប្រកបដោយប្រសិទ្ធភាព៖ ការពង្រឹងជំនាញទំនាក់ទំនង ការបង្កើតកិច្ចសន្ទនាសំខាន់ៗ និងការដឹកនាំក្រុមដែលមានសមត្ថភាពខ្ពស់តាមរយៈការហ្វឹកហាត់ និងពង្រឹងទំនួលខុសត្រូវប្រកបដោយប្រសិទ្ធភាព។

៣. ការជំរុញការផ្លាស់ប្តូរកែលម្អ និងគំនិតច្នៃប្រឌិតរបស់អង្គភាព៖ វិធីសាស្ត្រនៃការដឹកនាំ និងការគ្រប់គ្រងការផ្លាស់ប្តូរកែលម្អ ព្រមទាំងជំរុញវប្បធម៌នៃការច្នៃប្រឌិត តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រ ផែនការប្រតិបត្តិ និងប្រព័ន្ធគ្រប់គ្រងលទ្ធផលការងារប្រកបដោយប្រសិទ្ធភាពខ្ពស់៕






# ការប្រគល់ថវិកាបរិច្ចាគ របស់អគ្គនាយកដ្ឋានពន្ធដារ ជូនមូលនិធិគន្ធបុប្ផាកម្ពុជា


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
មូលនិធិគន្ធបុប្ផាកម្ពុជា
សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូន
ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ
និងជាប្រធានគណៈកម្មការទ្រទ្រង់មូលនិធិប្រចាំអគ្គនាយកដ្ឋានពន្ធ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកនៃអគ្គនាយកដ្ឋានពន្ធដារ
ដែលបានចូលរួមបរិច្ចាគថវិកាចំនួន ១៩០ ៣០០ ០០០ រៀល ជូនមូលនិធិគន្ធបុប្ផាកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង
**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ជាស្ថាបនិក និងមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី
និង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុនី ហ៊ុនម៉ាណែត** ជាប្រធានកិត្តិយស សំដៅធានានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផា។
សូមប្រសិទ្ធពរបវរសួស្តីមហាប្រសើរ និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃចន្ទ ២កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២ ខែធ្នូ គ.ស.២០២៤
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាភិបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា**
**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**








ក្រុមការងារតំណាងអគ្គនាយកដ្ឋានពន្ធដារ

នារសៀលថ្ងៃចន្ទ ទី២ ខែធ្នូ ឆ្នាំ២០២៤ យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងជាប្រធានគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជាប្រចាំអគ្គនាយកដ្ឋានពន្ធដារ ក្រុមការងារលេខាធិការដ្ឋាននៃគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជាប្រចាំអគ្គនាយកដ្ឋានពន្ធដារ ដឹកនាំដោយលោក **ង៉ាន់ វុទ្ធី** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិកនៃអគ្គនាយកដ្ឋានពន្ធដារ និងជាប្រធានលេខាធិការដ្ឋាន បាននាំយកថវិកាបរិច្ចាគសរុបចំនួន **១៩០ ៣០០ ០០០ (មួយរយកៅសិបលាន បីរយពាន់) រៀល** ប្រគល់ជូនមូលនិធិគន្ធបុប្ផាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងគោលបំណងរួមគ្នារក្សានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផា ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកនៃអគ្គនាយកដ្ឋានពន្ធដារ បានចូលរួមបរិច្ចាគថវិកាចាប់តាំងពីឆ្នាំ២០១៩ មក ផ្អែកតាមលិខិតលេខ០២៦ ម.គ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ របស់មូលនិធិគន្ធបុប្ផាកម្ពុជា។ គួរបញ្ជាក់ផងដែរថា ក្នុងឆ្នាំ២០១៩ អគ្គនាយកដ្ឋានពន្ធដារ បានចូលរួមបរិច្ចាគថវិកា ចំនួន **១៣៤ ៨៤៣ ០០០ រៀល**, ឆ្នាំ២០២០ ចំនួន **១៦៣ ៩៥០ ០០០ រៀល**, ឆ្នាំ២០២១ ចំនួន **១៦៦ ៤៥០ ០០០ រៀល**, ឆ្នាំ២០២២ ចំនួន **១៨០ ០៤០ ០០០ រៀល**, និងឆ្នាំ២០២៣ ចំនួន **១៨៣ ៨៥១ ០០០ រៀល**។

ក្នុងឱកាសនោះ តំណាងមូលនិធិគន្ធបុប្ផាប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងវាយតម្លៃខ្ពស់ចំពោះទឹកចិត្តសប្បុរសធម៌របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងជាប្រធានគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជាប្រចាំអគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់នៃអគ្គនាយកដ្ឋានពន្ធដារ ដែលបានចូលរួមបរិច្ចាគថវិកាជាប្រចាំ ចាប់តាំងពីឆ្នាំ២០១៩ រហូតដល់បច្ចុប្បន្ន និងសូមស្នើសុំឱ្យបន្តសម្រាប់ឆ្នាំក្រោយៗទៀត ដើម្បីរួមគ្នារក្សានិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផា ក្នុងការបន្តបេសកកម្មផ្តល់សេវាពិនិត្យនិងព្យាបាលទារក និងកុមារ ព្រមទាំងស្ត្រីមានផ្ទៃពោះរាប់លាននករណីក្នុងមួយឆ្នាំ ប្រកបដោយគុណភាព ឥតគិតថ្លៃ និងមិនមានការរើសអើង៕

# អនុសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៃអគ្គនាយកដ្ឋានពន្ធដារ នាំយកសម្ភារៈសិក្សា បរិក្ខារការិយាល័យ ចែកជូនកុមារា កុមារី នៅសាលាមត្តេយ្យសហគមន៍ភូមិព្រៃកក្រូច



នាព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤ លោកជំទាវ **ចិុន នារី** អគ្គនាយករង និងជាប្រធានអនុសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំក្រុមការងារ នាំយកសម្ភារៈសិក្សាចែកជូនកុមារា កុមារី ចំនួន **៣៥ រូប** និងបានឧបត្ថម្ភបរិក្ខារការិយាល័យមួយចំនួនដល់សាលាមត្តេយ្យសហគមន៍ ក្នុងភូមិព្រៃកក្រូច ឃុំភូមិធំ ស្រុកល្វាឯម ខេត្តកណ្ដាល។ សកម្មភាពនេះ បានឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរួមគ្នាជាកម្លាំងគាំទ្ររបស់អនុសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេស បញ្ចកោណទី១ (ការអភិវឌ្ឍមូលធនមនុស្ស)នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដោយប្រកាន់ខ្ជាប់នូវទស្សនអ្វីៗទាំងអស់ ដើម្បីសុខុមាលភាពរបស់ស្ត្រី និងកុមារកម្ពុជាដែលជាអនាគតនៃប្រទេសជាតិ៕



# កិច្ចពិភាក្សាស្តីពីការពង្រឹងសមត្ថភាព គ្រូបង្រៀនមុខវិជ្ជាពន្ធដារ នៅតាមគ្រឹះស្ថានឧត្តមសិក្សា



នាព្រឹកថ្ងៃសុក្រ ទី២០ ខែធ្នូ ឆ្នាំ២០២៤ នៅសាលាជាតិពន្ធដារបានរៀបចំកិច្ចពិភាក្សាស្តីពី "ការពង្រឹងសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាពន្ធដារ នៅតាមគ្រឹះស្ថានឧត្តមសិក្សា" រវាងសាលាជាតិពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ និងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ក្រោមអធិបតីភាពលោក **ស៊ុន ឧុទ្ធី** នាយកសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ និងឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** ប្រធានសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីនៃសាលាជាតិពន្ធដារ និងថ្នាក់ដឹកនាំ សាស្ត្រាចារ្យនៃសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាសរុបចំនួន **៧៧ រូប** ដែលអញ្ជើញមកពីបណ្តាសាកលវិទ្យាល័យ និងគ្រឹះស្ថានសិក្សាទូទាំងប្រទេស។

ជាកិច្ចចាប់ផ្តើម លោក **ស៊ុន ឧុទ្ធី** នាយកសាលាជាតិពន្ធដារ បានមានមតិសំណេះសំណាលដោយបានស្វាគមន៍យ៉ាងកក់ក្តៅនូវវត្តមានរបស់ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការ នាយក សាស្ត្រាចារ្យ លោក លោកស្រី ទាំងអស់ដែលបានចូលរួមក្នុងកិច្ចពិភាក្សានេះ និងបានគូសរំលេចអំពីការយកចិត្តទុកដាក់របស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការចូលរួមអនុវត្តភាពជាដៃគូល្អ រវាងអគ្គនាយកដ្ឋានពន្ធដារ និងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ជាពិសេសលើវិស័យអប់រំនេះ ក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃបំផុតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ បន្ថែមពីនេះលោកនាយកសាលាជាតិពន្ធដារបានគូសបញ្ជាក់អំពីគោលបំណងនៃកិច្ចពិភាក្សានេះ គឺដើម្បីបង្កើនភាពជាដៃគូ រវាងអគ្គនាយកដ្ឋានពន្ធដារ និងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ពង្រឹងសមត្ថភាពគ្រូបង្រៀនលើមុខវិជ្ជាពន្ធដារដើម្បីឱ្យមានសង្គតិភាព និងឯកភាពគ្នា ទាំងការបង្រៀន ការពន្យល់បកស្រាយ និងឯកសារបណ្តុះបណ្តាល និងបន្តផ្សព្វផ្សាយអំពីកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈពន្ធដារជូនដល់សមាជិកនៃសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា។ លោកនាយកបានបញ្ជាក់បន្ថែមថា ការធ្វើបច្ចុប្បន្នភាពចំណេះដឹងពាក់ព័ន្ធនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារគឺពិតជាមានសារៈសំខាន់មិនអាចខ្វះបានដើម្បីចូលរួមផ្សព្វផ្សាយនូវចំណេះដឹងស្តីពីពន្ធដារ ក៏ដូចជាវប្បធម៌នៃការបង់ពន្ធក្នុងការគាំទ្រដល់ការកៀរគរចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងគោលដៅបង្កើនចំណូលថវិការដ្ឋ និងរក្សាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។

ជាកិច្ចបន្ទាប់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** ប្រធានសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា បានផ្តល់ចំណាប់អារម្មណ៍អំពីកិច្ចពិភាក្សា និងថ្លែងអំណរគុណចំពោះអគ្គនាយកដ្ឋានពន្ធដារ ដែលតែងតែផ្តល់កិច្ចសហការល្អ និងបង្កើតឱ្យមានកិច្ចពិភាក្សានេះឡើង។ ឯកឧត្តមបណ្ឌិតបានសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹងដល់កិច្ចខិតខំប្រឹងប្រែងកំណែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ ដែលធ្វើឱ្យការប្រមូលចំណូលពន្ធដារជាថវិកាជាតិមានការកើនឡើងជារៀងរាល់ឆ្នាំ។ បន្ថែមពីនេះឯកឧត្តមបណ្ឌិតបានលើកឡើងអំពីកិច្ចសហការរវាងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារពិតជាមានសារៈសំខាន់ក្នុងការពង្រឹងសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាពន្ធដារនៅតាមបណ្តាគ្រឹះស្ថានឧត្តមសិក្សា និងជំរុញឱ្យមានសង្គតិភាពលើការបង្រៀន ការបកស្រាយ និងឯកសារបណ្តុះបណ្តាលឱ្យមានលក្ខណៈឯកសណ្ឋានភាព។

ជាលទ្ធផលនៃកិច្ចពិភាក្សា សមាជិកសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាបានបង្ហាញអំពីការគាំទ្រឱ្យមានវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាពន្ធដារសម្រាប់គ្រឹះស្ថានឧត្តមសិក្សា និងការរៀបចំឯកសារបណ្តុះបណ្តាលជារួមមួយលើមុខវិជ្ជាពន្ធដារ ដើម្បីឱ្យការបង្រៀនមុខវិជ្ជាពន្ធដារនេះមានសង្គតិភាពទូទាំងប្រទេស។ បន្ថែមលើនេះ កិច្ចពិភាក្សាអនុញ្ញាតឱ្យស្ថាប័នទាំងពីរអាចសហការផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារថ្មីៗ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ ជូនដល់គ្រូ ក៏ដូចជាសិស្ស-និស្សិត និងសាធារណជន ដើម្បីបន្តនិរន្តរភាពវប្បធម៌នៃការបង់ពន្ធ និងការប្រមូលចំណូលពន្ធ។ ជាងនេះទៅទៀត សមាជិកសមាគមគ្រឹះស្ថានឧត្តមសិក្សាដែលបានចូលរួមក្នុងកិច្ចពិភាក្សានេះក៏បានសំណូមពរឱ្យអគ្គនាយកដ្ឋានពន្ធដារបន្តរៀបចំឱ្យមានការជួបជុំពិភាក្សាគ្នាជាប្រចាំនៅពេលក្រោយៗទៀត៕



ឯកឧត្តមបណ្ឌិត ***ហេង វ៉ាន់ដា***
*ប្រធានសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា*



លោក ***ស៊ុន វុទ្ធី***
*នាយកសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ*



# ២. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ

## ការចូលរួមកិច្ចប្រជុំក្រុមការងារអន្តររដ្ឋាភិបាលរបស់សន្និសីទ អង្គការសហប្រជាជាតិស្តីពីការអភិវឌ្ឍនិងពាណិជ្ជកម្ម (UNCTAD) លើកទី៤១ ស្តីពីស្តង់ដាគណនេយ្យ និងស្តង់ដារបាយការណ៍អន្តរជាតិ (ISAR)




ចាប់ពីថ្ងៃទី៥ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំគណៈប្រតិភូរួមមាន លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងលោកស្រី **ព្រុំ នីដា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ចូលរួមក្នុងកិច្ចប្រជុំក្រុមការងារអន្តររដ្ឋាភិបាលរបស់សន្និសីទ អង្គការសហប្រជាជាតិស្តីពីការអភិវឌ្ឍ និងពាណិជ្ជកម្ម (UNCTAD) លើកទី៤១ ស្តីពីស្តង់ដាគណនេយ្យ និងស្តង់ដារបាយការណ៍អន្តរជាតិ (ISAR) ដែលបានប្រព្រឹត្តទៅពីថ្ងៃទី៥ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស។

សន្និសីទ UNCTAD-ISAR បានធ្វើឡើងជារៀងរាល់ឆ្នាំដោយបានបើកចំហការចូលរួមពីសមាជិកទាំងអស់របស់ UNCTAD។ សន្និសីទលើកទី៤១ នេះបានផ្តោតជាសំខាន់លើការអភិវឌ្ឍស្តង់ដារបាយការណ៍ និរន្តរភាពនៃវិស័យសាធារណៈ ដែលបានផ្តោតលើប្រធានបទសំខាន់បី រួមមាន ១.វិធីសាស្ត្រដែលក្រុមប្រឹក្សាភិបាលស្តង់ដាគណនេយ្យអន្តរជាតិ (International Public Sector Accounting Standard Board -IPSASB) នឹងអភិវឌ្ឍស្តង់ដារបាយការណ៍និរន្តរភាពនៃវិស័យសាធារណៈដែលបំពេញតម្រូវការផ្សេងៗគ្នា របស់អ្នកប្រើប្រាស់និងសមត្ថភាពនៃការរៀបចំ ២.តម្រូវការព័ត៌មានសម្រាប់អ្នកប្រើប្រាស់របាយការណ៍និរន្តរភាពនៃវិស័យសាធារណៈ និង ៣.ភារកិច្ចរបស់ក្រុមការងារអន្តររដ្ឋាភិបាលនៃអ្នកជំនាញលើស្តង់ដាគណនេយ្យ និងស្តង់ដារបាយការណ៍អន្តរជាតិ (Intergovernmental Working Group of Experts on International Standards of Accounting and Reporting-ISAR) ក្នុងការលើកកម្ពស់របាយការណ៍និរន្តរភាពអង្គការវិជ្ជាជីវៈគណនេយ្យ (Professional Accountancy Organizations-PAOs) ស្ថាប័នវិស័យសាធារណៈ និងតួអង្គសង្គមស៊ីវិលផ្សេងទៀតអាចជួយសម្របសម្រួលក្នុងការរៀបចំកសាងសមត្ថភាព ដើម្បីការអនុម័ត និងការអនុវត្តរបាយការណ៍និរន្តរភាពក្នុងវិស័យសាធារណៈ។ ក្នុងន័យនេះ អង្គសន្និសីទ បានផ្តល់ឱកាសឱ្យមានការបង្ហាញ

ពីការគិតគូររបស់ IPSASB លើការអភិវឌ្ឍរបាយការណ៍និរន្តរភាពនៃវិស័យសាធារណៈ ដើម្បីឆ្លើយតបនឹងការវិវឌ្ឍផ្នែកឌីជីថល និងកង្វល់របស់តួអង្គពាក់ព័ន្ធទាំងអស់។

ក្នុងអង្គសន្និសីទនេះ ក៏មានដំណើរការនូវកិច្ចប្រជុំក្រុមការងារអន្តររដ្ឋាភិបាល ដែលផ្តោតលើរបៀបវារៈសំខាន់ៗចំនួនពីរ រួមមាន ១.ការពិនិត្យឡើងវិញនូវការអនុវត្តជាក់ស្តែងនៃការអភិវឌ្ឍថ្មីៗនៅក្នុងតម្រូវការនិរន្តរភាព ២.តម្រូវការរបាយការណ៍ និងគណនេយ្យរបស់សហគ្រាសធុនតូចនិងមធ្យម និងតួនាទីនៃរបាយការណ៍និងគណនេយ្យក្នុងការសម្របសម្រួលឱ្យសហគ្រាសក្នុងវិស័យក្រៅផ្លូវការចូលនៅក្នុងវិស័យផ្លូវការ។ ពាក់ព័ន្ធនឹងរបៀបវារៈទី១ អង្គប្រជុំបានលើកឡើងថា ភាពជឿទុកចិត្តបាននៃគណនេយ្យនិងរបាយការណ៍ស្តីពីហិរញ្ញវត្ថុ និងនិរន្តរភាពរបស់វិស័យឯកជន និងវិស័យសាធារណៈ គឺជាបុរេលក្ខខណ្ឌតម្រូវសម្រាប់ជាព័ត៌មាននៃការសម្រេចចិត្តវិនិយោគ និងជាការសម្រួលដល់ការបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តផងដែរ។ ទន្ទឹមនឹងនេះ អង្គប្រជុំបានស្វាគមន៍ចំពោះវឌ្ឍនភាពឆ្ពោះទៅរកការចុះសម្រុងគ្នានៃរបាយការណ៍និរន្តរភាព តាមរយៈការបោះពុម្ពផ្សាយនូវស្តង់ដារបាយការណ៍និរន្តរភាពដំបូងដោយក្រុមប្រឹក្សាស្តង់ដានិរន្តរភាពអន្តរជាតិ (International Sustainability Standards Board - ISSB) និងការទទួលយកមកពិចារណាលើស្តង់ដាទាំងនេះដោយអង្គការអន្តរជាតិនៃគណៈកម្មការមូលបត្រ។ អង្គប្រជុំក៏បានរំលឹកអំពីតម្រូវការសម្រាប់រដ្ឋជាសមាជិក ក្នុងការកសាងនិងអភិវឌ្ឍន៍បទប្បញ្ញត្តិ ស្ថាប័ន និងសមត្ថភាពធនធានមនុស្ស ដើម្បីគាំទ្រដល់ប្រសិទ្ធភាព នៃការអនុវត្តស្តង់ដារបាយការណ៍និរន្តរភាព ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ ជាមួយគ្នានេះ ក្រុមការងារអន្តររដ្ឋាភិបាលរបស់ UNCTAD បាន៖ ១.អំពាវនាវដល់លេខាធិការដ្ឋាន UNCTAD ឱ្យបន្តត្រួតពិនិត្យការពិភាក្សាស្តីពីការបង្កើតស្តង់ដារបាយការណ៍និរន្តរភាព សម្រាប់អង្គភាពវិស័យសាធារណៈ ដែលធ្វើឡើងដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យ វិស័យសាធារណៈអន្តរជាតិ ដើម្បីដើរតួជាមធ្យោបាយ ក្នុងការត្រួតពិនិត្យតាមតម្រូវការរបស់ ISAR ២.ស្នើសុំឱ្យលេខាធិការដ្ឋាន UNCTAD បន្តគាំទ្រដល់រដ្ឋសមាជិកក្នុងការកសាងសមត្ថភាពសម្រាប់ការអនុវត្តតម្រូវការរបាយការណ៍និរន្តរភាព រួមទាំងតាមរយៈគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេស ជាពិសេស ប្រទេសកំពុងអភិវឌ្ឍន៍ ៣.លើកទឹកចិត្តឱ្យលេខាធិការដ្ឋាន UNCTAD បន្តកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារពាក់ព័ន្ធរបស់ UN និងស្ថាប័នផ្សេងទៀតស្តីពីរបាយការណ៍និរន្តរភាព ជាពិសេសការវាស់វែងនូវការរួមចំណែករបស់វិស័យឯកជន ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ៤.ធ្វើការវាយតម្លៃខ្ពស់ចំពោះលេខាធិការដ្ឋាន UNCTAD ដែលបានផ្តល់ការគាំទ្រក្នុងអំឡុងពេលអន្តរកម្មដល់ភាពជាដៃគូ ក្នុងតំបន់សម្រាប់ការលើកកម្ពស់របាយការណ៍និរន្តរភាពនៅក្នុងទ្វីបអាហ្វ្រិក និងអាមេរិកឡាទីន ចំពោះការរៀបចំជាបន្តបន្ទាប់នៃការពិគ្រោះយោបល់ ដើម្បីគាំទ្រដល់ការបង្កើតភាពជាដៃគូក្នុងតំបន់ប្រហាក់ប្រហែល នៅអាស៊ីនិងនៅរដ្ឋក្នុងតំបន់ឈូងសមុទ្រ និងប្រទេសជិតខាង ៥.លើកទឹកចិត្តឱ្យលេខាធិការដ្ឋាន UNCTAD បន្តស្វែងរកកិច្ចសហការគ្នាជាមួយសហគមន៍ហិរញ្ញវត្ថុ និងវិនិយោគប្រកបដោយនិរន្តរភាពកាន់តែទូលំទូលាយ។ សម្រាប់របៀបវារៈទី២ អង្គប្រជុំបានរំលឹកឡើងវិញនូវដំណោះស្រាយរបស់មហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០២២ ដែលបានទទួលស្គាល់ពីសារៈសំខាន់នៃសហគ្រាសធុនតូចនិងមធ្យម (SMEs) ក្នុងការជំរុញកំណើនសេដ្ឋកិច្ចរបស់ប្រទេសសមាជិក និងតួនាទីរបស់ SMEs ក្នុងការគាំទ្រដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ទន្ទឹមនឹងនេះ អង្គប្រជុំបានទទួលស្គាល់ពីវឌ្ឍនភាពដ៏សំខាន់ដែលត្រូវបានធ្វើឡើងក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ក្នុងការឈានទៅផ្តល់ជូន SMEs នូវសេចក្តីណែនាំស្តីពីគណនេយ្យនិងរបាយការណ៍ សមស្របទៅនឹងទំហំរបស់ SMEs និងឥទ្ធិពលវិជ្ជមានរបស់សេចក្តីណែនាំស្តីពីគណនេយ្យនិងហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យម ចេញដោយ ISAR ព្រមទាំងមានការសម្របសម្រួលដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋសមាជិកក្នុងការអនុវត្ត។ អង្គប្រជុំបានសង្កត់ធ្ងន់លើអត្ថប្រយោជន៍សំខាន់ៗ ដែលរដ្ឋជាសមាជិកអាចទទួលបាននូវការគាំទ្រក្នុងការធ្វើឱ្យ SMEs ក្នុងវិស័យក្រៅផ្លូវការចូលទៅក្នុងវិស័យផ្លូវការប្រកបដោយនិរន្តរភាព។ បន្ថែមពីនេះ ក៏បានទទួលស្គាល់ស្តង់ដាគណនេយ្យ

និងស្តង់ដារបាយការណ៍ អាចប៉ះពាល់ដល់ការចូលទៅក្នុងវិស័យផ្លូវការរបស់សហគ្រាសក្នុងវិស័យក្រៅផ្លូវការ ហើយដំណោះស្រាយឌីជីថលអាចគាំទ្រដល់រដ្ឋាភិបាលក្នុងការធ្វើឱ្យសហគ្រាសក្នុងវិស័យក្រៅផ្លូវការចូលទៅក្នុងវិស័យផ្លូវការដែលជាគោលដៅនៃការអភិវឌ្ឍវិស័យឯកជន។ ជាមួយគ្នានេះ ក្រុមការងារអន្តររដ្ឋាភិបាល របស់ UNCTAD បានស្នើឱ្យលេខាធិការដ្ឋាន UNCTAD ១.បន្តធ្វើការត្រួតពិនិត្យតាមកាលកំណត់លើប្រធានបទនេះ ក្នុងគោលបំណងសម្របសម្រួលចែករំលែកការអនុវត្តល្អក្នុងចំណោមរដ្ឋសមាជិកលើបញ្ហាដូចជាភាពសាមញ្ញនៃគណនេយ្យនិងតម្រូវការរបាយការណ៍សម្រាប់សហគ្រាស និងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់សហគ្រិន និងការកសាងសមត្ថភាពផ្នែកគណនេយ្យ និងរបាយការណ៍ក្នុងក្របខ័ណ្ឌទូលំទូលាយនៃគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលលើការអភិវឌ្ឍវិស័យឯកជន និង ២.បន្តគាំទ្ររដ្ឋសមាជិកជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការខិតខំប្រឹងប្រែងឆ្ពោះទៅរកនិរន្តរភាពនៃការធ្វើឱ្យ SMEs ក្នុងវិស័យក្រៅផ្លូវការចូលក្នុងវិស័យផ្លូវការ រួមទាំងតាមរយៈគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេស៕














# ការចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សា នៃវេទិកាពាណិជ្ជកម្ម និងវិនិយោគរួមគ្នារវាង កម្ពុជា និងចក្រភពអង់គ្លេស លើកទី២ក្រោមមូលបទ "ចក្ខុវិស័យឆ្ពោះទៅកាន់ឆ្នាំ២០៣០" (United Kingdom-Cambodia Joint Trade and Investment Forum, "Road to 2030")



នារសៀលថ្ងៃអង្គារ ទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅសណ្ឋាគាររ៉ូសវូដ រាជធានីភ្នំពេញ លោកជំទាវ **ម៉ឹន ណារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំគណៈប្រតិភូអគ្គនាយកដ្ឋានពន្ធដារ ចូលរួមនិងធ្វើជាវាគ្មិនក្នុងកិច្ចពិភាក្សានៃវេទិកាពាណិជ្ជកម្មនិងវិនិយោគរួមគ្នារវាងកម្ពុជា និងចក្រភពអង់គ្លេស លើកទី២ ក្រោមមូលបទ "ចក្ខុវិស័យឆ្ពោះទៅកាន់ឆ្នាំ២០៣០" (United Kingdom-Cambodia Joint Trade and Investment Forum, "Road to 2030")។ វេទិកាពាណិជ្ជកម្មនិងវិនិយោគរួមគ្នានេះ មានការចូលរួមដឹកនាំជាសហប្រធានដោយលោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឯកឧត្តម Dominic Williams ឯកអគ្គរាជទូតចក្រភពអង់គ្លេសប្រចាំកម្ពុជា ព្រមទាំងមានវត្តមានចូលរួមពីតំណាងក្រសួងស្ថាប័ន សភាពាណិជ្ជកម្ម ក្រុមហ៊ុន និងសហគ្រាសឯកជននៃប្រទេសទាំងពីរ សរុបប្រមាណ **៩០ រូប** ផងដែរ។

ក្នុងចំណាប់អារម្មណ៍បើកវេទិកាពាណិជ្ជកម្មនិងវិនិយោគរួមគ្នានេះ លោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឯកឧត្តម Dominic Williams ឯកអគ្គរាជទូតចក្រភពអង់គ្លេសប្រចាំកម្ពុជា បានសម្តែងនូវមតិស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា តំណាងក្រសួងស្ថាប័ន សភាពាណិជ្ជកម្ម ក្រុមហ៊ុន និងសហគ្រាសឯកជននៃប្រទេសទាំងពីរ ដែលមានវត្តមានក្នុងវេទិកានេះ និងបានបង្ហាញអំពីគោលបំណងសំខាន់ក្នុងការរៀបចំវេទិកានេះឡើង ពោលគឺដើម្បីពិភាក្សាពីវឌ្ឍនភាពការងារក្រោមក្របខ័ណ្ឌវេទិកាពាណិជ្ជកម្មនិងវិនិយោគ និងកំណត់ទិសដៅការងារបន្តក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងវិនិយោគឱ្យមានកំណើនប្រកបដោយបរិយាបន្ន និងចីរភាព ជាពិសេសការពង្រឹងភាពជាដៃគូរវាងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរឡើងថែមមួយកម្រិតទៀត។

វេទិកាពាណិជ្ជកម្មនិងវិនិយោគរួមគ្នារវាងកម្ពុជា និងចក្រភពអង់គ្លេសលើកទី២ ក៏បានរៀបចំជាកិច្ចពិភាក្សាមួយ ដែលផ្តោតទៅលើ "**ការអភិវឌ្ឍគោលនយោបាយពាណិជ្ជកម្មនិងវិនិយោគ និងផ្នែកអាទិភាពរវាងកម្ពុជា និងចក្រភពអង់គ្លេស** (Cambodia and UK Trade and Investment Policy Development and Priorities" ដោយលោកជំទាវ **ម៉ុន សារី** ក្នុងនាមតំណាងអគ្គនាយកដ្ឋានពន្ធដារបានចូលរួមជាអ្នកពិភាក្សា (Panelist) ជាមួយតំណាងស្ថាប័នរដ្ឋាភិបាលផ្សេងទៀតផងដែរ។ ក្នុងកិច្ចពិភាក្សានេះ លោកជំទាវ បានគូសបញ្ជាក់ថា បច្ចុប្បន្នអគ្គនាយកដ្ឋានពន្ធដារបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះតម្លាភាព សង្គតិភាព និងភាពអាចព្យាករទុកបាន (Transparency, Consistency and Predictability) ជាក់ស្តែង នាពេលថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារបានផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនូវសៀវភៅណែនាំស្តីពីបែបបទ នីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ (SOP on Auditing) និងសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ (SOP on Investigation) ក៏ដូចជាបានបង្កើតនូវអង្គភាពសវនកម្មពន្ធដារពិសេស ដើម្បីធ្វើឱ្យប្រសើរថែមទៀតនូវការធ្វើសវនកម្មពន្ធដារ ពង្រឹងយន្តការ និងបទប្បញ្ញត្តិនានា ឱ្យមានភាពអាចព្យាករទុកបាននិងកាន់តែច្បាស់លាស់។ ជាមួយគ្នានេះ លោកជំទាវ ក៏បានបង្ហាញអំពីវឌ្ឍនភាពថ្មីៗនៃការចរចាកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) និងបានជម្រាបជូនអង្គវេទិកាផងដែរថា អគ្គនាយកដ្ឋានពន្ធដារបានត្រៀមខ្លួនរួចជាស្រេចក្នុងការចាប់ផ្តើមការចរចាកិច្ចព្រមព្រៀង DTA ជាមួយចក្រភពអង់គ្លេស។ បន្ថែមពីលើនេះ លោកជំទាវក៏បានជម្រាបជូនអំពីយន្តការនៃការដោះស្រាយបណ្តឹងតវ៉ាស្របតាមច្បាប់ស្តីពីសារពើពន្ធរបស់កម្ពុជា ដែលមានយន្តការកម្រិតអគ្គនាយកដ្ឋានពន្ធដារ និងយន្តការឯករាជ្យរបស់គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ក្នុងករណីវិនិយោគិនអង់គ្លេសមានបញ្ហាណាមួយពាក់ព័ន្ធនឹងពន្ធដារ វិនិយោគិនអាចទំនាក់ទំនងផ្ទាល់មកអគ្គនាយកដ្ឋានពន្ធដារ និងលើកជាបញ្ហាជាក់ស្តែង ដើម្បីឱ្យអគ្គនាយកដ្ឋានពន្ធដារដោះស្រាយ និងបានស្នើឱ្យអង្គវេទិកាទាំងមូលតាមដានទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយក-ដ្ឋានពន្ធដារ ដើម្បីទទួលបានព័ត៌មានថ្មីៗ ឬទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលពិគ្រោះយោបល់របស់អគ្គនាយកដ្ឋានពន្ធដារ តាមរយៈលេខ ១២៧៧ ដើម្បីសាកសួរសំណួរផ្សេងៗ។ បច្ចុប្បន្ន អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវផែនការសកម្មភាពក្នុងការធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធ (Digital Transformation of Tax Administration) ដែលស្របទៅតាមនិន្នាការ និងតម្រូវការនៃការធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធក្នុងតំបន់និងសកលលោក យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍធនធានមនុស្ស និងការផ្តល់សេវាប្រកបដោយគុណភាពផងដែរ។

ថ្លែងក្នុងមតិបិទបញ្ចប់អង្គវេទិកានេះ លោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឯកឧត្តម Dominic Williams ឯកអគ្គរាជទូតចក្រភពអង់គ្លេសប្រចាំកម្ពុជា បានវាយតម្លៃខ្ពស់ចំពោះការរៀបចំវេទិកាពាណិជ្ជកម្មនិងវិនិយោគរួមគ្នារវាងកម្ពុជា និងចក្រភពអង់គ្លេសលើកទី២ នេះឡើងប្រកបដោយភាពជោគជ័យ ព្រមទាំងទទួលបាននូវលទ្ធផលផ្លែផ្កា និងបានថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា តំណាងក្រសួងស្ថាប័ន សភាពាណិជ្ជកម្ម ក្រុមហ៊ុន និងសហគ្រាសឯកជននៃប្រទេសទាំងពីរ ដែលបានចូលរួមនិងលើកឡើងជាមតិយោបល់នានាក្នុងអង្គវេទិកានេះ ព្រមទាំងសូមជូនពរប្រកបដោយសុភមង្គលក្នុងក្រុមគ្រួសារ និងជោគជ័យគ្រប់ភារកិច្ច ជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# ៣. កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA)

## កិច្ចប្រជុំចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) ជុំទី១ ជាមួយរដ្ឋកាតា



នាថ្ងៃទី២១-២៤ ខែតុលា ឆ្នាំ២០២៤ មានរៀបចំកិច្ចប្រជុំចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) ជុំទី១ រវាងព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយលោក **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ តំណាងឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងរដ្ឋកាតា ដឹកនាំដោយលោក Abdulla Ahmed Al-Sulaiti ប្រធានផ្នែកសន្ធិសញ្ញាពន្ធនិងការចរចា នៃនាយកដ្ឋានសន្ធិសញ្ញាពន្ធនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ នៃអគ្គអាជ្ញាធរពន្ធដាររបស់រដ្ឋកាតា នៅទីស្នាក់ការអគ្គអាជ្ញាធរពន្ធដារ (General Tax Authority) ក្នុងរាជធានីដូហា រដ្ឋកាតា។

ជាកិច្ចចាប់ផ្តើម លោក Abdulla Ahmed Al-Sulaiti ក្នុងនាមជាម្ចាស់ផ្ទះ បានសម្តែងមតិស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់គណៈប្រតិភូអគ្គនាយកដ្ឋានពន្ធដារ ដែលបានមកចូលរួមកិច្ចប្រជុំចរចា តបតាមការអញ្ជើញរបស់អគ្គអាជ្ញាធរពន្ធដារ នៃរដ្ឋកាតា ក៏ដូចជាបានបញ្ជាក់អំពីសារៈសំខាន់នៃកិច្ចព្រមព្រៀង DTA ក្នុងការពង្រីកកិច្ចសហប្រតិបត្តិការពន្ធដារទ្វេភាគីរវាងកម្ពុជា និងកាតា។ លោកក៏បានបន្ថែមទៀតថា លោកមានបំណងចង់ឱ្យការចរចានេះអាចបញ្ចប់ទៅឱ្យបានឆាប់តាមតែអាចធ្វើបានផងដែរ។

ជាការឆ្លើយតប លោក **សេង ជាសិទ្ធ** បានសម្តែងអំណរគុណចំពោះការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីភាគីកាតា និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំរបស់ភាគីកាតា ក្នុងការរៀបចំឱ្យមានកិច្ចប្រជុំចរចាលើកិច្ចព្រមព្រៀង DTA ជុំទី១ ជាលក្ខណៈរូបវន្ត និងបានឯកភាពក្នុងការព្យាយាមបញ្ចប់ការចរចាកិច្ចព្រមព្រៀង DTA នេះ ឱ្យបានឆាប់ផងដែរ។ លោកប្រធាននាយកដ្ឋាន ក៏បានគូសរំលេចអំពីសារៈសំខាន់នៃកិច្ចព្រមព្រៀងនេះ ក្នុងការជំរុញកំណើនពាណិជ្ជកម្ម និងការវិនិយោគទៅវិញទៅមក ជាពិសេសអត្ថប្រយោជន៍ដែលសហគ្រាសក្នុងវិស័យដឹកជញ្ជូនតាមផ្លូវអាកាសនិងផ្លូវទឹក រវាងកម្ពុជានិងកាតា អាចទទួលបានពីកិច្ចព្រមព្រៀងនេះ។

កិច្ចប្រជុំចរចាជុំទី១នេះបានបញ្ចប់ទៅក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងប្រកបដោយភាពយោគយល់គ្នាខ្ពស់ ហើយភាគីទាំងពីរនឹងបន្តការចរចាដើម្បីឈានទៅបញ្ចប់និងចុះហត្ថលេខានាពេលខាងមុខ៕

# ផ្នែកទី៥
# ការផ្សព្វផ្សាយ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ

១.	កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ

២.	ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ

៣.	សិក្ខាសាលាសំខាន់ៗ

# ការផ្សព្វផ្សាយ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ

ក្នុងគោលដៅពង្រឹងការយល់ដឹងអំពីពន្ធដារ ពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ការធ្វើទំនើបកម្មពន្ធដារ និងវឌ្ឍនភាពថ្មីៗ ជាពិសេសពាក់ព័ន្ធការផ្តល់សេវាអ្នកជាប់ពន្ធ ក្នុងខែធ្នូ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលចំនួន **៥៩ លើក** មានសិក្ខាកាមចូលរួមចំនួន **៧ ១៨៨ រូប** ក្នុងនោះ វគ្គបណ្តុះបណ្តាលចំនួន **១០ លើក** មានសិក្ខាកាមចូលរួមចំនួន **១ ៣៣០ រូប** និងសិក្ខាសាលាចំនួន **៤៩ លើក** មានសិក្ខាកាមចូលរួមចំនួន **៥ ៨៥៨ រូប**។

សរុបរយៈពេល ១២ខែ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលចំនួន **៨៦១ លើក** មានសិក្ខាកាមចូលរួមចំនួន **១០៨ ៩៦៨ រូប** ក្នុងនោះវគ្គបណ្តុះបណ្តាលចំនួន **៣៥៣ លើក** មានសិក្ខាកាមចូលរួមចំនួន **៥៤ ៩៤៣ រូប** និងសិក្ខាសាលាចំនួន **៥០៨ លើក** មានសិក្ខាកាមចូលរួមចំនួន **៥៤ ០២៥ រូប**។

**របាយការណ៍ ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ក្នុងរយៈពេល ១២ខែ ឆ្នាំ២០២៤**

| បរិយាយ | ចំនួនដង ក្នុងខែតុលា | ចំនួនសិក្ខាកាម ក្នុងខែតុលា | ចំនួនដង ក្នុងខែវិច្ឆិកា | ចំនួនសិក្ខាកាម ក្នុងខែវិច្ឆិកា | ចំនួនដង ក្នុងខែធ្នូ | ចំនួនសិក្ខាកាម ក្នុងខែធ្នូ | ចំនួនដង រយៈពេល១២ខែ | ចំនួនសិក្ខាកាម រយៈពេល១២ខែ |
|---|---|---|---|---|---|---|---|---|
| I.**សិក្ខាសាលា** | | | | | | | | |
| អ្នកជាប់ពន្ធ | ២១ | ១ ៩៣៣ | ១១ | ១ ៩៨៦ | ២៧ | ៣ ៩០០ | ៣៣៤ | ៣៣ ១២៤ |
| មន្ត្រីរាជការពន្ធដារ | ០២ | ១០០ | ១០ | ១ ៤៩០ | ០៧ | ៨៦១ | ៨២ | ១១ ៥០៨ |
| សិស្ស-និស្សិត | ០២ | ១២១ | ០២ | ៣៧៣ | ០០ | ០០ | ០៧ | ១ ១១១ |
| សាធារណជន | ០៥ | ៣៤៦ | ៣៣ | ៤ ២៩៨ | ១៥ | ១ ០៩៧ | ៨៥ | ៨ ២៨២ |
| មន្ត្រីធនាគារដៃគូ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| **សរុបសិក្ខាសាលា** | **៣០** | **២ ៥០០** | **៥៦** | **៨ ១៤៧** | **៤៩** | **៥ ៨៥៨** | **៥០៨** | **៥៤ ០២៥** |
| II.**វគ្គបណ្តុះបណ្តាល** | | | | | | | | |
| មន្ត្រីធនាគារដៃគូ | ០០ | ០០ | ១៧ | ៣ ១២០ | ០០ | ០០ | ៦០ | ១៤ ៨៨៤ |
| មន្ត្រីរាជការពន្ធដារ | ៣៥ | ៣ ៥៤៩ | ១៤ | ២ ១៧៥ | ១០ | ១ ៣៣០ | ២៩០ | ៣៩ ៦៤២ |
| អ្នកជាប់ពន្ធ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០៣ | ៤១៧ |
| **សរុបវគ្គបណ្តុះបណ្តាល** | **៣៥** | **៣ ៥៤៩** | **៣១** | **៥ ២៩៥** | **១០** | **១ ៣៣០** | **៣៥៣** | **៥៤ ៩៤៣** |
| **សរុបរួម** (I+II) | **៦៥** | **៦ ០៤៩** | **៨៧** | **១៣ ៤៤២** | **៥៩** | **៧ ១៨៨** | **៨៦១** | **១០៨ ៩៦៨** |





# ១.កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ

## វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ

ក្នុងត្រីមាសទី៤ ឆ្នាំ២០២៤ នេះ សាលាជាតិពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារបានបន្តបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ ជូនសិក្ខាកាមដែលបានចុះឈ្មោះចូលរៀនដែលក្នុងនោះរួមមាន៖ ១.ជំនាន់ទី១៨ បង់លុយពេញថ្លៃ ចំនួន **៤៣ ក្រុម** មានសរុបចំនួន **៩០៧ រូប** ២.ជំនាន់ទី១៨ បង់ថ្លៃអាហារូបករណ៍ ៥០% ចំនួន **៦ ក្រុម** មានសិក្ខាកាមសរុបចំនួន **១០៥ រូប** ៣.ជំនាន់ទី១៩ បង់លុយពេញថ្លៃ ចំនួន **៤៩ ក្រុម** ដែលមានសិក្ខាកាមសរុបចំនួន **៩៣៤ រូប**៕




## វគ្គបណ្តុះបណ្តាលខ្លីៗសម្រាប់អ្នកជាប់ពន្ធ និងសាធារណជនទូទៅ

ស្របតាមផែនការប្រតិបត្តិឆ្នាំ២០២៤ របស់សាលាជាតិពន្ធដារ នៅក្នុងត្រីមាសទី៤ នេះ សាលាជាតិពន្ធដារបានបន្តបើកវគ្គបណ្តុះបណ្តាលខ្លីៗ ជូនសាធារណជនទូទៅ ចំនួន **៤ វគ្គ** ដែលក្នុងនោះរួមមាន៖ ១.កាតព្វកិច្ចសារពើពន្ធរបស់សហគ្រាសប្រកបអាជីវកម្មផ្គត់ផ្គង់អគ្គិសនី សរុបចំនួន **២ ក្រុម** ដែលមានសិក្ខាកាមចុះឈ្មោះសិក្សាចំនួន **៥០ រូប** ២.នីតិវិធីការរៀបចំលិខិតប្រកាសពន្ធប្រចាំខែសម្រាប់អ្នកជាប់ពន្ធតូច កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច និងគណនេយ្យសាមញ្ញ ចំនួន **១ ក្រុម** ដែលមានសិក្ខាកាមចូលរួមចំនួន **៣០ រូប** ៣.ពន្ធកាត់ទុកទូទៅ ពន្ធលើប្រាក់បៀវត្ស និងកម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស ចំនួន **១ ក្រុម** ដែលមានសិក្ខាកាមចូលរួមចំនួន **១៧ រូប**៕



# សិក្ខាសាលាជូនភ្នាក់ងារសេវាកម្មពន្ធដារ អ្នកជាប់ពន្ធ និងសាធារណជនទូទៅ




ក្នុងត្រីមាសទី៤ ឆ្នាំ២០២៤ សាលាជាតិពន្ធដារ ក្រោមការសម្របសម្រួលពីលោកស្រី **ឆាយ៉ា ឆព័ណ្ណា** នាយករងសាលាជាតិពន្ធដារ និងលោក **នាក់ ឌីម** ប្រធានការិយាល័យនៃសាលាជាតិពន្ធដារ បានរៀបចំសិក្ខាសាលាទាំងផ្ទាល់និងអនឡាញលើប្រធានបទសំខាន់ៗមួយចំនួន រួមមាន អត្ថប្រយោជន៍នៃពន្ធ ប្រព័ន្ធពន្ធដារកម្ពុជា និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App) និងអាករលើតម្លៃបន្ថែម (អនុក្រឹត្យលេខ ៤៩ សហវ.ប្រក) សរុបចំនួន **៩ លើក** ជូនភ្នាក់ងារសេវាកម្មពន្ធដារ និងនិស្សិតតាមគ្រឹះស្ថានឧត្តមសិក្សា ចំនួន **៩៤៤ នាក់**៕



# ២.ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ

## ការផ្តល់សេវាបណ្ណាល័យសាលាជាតិពន្ធដារ

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៤ សាលាជាតិពន្ធដារបានផ្តល់សេវាបណ្ណាល័យរួមមាន៖ ការចូលអាន ការខ្ចី និងការទទួលសងសៀវភៅ និងឯកសារផ្សេងៗ ជូនដល់មន្ត្រីរាជការ សិក្ខាកាម សិស្ស-និស្សិត និងសាធារណជនទូទៅ បានចំនួន **៧៤ រូប** (ស្រីចំនួន ៧ រូប)។ ក្រៅពីការងារផ្តល់សេវាទាំងនេះ សាលាជាតិពន្ធដារក៏បានខិតខំស្រាវជ្រាវប្រមូល និងបានទទួលសៀវភៅថ្មីៗពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពីអគ្គនាយកដ្ឋានពន្ធដារ និងស្ថាប័នផ្សេងៗ បានចំនួន **១៤៨ ក្បាល** បន្ថែមទៀត ដើម្បីបំពេញតម្រូវការរបស់អ្នកអាន។ គិតមកដល់បច្ចុប្បន្ន បណ្ណាល័យសាលាជាតិពន្ធដារបានរក្សាទុកសៀវភៅ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងឯកសារសំខាន់ៗផ្សេងៗទៀតជាច្រើន សរុបចំនួន **៧ ៨៥៦ ក្បាល** ក្នុងនោះមានឯកសារជាទម្រង់ឌីជីថលចំនួន **២ ០៥៥ ឯកសារ**។





# ៣.សិក្ខាសាលាសំខាន់ៗ

## សិក្ខាសាលាស្តីពី "បច្ចុប្បន្នភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ"




រសៀលថ្ងៃចន្ទ ទី២១ ខែតុលា ឆ្នាំ២០២៤ លោកជំទាវ **ប៊ុន នារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាង ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ អគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារចូលរួមសិក្ខាសាលា ស្តីពីបច្ចុប្បន្នភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ តបតាមការអញ្ជើញរបស់សមាគមសភាពាណិជ្ជកម្មចិននៅកម្ពុជា (Chinese Chamber of Commerce in Cambodia-CCCC) ក្នុងគោលដៅផ្តល់នូវបច្ចុប្បន្នភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីពន្ធដារ ជូនសមាជិកសមាគមសភាពាណិជ្ជកម្មចិននៅកម្ពុជា។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្រោមអធិបតីភាពលោក LIN Shiqiang ប្រធានសមាគមសភាពាណិជ្ជកម្មចិន នៅកម្ពុជា និងសម្របសម្រួលដោយ ឧកញ៉ា Tan Khee Meng ទីប្រឹក្សាផ្នែកពន្ធនៃសមាគមសភាពាណិជ្ជកម្មចិន នៅកម្ពុជា ព្រមទាំងមានការចូលរួមពីតំណាងសហគ្រាសជាសមាជិកសមាគមសភាពាណិជ្ជកម្មចិននៅកម្ពុជា សរុប ប្រមាណ ២០០ រូប។

ដើម្បីបន្តសម្រួលបរិយាកាសធុរកិច្ចនិងការវិនិយោគ និងដោះស្រាយកង្វល់នានារបស់វិស័យឯកជន អគ្គនាយកដ្ឋាន ពន្ធដារដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានបន្តរៀបចំនិងធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងបន្តផ្សព្វផ្សាយគោលនយោបាយលើកទឹកចិត្តពន្ធដារនានារបស់រាជរដ្ឋាភិបាលដល់អ្នកជាប់ពន្ធដូចជា ១.ច្បាប់ ស្តីពីសារពើពន្ធឆ្នាំ២០២៣ ២.វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ និងការបន្តលើកទឹកចិត្តពន្ធដារក្នុងសេចក្តីថ្លែងការណ៍ពិសេសស្តីពីសមិទ្ធផល ១ឆ្នាំ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និង៣.កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុឆ្នាំ២០២៤។

ក្នុងសិក្ខាសាលានេះ មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ បានធ្វើបទបង្ហាញពន្យល់ និងបកស្រាយលម្អិតយ៉ាង ក្បោះក្បាយអំពីខ្លឹមសារនីមួយៗនៃបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងគោលនយោបាយលើកទឹកចិត្ត ពន្ធដារនានារបស់រាជរដ្ឋាភិបាលដែលបានដាក់ឱ្យអនុវត្ត ហើយនេះគឺជាការផ្តល់សេវាផ្សព្វផ្សាយផ្ទាល់ជូនអ្នកជាប់ពន្ធ។ បទបង្ហាញនេះបានធ្វើឱ្យសមាជិកសមាគមសភាពាណិជ្ជកម្មចិននៅកម្ពុជា ពេញចិត្តយ៉ាងខ្លាំងនិងបានបញ្ជាក់ពីការ ទទួលនូវចំណេះដឹងថ្មីក្នុងការបង្កើនអនុលោមភាពសារពើពន្ធ៕

# សិក្ខាសាលាស្តីពី "អាករលើតម្លៃបន្ថែម ចំពោះប្រតិបត្តិការឆ្លងកាត់ព្រំដែន"




នាថ្ងៃទី២១និងថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ បានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank - ADB) រៀបចំសិក្ខាសាលាស្តីពី "អាករលើតម្លៃបន្ថែមចំពោះប្រតិបត្តិការឆ្លងកាត់ព្រំដែន" នៅសណ្ឋាគារ Raffles Le Royal ។ បន្ទាប់ពីមានការចាត់តាំងរបស់លោកប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ (ន.នគសអ) សិក្ខាសាលានេះបានប្រព្រឹត្តទៅ ដោយមានការថ្លែងសុន្ទរកថាស្វាគមន៍ដោយ លោកបណ្ឌិត **ម៉ុង ឡាមី** ប្រធានការិយាល័យគោលនយោបាយសារពើពន្ធ នៃ ន.នគសអ និងការថ្លែងសុន្ទរកថាបើកដោយលោក **ឌួង ពូលឡង់** មន្ត្រីជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច នៃ ADB ប្រចាំប្រទេសកម្ពុជា និងការធ្វើបទឧទ្ទេសដោយលោក Richard Stern ជំនាញការអន្តរជាតិផ្នែកពន្ធប្រយោល នៃ ADB និងលោក **សុង កុសល** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ។ សិក្ខាសាលានេះមានការចូលរួមពីលោក **ប៉ូ ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម លោក **អាន សំណាង** អនុប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ លោក លោកស្រីប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រីជំនាញពាក់ព័ន្ធនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ, ន.នគសអ, នាយកដ្ឋានសវនកម្មសហគ្រាស, នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ, នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីនៃ ADB ប្រចាំប្រទេសកម្ពុជា សរុបអ្នកចូលរួមប្រមាណ **៥០ រូប**។

ជាកិច្ចចាប់ផ្តើម តំណាងអគ្គនាយកដ្ឋានពន្ធដារ បានថ្លែងសុន្ទរកថាស្វាគមន៍ និងលើកឡើងពីសារៈសំខាន់នៃការផ្តល់ជំនួយបច្ចេករបស់ ADB រហូតដល់មានការរៀបចំសិក្ខាសាលាពង្រឹងសមត្ថភាពនេះ, មានជំនួយបច្ចេកទេសកន្លងមកដែលកំពុងដំណើរការក្រោមកិច្ចសហប្រតិបត្តិការរវាងអគ្គនាយកដ្ឋានពន្ធដារ និងADB, ការបង្កើតក្រុមការងារបទប្បញ្ញត្តិ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ, ការអនុវត្តអាករលើតម្លៃបន្ថែមលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងប្រទេសកម្ពុជា,

ការរៀបចំសិក្ខាសាលាក្នុងការចែករំលែកនូវចំណេះដឹង និងឧត្តមានុវត្តន៍នៃការអនុវត្តអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអេឡិចត្រូនិកដល់មន្ត្រីជំនាញពាក់ព័ន្ធ, កិច្ចខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគំនិតផ្តួចផ្តើមខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ក្នុងការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងការប្តេជ្ញាចិត្តដើម្បីប្រែក្លាយជារដ្ឋបាលសារពើពន្ធ ២.0 បូក នៅត្រឹមឆ្នាំ២០២៨ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ របស់អគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចបន្ទាប់ តំណាង ADB ប្រចាំប្រទេសកម្ពុជា បានថ្លែងសុន្ទរកថាបើកសិក្ខាសាលា ដោយថ្លែងអំណរគុណចំពោះអគ្គនាយកដ្ឋានពន្ធដារ ADB និង Japan Fund for Prosperous and Resilient Asia and the Pacific ដែលបានសហការរៀបចំសិក្ខាសាលានេះ និងលើកឡើងពីទិន្នន័យនៃការប្រើប្រាស់ Internet ក្នុងតំបន់អាស៊ីអាគ្នេយ៍, ការផ្លាស់ប្តូរបរិបទក្នុងការធ្វើការ ការទិញទំនិញ និងការកំសាន្តនានា នាំឱ្យមានបញ្ហាប្រឈមក្នុងការកំណត់ប្រភពចំណូលថ្មីៗ ក្នុងវិស័យពាណិជ្ជកម្មអេឡិចត្រូនិក និងបណ្តាលឱ្យមានការប្រកួតប្រជែងពុំស្មើភាពចំពោះអ្នកផ្គត់ផ្គង់ក្នុងស្រុក, ភាពចាំបាច់ក្នុងការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយលើការអនុវត្តអាករលើតម្លៃបន្ថែមលើពាណិជ្ជកម្មអេឡិចត្រូនិក និងការអនុវត្តយ៉ាងល្អប្រសើររបស់ប្រទេសកម្ពុជា ក្នុងការចាប់ផ្តើមអនុវត្តអាករលើតម្លៃបន្ថែមលើពាណិជ្ជកម្មអេឡិចត្រូនិក នាឆ្នាំ២០២១។

សិក្ខាសាលារយៈពេល ២ថ្ងៃ បានបន្តដោយមានការធ្វើបទបង្ហាញពីជំនាញការរបស់ ADB និងមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ ជាមួយនឹងការជជែកពិភាក្សាយ៉ាងផុសផុល និងការឆ្លើយបំភ្លឺយ៉ាងក្បោះក្បាយលើប្រធានបទសំខាន់ៗ ដូចជា ១.ការយកពន្ធលើសេដ្ឋកិច្ចឌីជីថល ២.អាករលើតម្លៃបន្ថែមដែលបានអនុវត្តចំពោះប្រតិបត្តិការឆ្លងកាត់ព្រំដែន ៣.ភាពចាំបាច់ក្នុងគោលនយោបាយអាករលើតម្លៃបន្ថែម ដើម្បីបើកឱ្យមាននូវការកំណត់ពន្ធលើប្រតិបត្តិការឆ្លងកាត់ព្រំដែន ៤.រដ្ឋបាលនៃអាករលើតម្លៃបន្ថែមឆ្លងកាត់ព្រំដែន ៥.ការប្រើប្រាស់ប្រភពទិន្នន័យដើម្បីធានាបាននូវអនុលោមភាព ៦.យន្តការក្នុងការពង្រឹងអនុលោមភាព ៧.អភិក្រមនៃរដ្ឋបាលសារពើពន្ធឌីជីថល និង ៨.ករណីសិក្សាអំពីអាករលើតម្លៃបន្ថែមក្នុងវិស័យទេសចរណ៍៕








# សិក្ខាសាលាស្តីពី "ពន្ធលើប្រាក់ចំណូលនិងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)"



នាព្រឹកថ្ងៃសុក្រ ទី២២ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅសាលាខេត្តកំពត អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាស្តីពី "ពន្ធលើប្រាក់ចំណូលនិងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)" សម្រាប់សហគ្រាសអ្នកជាប់ពន្ធមធ្យមនៅក្នុងខេត្តកំពត ក្រោមអធិបតីភាពឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងឯកឧត្តម **ចាន់ ថា** អភិបាលរង នៃគណៈអភិបាលខេត្តកំពត តំណាងឯកឧត្តមបណ្ឌិត **ម៉ៅ ធនិន** អភិបាល នៃគណៈអភិបាលខេត្តកំពត ដោយមានការអញ្ជើញចូលរួមពីលោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម លោកប្រធានសាខាពន្ធដារខេត្តកំពត តំណាងមកពីមន្ទីរជុំវិញខេត្តកំពត ស្នងការនគរបាលខេត្ត កងរាជអាវុធហត្ថខេត្ត តំបន់ប្រតិបត្តិការសឹករងកំពត ព្រមទាំងអ្នកជាប់ពន្ធចំនួន **២៣០ រូប**។

សិក្ខាសាលានេះ រៀបចំឡើងដោយមានការធ្វើបទបង្ហាញលើប្រធានបទសំខាន់ៗចំនួន ៣ គឺ ១.បទបង្ហាញស្តីពី "ការបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូល" ដែលមានលោក **ម៉ា បូរ៉ា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ជាវាគ្មិន ២.បទបង្ហាញស្តីពី "ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ" ដែលមានលោក **គង់ គីរី** អនុប្រធានការិយាល័យនៃនាយកដ្ឋានសវនកម្មសហគ្រាស ជាវាគ្មិន និង ៣.បទបង្ហាញស្តីពី "ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing)" ដែលមានលោក **សុធី គីរី** អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ជាវាគ្មិន។

បន្ទាប់ពីមតិស្វាគមន៍របស់លោកប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងចំណាប់អារម្មណ៍របស់ឯកឧត្តមអភិបាលរងនៃគណៈអភិបាលខេត្តកំពតរួចមក ឯកឧត្តមអគ្គនាយករង បានថ្លែងសុន្ទរកថាបើកសិក្ខាសាលា ដោយបានសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងការវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់ឧកញ៉ា លោក លោកស្រី

អ្នកនាង កញ្ញា ដែលបានអញ្ជើញចូលរួមក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នេះ។ វត្តមានរបស់ឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា គឺជាការឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការគោរពប្រតិបត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ជាពិសេស គឺដើម្បីឈ្វេងយល់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀត ចំពោះការអនុវត្តកាតព្វកិច្ចសារពើពន្ធ ក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន។ ឯកឧត្តមអគ្គនាយករង បានលើកឡើងអំពីសារៈសំខាន់ និងភាពងាយស្រួលក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ តាមអនឡាញ (ToI e-Filing)។ បន្ថែមពីនេះ ឯកឧត្តមអគ្គនាយករង បានលើកឡើងថាអគ្គនាយកដ្ឋានពន្ធដារ បានរៀបចំនិងអនុវត្តការផ្តល់សេវាអ្នកជាប់ពន្ធ តាមរយៈសកម្មភាពជាច្រើននិងគ្រប់មធ្យោបាយ ដោយអនុលោមតាមមាត្រា ១៩៣ នៃច្បាប់ស្តីពីសារពើពន្ធ ដែលបានចែងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ។ មាត្រា ១៩៣ នេះ ចែងថា "អ្នកជាប់ពន្ធមានសិទ្ធិទទួលព័ត៌មានជាប្រចាំអំពីដំណើរការនៃប្រព័ន្ធពន្ធដារនិងនីតិវិធីនៃការកំណត់ពន្ធ ដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ មាត្រា ១៩៩ អំពីការផ្សព្វផ្សាយនិងការពន្យល់ណែនាំបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា ២១១ អំពីនីតិវិធីនៃការកំណត់ពន្ធឡើងវិញ"។

ឯកឧត្តមអគ្គនាយករងបានគូសរំលេចថា ការបង់ពន្ធគឺជាកាតព្វកិច្ច ហើយការយកពន្ធគឺជាការផ្តល់នូវធនធានដ៏ចាំបាច់ដល់រាជរដ្ឋាភិបាលក្នុងការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា។ ឯកឧត្តមក៏បានលើកឡើងដែរថា ទំនាក់ទំនងរវាងអ្នកជាប់ពន្ធនិងរដ្ឋបាលសារពើពន្ធ គឺមិនត្រឹមតែជាការបំពេញកាតព្វកិច្ចសារពើពន្ធ និងការផ្តល់សេវាពន្ធដារប៉ុណ្ណោះទេ ប៉ុន្តែជាដៃគូសហការល្អ ក្នុងការចូលរួមចំណែកកសាងនិងអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើនទៅមុខបន្ថែមទៀត។ បន្ថែមពីនេះ ឯកឧត្តម ក៏បានលើកឡើងពីលក្ខណសម្បត្តិ ៤ យ៉ាងសំខាន់ៗរបស់មន្ត្រីរាជការ និងពលរដ្ឋល្អ។ មន្ត្រីរាជការល្អត្រូវមាន ១.ឥរិយាបថរួសរាយរាក់ទាក់ និងមានឆន្ទៈក្នុងការផ្តល់សេវា ២.សមត្ថភាពពេញលេញលើផ្នែកច្បាប់និងបទប្បញ្ញត្តិ ជំនាញ និងបទពិសោធ ៣.ក្រមសីលធម៌ វិជ្ជាជីវៈ និង៤.សិល្បៈក្នុងការពន្យល់ និងដោះស្រាយបញ្ហា។ ដោយឡែក ពលរដ្ឋល្អត្រូវមានលក្ខណសម្បត្តិ ដូចជា ១.មានក្រមសីលធម៌ល្អក្នុងសង្គម ២.គោរពច្បាប់ ៣.សិក្សា និងឈ្វេងយល់ជាប្រចាំ និង៤.សហការសាមគ្គី និងគោរពសិទ្ធិគ្នាទៅវិញទៅមក។

ជាមួយគ្នានេះ ដើម្បីចូលរួមនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ ឆ្នាំ២០២៣-២០២៨ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងនិងប្រតិបត្តិជាបន្តបន្ទាប់ និងព្យាយាមវិវត្តទៅជារដ្ឋបាលសារពើពន្ធទំនើបស្របតាមឧត្តមានុវត្តន៍តំបន់និងអន្តរជាតិ និងបរិការណ៍សង្គម-សេដ្ឋកិច្ចឌីជីថល ដើម្បីកែលម្អសេវាអ្នកជាប់ពន្ធ និងលើកកម្ពស់វប្បធម៌ការបង់ពន្ធ និងពង្រឹងអនុលោមភាពសារពើពន្ធ ព្រមទាំងចូលរួមចំណែកលើកកម្ពស់ការប្រកួតប្រជែងដោយស្មើភាពជូនវិស័យឯកជន។ ជាក់ស្តែង អគ្គនាយកដ្ឋានពន្ធដារបានរៀបចំដាក់ឱ្យអ្នកជាប់ពន្ធអនុវត្តនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាច្រើន ដើម្បីសម្រួលដល់ការបង់ពន្ធ និងពង្រឹងការគ្រប់គ្រងទិន្នន័យពន្ធ សំដៅធានានូវតម្លាភាព គណនេយ្យភាព សមធម៌នៃការបង់ពន្ធ និងជំរុញអនុលោមភាពសារពើពន្ធ ក្នុងនោះរួមមានដូចជា e-Register, e-Filing, ToI e-Filing, e-Payment, e-Tax Service, GDT Taxpayer App, GDT Live Chat, Call Center 1277, GDT e-Administration និងប្រព័ន្ធកម្មវិធីបច្ចេកវិទ្យាព័ត៌មានគាំទ្រជាច្រើនទៀត។ ឯកឧត្តម បានណែនាំដល់សិក្ខាកាមទាំងអស់ឱ្យយកចិត្តទុកដាក់ស្តាប់ និងកត់ត្រា ដើម្បីផ្តល់ជាពុទ្ធិបន្ថែមក្នុងការបំពេញកាតព្វកិច្ចពន្ធលើប្រាក់ចំណូល៕

# សិក្ខាសាលាស្តីពី "សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing)"



នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាស្តីពី "សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing)" សម្រាប់សហគ្រាសអ្នកជាប់ពន្ធមធ្យមដែលបានចុះបញ្ជីពន្ធដារថ្មីៗ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខណ្ឌដូនពេញ ខណ្ឌមានជ័យ ខណ្ឌ៧មករា ខណ្ឌឫស្សីកែវ និងខណ្ឌពោធិ៍សែនជ័យ ក្រោមអធិបតីភាព ឯកឧត្តម **ហេង សុខណាង** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីលោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធ ព្រមទាំងអភិបាល បណ្ណាធិការ និងតំណាងសហគ្រាស សរុបចំនួន **២៩០ រូប**។

សិក្ខាសាលានេះ រៀបចំឡើងដោយមានការធ្វើបទបង្ហាញលើប្រធានបទសំខាន់ៗចំនួន ២ គឺ ១.បទបង្ហាញស្តីពី "សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងសៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ" មានលោក **ម៉ា បូរ៉ា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ជាវាគ្មិន និង២.បទបង្ហាញស្តីពី "ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing)" មានលោក **ស៊ីវ ស៊ុនហួច** អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ជាវាគ្មិន។

ឯកឧត្តម **ហេង សុខណាង** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ បានថ្លែងសុន្ទរកថាបើកសិក្ខាសាលា ដោយបានសម្តែងស្វាគមន៍យ៉ាងកក់ក្តៅ និងការវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់សិក្ខាកាមដែលបានអញ្ជើញចូលរួមក្នុងកម្មវិធីសិក្ខាសាលាដ៏មានសារប្រយោជន៍នេះ ដែលសបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការគោរពប្រតិបត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ជាពិសេសគឺដើម្បីឈ្វេងយល់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀត ចំពោះសិទ្ធិរបស់អ្នកជាប់ពន្ធដែលទទួលបាននិងកាតព្វកិច្ចសារពើពន្ធដែលអ្នកជាប់ពន្ធត្រូវអនុវត្ត។ ឯកឧត្តមអគ្គនាយករង

បានលើកឡើងអំពីសារៈសំខាន់ និងភាពងាយស្រួលក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) ជំនួសឱ្យការដាក់លិខិតប្រកាសពន្ធដោយដៃ ប៉ុន្តែទាមទារឱ្យអ្នកជាប់ពន្ធសិក្សាឈ្វេងយល់អំពីការប្រើប្រាស់ប្រព័ន្ធនេះឱ្យកាន់តែច្បាស់។ អ្នកជាប់ពន្ធត្រូវប្រើប្រាស់លេខទូរស័ព្ទនិងអ៊ីមែលឱ្យបានត្រឹមត្រូវសម្រាប់ការចុះបញ្ជីពន្ធដារ ចៀសវាងមានបញ្ហានៅពេលចូលប្រើប្រាស់ប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារនៅពេលក្រោយ ដោយហេតុថា ការប្រើប្រាស់ប្រព័ន្ធតម្រូវឱ្យមានការផ្ទៀងផ្ទាត់ជាមួយនឹងលេខទូរស័ព្ទឬអ៊ីមែលដែលប្រើប្រាស់នៅពេលចុះបញ្ជីពន្ធដារ។ ជាមួយគ្នានេះ ឯកឧត្តមអគ្គនាយករង បានជំរុញនិងលើកទឹកចិត្តសិក្ខាកាមទាំងអស់ចូលរួមប្រើប្រាស់កម្មវិធីវិក្កយបត្រនាំសំណាងរបស់អគ្គនាយកដ្ឋានពន្ធដារ (GDT Lucky Draw App) ដើម្បីទទួលបានឱកាសឈ្នះរង្វាន់ពីអគ្គនាយកដ្ឋានពន្ធដារ ដោយគ្រាន់តែបញ្ចូល (Upload) វិក្កយបត្រដែលលោក លោកស្រីទទួលបាននៅពេលទិញទំនិញឬសេវា។ ឯកឧត្តមអគ្គនាយករង បានស្នើម្ចាស់សហគ្រាសតូចនិងមធ្យម និងភ្នាក់ងារសេវាកម្មពន្ធដារ គួរយកចិត្តទុកដាក់ពង្រឹងជំនាញវិជ្ជាជីវៈពន្ធដារបន្ថែម ដោយចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលផ្សេងៗ នៅសាលាជាតិពន្ធដារ ជាពិសេសវគ្គបណ្តុះបណ្តាលភ្នាក់ងារសេវាកម្មពន្ធដារ ដែលអាចឱ្យអ្នកជាប់ពន្ធធ្វើការប្រកាសពន្ធបានត្រឹមត្រូវដោយខ្លួនឯងស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបាននិងកំពុងបន្តលើកទឹកចិត្តផ្នែកពន្ធដារលើវិស័យអចលនទ្រព្យ ជាអាទិ៍ ពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រា ពន្ធលើដីធ្លីមិនបានប្រើប្រាស់និងវិស័យអាទិភាពផ្សេងៗទៀត។ បន្ថែមពីនេះ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ចេញនូវកម្មវិធីពាក់ព័ន្ធនឹងទូរស័ព្ទដៃជាច្រើនដែលអគ្គនាយកដ្ឋានពន្ធដារបានបង្កើតឡើង និងជំរុញឱ្យអ្នកជាប់ពន្ធចូលរួមប្រើប្រាស់កម្មវិធីទាំងនេះ រួមមានកម្មវិធីរដ្ឋបាល អេឡិចត្រូនិកពន្ធដារ (GDT e-Administration) កម្មវិធីព័ត៌មានស្តីពីពន្ធដារ (GDT News App) កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App) កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (GDT Salary Tax Calculation) កម្មវិធីទូរស័ព្ទដៃត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track App) កម្មវិធីគណនាពន្ធមធ្យោបាយ (GDT Means of Transportation Tax Calculation) កម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ (GDT Live Chat App)។ យ៉ាងណាមិញ ឯកឧត្តមអគ្គនាយករង ក៏បានជំរុញនិងលើកទឹកចិត្តអ្នកជាប់ពន្ធឱ្យចូលរួមតាមដានកម្មវិធីពន្ធដារកម្ពុជា សិក្ខាសាលា កម្មវិធីរៀនអំពីពន្ធដារតាមអនឡាញ គេហទំព័រ និង Facebook Page របស់អគ្គនាយកដ្ឋានពន្ធដារ ដែលជាមធ្យោបាយដើម្បីទទួលបាននូវការផ្សព្វផ្សាយស្តីពីបទប្បញ្ញត្តិស្តីពីពន្ធដារ និងព័ត៌មានថ្មីៗ ព្រមទាំងបានរំលឹកបន្ថែមអំពីកាលបរិច្ឆេទផុតកំណត់នៃការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនប្រចាំឆ្នាំ២០២៤ គឺនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤។ ឯកឧត្តមអគ្គនាយករង មានជំនឿយ៉ាងមុតមាំថា សិក្ខាសាលាដ៏មានសារៈសំខាន់នេះនឹងរួមចំណែក លើកកម្ពស់ក្នុងការពង្រឹងការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់ម្ចាស់សហគ្រាសទាំងអស់ដែលបាននិងកំពុងប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេស អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារថ្មីក្នុងសាខាពន្ធដារខណ្ឌដូនពេញ ខណ្ឌមានជ័យ ខណ្ឌ៧មករា ខណ្ឌឫស្សីកែវ និងខណ្ឌពោធិ៍សែនជ័យ នឹងទទួលបាននូវចំណេះដឹងថ្មីបន្ថែមទៀត ស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ និងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) និងកាតព្វកិច្ចសារពើពន្ធប្រចាំខែនិងប្រចាំឆ្នាំផ្សេងៗទៀត សម្រាប់សហគ្រាសរបស់ឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ដើម្បីចូលរួមអនុវត្តការបង់ពន្ធឱ្យបានត្រឹមត្រូវ៕

# សិក្ខាសាលាផ្សព្វផ្សាយស្តីពី "អង្គភាពសវនកម្មពន្ធដារពិសេស និងបច្ចុប្បន្នភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ"




នាព្រឹកថ្ងៃអង្គារ ទី៣ ដល់ថ្ងៃពុធ ទី៤ ខែធ្នូ ឆ្នាំ២០២៤ នៅសាលប្រជុំជាន់ទី១០ នៃអគារសាលាជាតិពន្ធដារ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "អង្គភាពសវនកម្មពន្ធដារពិសេស និងបច្ចុប្បន្នភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ" ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សីហា** និងឯកឧត្តម **រ័ត្ន មុនី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងអភិបាល បណ្ណាធិការ និងតំណាងសហគ្រាសសរុបចំនួន **៥៥៦ រូប**។ សិក្ខាសាលានេះ មានប្រធានបទសំខាន់ៗចំនួន ២ គឺ បទបង្ហាញស្តីពី "អង្គភាពសវនកម្មពន្ធដារពិសេស" ដោយលោក **សៀង ស៊ីថា** ប្រធានអង្គភាពសវនកម្មពន្ធដារពិសេស ជាវាគ្មិន ធ្វើបទបង្ហាញនិងបកស្រាយ និងបទបង្ហាញស្តីពី "បច្ចុប្បន្នភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ" ដោយលោក **ឆាយ ជាហេង** អនុប្រធានអង្គភាពសវនកម្មពន្ធដារពិសេស ជាវាគ្មិន។

សិក្ខាសាលានេះ រៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយឱ្យបានជ្រាបច្បាស់អំពីអង្គភាពសវនកម្មពន្ធដារពិសេស ដែលជាអង្គភាពថ្មីទើបតែបង្កើតឡើងនិងការកែសម្រួលបទប្បញ្ញត្តិថ្មីៗរបស់អគ្គនាយកដ្ឋានពន្ធដារ។ គួរបញ្ជាក់ថា អង្គភាពសវនកម្មពន្ធដារពិសេស ត្រូវបានបង្កើតឡើងតាមរយៈអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ១៦០ អនក្រ.បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ និងប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ៥០៥ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤។ បន្ទាប់មក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញសេចក្តីណែនាំលេខ ០២៤ ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ ស្តីពីសហគ្រាសស្ថិតនៅក្រោមការធ្វើសវនកម្មរបស់អង្គភាពសវនកម្មពន្ធដារពិសេស។ អង្គភាពនេះ បង្កើតឡើងជាយន្តការជំរុញ និងពន្លឿនការដោះស្រាយបញ្ហានានារបស់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងការងារសវនកម្មពន្ធដារឱ្យបានឆាប់រហ័ស ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ សំដៅកែលម្អបរិយាកាសធុរកិច្ចនិងការវិនិយោគ។ ជាមួយគ្នានេះដែរ អង្គភាពនេះក៏ពិនិត្យនិងដោះស្រាយបញ្ហាដែលនៅសេសសល់ ឬពុំទាន់ត្រូវបានបញ្ចប់ពាក់ព័ន្ធនឹង

ការធ្វើសវនកម្មពន្ធដារកន្លងមក របស់សហគ្រាសដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចំពោះការបញ្ចូលសហគ្រាសឱ្យនៅក្រោមការធ្វើសវនកម្មរបស់អង្គភាពនេះ គឺជាសហគ្រាសដែលទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទមាស សហគ្រាសដែលស្នើសុំនិងសហគ្រាសដែលសម្រេចបញ្ចូលដោយថ្នាក់ដឹកនាំ (អគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **សម្តេចធិបតី នាយករដ្ឋមន្ត្រី**)។ បច្ចុប្បន្ន សហគ្រាសចំនួន **៣៨៧** ត្រូវបានជ្រើសរើសឱ្យស្ថិតក្រោមការធ្វើសវនកម្មរបស់អង្គភាពនេះ ដែលក្នុងនោះភាគច្រើនជាប្រភេទអ្នកជាប់ពន្ធធំនិងមួយចំនួនតូចជាអ្នកជាប់ពន្ធមធ្យម។ សហគ្រាសស្ថិតនៅក្រោមការធ្វើសវនកម្មរបស់អង្គភាពនេះ នៅតែមានកាតព្វកិច្ចដាក់លិខិតប្រកាសតាមអនឡាញ (e-Filing) និងបង់ប្រាក់ពន្ធ ព្រមទាំងទទួលសេវាដទៃទៀត ដូចជាសេវាអ្នកជាប់ពន្ធបំណុលពន្ធ និងការបង្វិលសងអាករលើតម្លៃបន្ថែមជាដើម នៅតាមអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធ (នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធដារខេត្ត-ខណ្ឌ) ដដែល ដោយគ្រាន់តែការធ្វើសវនកម្ម ត្រូវស្ថិតនៅក្រោមអង្គភាពសវនកម្មពន្ធដារពិសេស ហើយអង្គភាពដទៃទៀតមិនអាចធ្វើសវនកម្មទៀតបានទេ។ ពិសេសជាងនេះទៅទៀត ការធ្វើសវនកម្មនេះ គឺជាការធ្វើសវនកម្មពេញលេញតែ **១ លើក** ប៉ុណ្ណោះ សម្រាប់ការិយបរិច្ឆេទនីមួយៗ ដោយពុំចាំបាច់ធ្វើសវនកម្មលើលិខិតស្នាម និងសវនកម្មមានកម្រិតឡើយ។ ម៉្យាងទៀត សហគ្រាសដែលត្រូវជ្រើសរើសធ្វើសវនកម្មដោយអង្គភាពនេះ គឺចំពោះតែសហគ្រាសដែលមានហានិភ័យ ឬភាពមិនប្រក្រតីនៃការប្រកាសបង់ពន្ធរបស់សហគ្រាសតែប៉ុណ្ណោះ។

ក្នុងឱកាសនោះដែរ ឯកឧត្តមអគ្គនាយករង បានលើកឡើងត្រួសៗអំពីបច្ចុប្បន្នភាពនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ដែលកន្លងមក រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការចងក្រងច្បាប់ស្តីពីសារពើពន្ធ ដោយបញ្ចូលប្រភេទពន្ធទាំងអស់ ដែលនៅរាយប៉ាយផ្សេងៗគ្នា ឱ្យស្ថិតនៅក្នុងច្បាប់ស្តីពីសារពើពន្ធតែមួយ និងបានកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពន្ធដារមួយចំនួន ក្នុងគោលបំណងដើម្បីធ្វើឱ្យមានភាពងាយស្រួលនិងច្បាស់លាស់ (Simplification) បង្កើនចំណូលពន្ធ (Tax Revenue) បន្ថយការគេចវេះពន្ធ (Tax Evasion) ស្មើភាពក្នុងការប្រកួតប្រជែង (Equity and Fairness) ទាក់ទាញការវិនិយោគ និងជួយសម្រួលដល់ជីវភាពកម្មករនិងមន្ត្រីរាជការ។ ការកែទម្រង់នេះ មានចំណុចសំខាន់ៗមួយចំនួន រួមមាន៖ ការកែសម្រួលអត្រាអាករសម្រាប់បំភ្លឺសាធារណៈ ពន្ធលើប្រាក់បៀវត្ស ពន្ធលើប្រាក់ចំណូល អាករលើតម្លៃបន្ថែម ការលើកទឹកចិត្តពន្ធដារតាមច្បាប់ស្តីពីវិនិយោគជាដើម៕



# សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចការអនុវត្តវិធាននៃការប្រើប្រាស់វិក្កយបត្រ" និង "កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw)"



នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៥ ខែធ្នូ ឆ្នាំ២០២៤ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចការអនុវត្តវិធាននៃការប្រើប្រាស់វិក្កយបត្រ" និង "កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)" ក្រោមអធិបតីភាពលោក **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ តំណាងឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងសិក្ខាកាមដែលជាតំណាងសហគ្រាស តាមរយៈតំណភ្ជាប់តាមប្រព័ន្ធអនឡាញ Zoom Link សរុបចំនួនប្រមាណ **២៣៨ រូប**។

ជាកិច្ចស្វាគមន៍ លោក **អេង រតនា** បានសម្តែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ដែលបានចូលរួមក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នេះ។ កន្លងមកនេះ ក្នុងនាមអគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ បានរៀបចំសិក្ខាសាលាធ្វើការផ្សព្វផ្សាយ ពន្យល់ ណែនាំនិងធ្វើកំណត់ហេតុពាក់ព័ន្ធនឹងវិធាននៃការប្រើប្រាស់វិក្កយបត្រ ព្រមទាំងបានរៀបចំសិក្ខាសាលាពាក់ព័ន្ធ នឹងប្រធានបទនេះ ចំនួន ៤ លើក រួចមកហើយ ដែលនៅក្នុងឆ្នាំ២០២៣ ចំនួន ២ លើក និងនៅក្នុងឆ្នាំ២០២៤ នេះ ចំនួន ២ លើក។ ការរៀបចំសិក្ខាសាលានេះឡើង ក្នុងគោលដៅផ្សព្វផ្សាយដល់អ្នកជាប់ពន្ធឱ្យបានយល់ដឹងអំពីកាតព្វកិច្ចក្នុងការចេញវិក្កយបត្រលើរាល់ការផ្គត់ផ្គង់ទំនិញឬសេវាឱ្យបានត្រឹមត្រូវ ស្របតាមវិធាននៃការប្រើប្រាស់វិក្កយបត្រ។ សិក្ខាសាលានេះ មានគោលដៅដើម្បីពង្រឹងការគ្រប់គ្រងប្រមូលចំណូលសារពើពន្ធប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ព្រមទាំងធានាដល់យន្តការផ្ទៀងផ្ទាត់វិក្កយបត្រឱ្យកាន់តែច្បាស់លាស់ ក៏ដូចជាសម្របសម្រួលដល់ការអនុវត្តការបង្វិលសងអាករលើតម្លៃបន្ថែមឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ផ្ទៀតក្នុងឱកាសនេះ លោកប្រធាននាយកដ្ឋាន ក៏បានបញ្ជាក់បន្ថែមថា ការមិនចេញវិក្កយបត្រ ឬចេញវិក្កយបត្រមិន

ត្រឹមត្រូវឬក្លែងបន្លំ ត្រូវចាត់ទុកជាអំពើរាំងស្ទះក្នុងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា ២២៥ និងត្រូវទទួលរងនូវទោសទណ្ឌដូចមានចែងក្នុងមាត្រា ២៣៥ និងមាត្រា២៤៣ នៃច្បាប់ស្តីពីសារពើពន្ធ ការបិទអាជីវកម្មក្នុងរយៈពេលដោយច្បាប់ការកំណត់ពន្ធឡើងវិញ ឬការប្តឹងចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិ ស្តីពីពន្ធដារដែលត្រូវផ្តន្ទាទោសជាប្រាក់រហូតដល់ ១០០ ០០០ ០០០ រៀល ឬជាប់ពន្ធនាគាររហូតដល់ ១ឆ្នាំ ឬទោសទាំងពីរនេះ។

បន្ថែមពីនេះទៀត លោកប្រធាននាយកដ្ឋាន ក៏បានលើកឡើងអំពីកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App) ដែលអនុញ្ញាតឱ្យសាធារណជនធ្វើការបញ្ចូលវិក្កយបត្របានមកពីការទិញទំនិញឬប្រើប្រាស់សេវាផ្សេងៗ ដោយគ្រាន់តែថតវិក្កយបត្រនិងបង្ហោះចូលកម្មវិធី GDT Lucky Draw ដើម្បីចូលរួមផ្សងសំណាងនិងឈ្នះរង្វាន់ជាច្រើនពីកម្មវិធីចាប់រង្វាន់ផ្សងសំណាងពីកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App) របស់អគ្គនាយកដ្ឋានពន្ធដារ។ គិតចាប់តាំងពីដាក់ឱ្យដំណើរការកម្មវិធីនេះរហូតមកដល់ពេលបច្ចុប្បន្ន ក្រុមការងារគ្រប់គ្រងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App) បានទទួលវិក្កយបត្រដែលបានផ្ញើមកចូលរួមផ្សងសំណាង មានសរុបចំនួន **១ ៥៧៦ ៧១៣ វិក្កយបត្រ** ក្នុងនោះមានវិក្កយបត្រត្រឹមត្រូវមានចំនួន **១ ៥១៥ ៨០៩ វិក្កយបត្រ** និងវិក្កយបត្រមិនត្រឹមត្រូវមានចំនួន **៦០ ៩០៤ វិក្កយបត្រ**។ នាពេលថ្មីនេះ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកម្មវិធីប្រគល់រង្វាន់ដល់អ្នកដែលមានសំណាងឈ្នះរង្វាន់ពីកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App) ដែលបានចាប់រង្វាន់កាលពីថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៤ សរុបចំនួន **៤០ រង្វាន់** ហើយការប្រគល់រង្វាន់នេះ ជាការប្រគល់រង្វាន់លើកទី៣ ផងដែរ។

ជាកិច្ចបន្ទាប់ វាគ្មិនបានធ្វើបទបង្ហាញស្តីពី "កាតព្វកិច្ចការអនុវត្តវិធាននៃការប្រើប្រាស់វិក្កយបត្រ" និង "កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)" ដើម្បីធ្វើការផ្សព្វផ្សាយ និងពន្យល់ណែនាំលម្អិតជូនសិក្ខាកាមអំពីការប្រើប្រាស់វិក្កយបត្រឱ្យត្រឹមត្រូវស្របទៅតាមវិធាននៃការប្រើប្រាស់វិក្កយបត្រ និងការប្រើប្រាស់កម្មវិធី GDT Lucky Draw។ នៅក្នុងសិក្ខាសាលានេះដែរ សិក្ខាកាមបានចូលរួមជជែកពិភាក្សានិងមានការលើកជាសំណួរយ៉ាងច្រើនផុសផុល ព្រមទាំងទទួលបានការបកស្រាយនូវចម្ងល់ផ្សេងៗពីវាគ្មិន។

មុននឹងបញ្ចប់ លោកប្រធាននាយកដ្ឋាន បានស្នើសុំឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ដែលជាតំណាងសហគ្រាសទាំងអស់ ចូលរួមបំពេញកាតព្វកិច្ចសារពើពន្ធក្នុងការចេញវិក្កយបត្រនិងបង់ប្រាក់ពន្ធឱ្យបានត្រឹមត្រូវ ព្រមទាំងបានធ្វើការក្រើនរំលឹកដល់សិក្ខាកាមទាំងអស់ក្នុងការរៀបចំរបាយការណ៍បិទបញ្ជី និងដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២៤ នាពេលខាងមុខនេះ ឱ្យបានទាន់ពេលកំណត់តាមរយៈការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) ដែលមានកាលបរិច្ឆេទចាប់ពីថ្ងៃទី១ ខែមករា រហូតដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥។ ក្នុងករណី មានសំណួរឬចម្ងល់ផ្សេងៗ សូមទាក់ទងជាមួយការិយាល័យសេវាអ្នកជាប់ពន្ធ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬអាចទូរស័ព្ទមក Call Center-1277 ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android ៕

# សិក្ខាសាលាស្តីពី "ការវិនិយោគនៅកម្ពុជា (Invest-in-Cambodia)"




នាព្រឹកថ្ងៃអង្គារ ទី១០ ខែធ្នូ ឆ្នាំ២០២៤ តបតាមការអញ្ជើញរបស់ការិយាល័យសេវាកម្មពន្ធដារខេត្តហៃណាន នៃរដ្ឋបាលសារពើពន្ធ សាធារណរដ្ឋប្រជាមានិតចិន តាមប្រព័ន្ធអនឡាញ និងដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម **គន់ ឋិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ដែលដឹកនាំដោយលោក **សេខ ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ និងការចូលរួមពីសហការីពាក់ព័ន្ធនៃនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ រៀបចំសិក្ខាសាលាស្តីពី "ការវិនិយោគនៅកម្ពុជា (Invest-in-Cambodia)"។ ក្នុងសិក្ខាសាលានេះផងដែរក៏មានការចូលរួមពីលោក Huang Suhua ប្រធាននាយកដ្ឋានស្តីទី នៃនាយកដ្ឋានពន្ធអន្តរជាតិ នៃរដ្ឋបាលសារពើពន្ធសាធារណរដ្ឋប្រជាមានិតចិន និងសហការី តំណាងស្ថានអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងហៃគូ ព្រមទាំងតំណាងសហគ្រាសចិន សរុបចំនួន **១៤០ រូប**។

ក្នុងចំណាប់អារម្មណ៍បើកអង្គសិក្ខាសាលា លោក Huang Suhua បានថ្លែងអំណរគុណដល់អគ្គនាយកដ្ឋានពន្ធដារដែលបានសហការរៀបចំសិក្ខាសាលានេះឡើង។ លោកក៏បានលើកឡើងផងដែរថា សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងជួយសម្រួលដល់សហគ្រាសចិន ដើម្បីទទួលបានការយល់ដឹងឱ្យបានទូលំទូលាយអំពីប្រព័ន្ធពន្ធដារកម្ពុជា។ នៅក្នុងឱកាសនៃអង្គសិក្ខាសាលានេះ លោក **សេខ ជាសិទ្ធ** ក៏បានថ្លែងចំណាប់អារម្មណ៍ដោយគូសរំលេចអំពីការធ្វើកំណែទម្រង់ប្រព័ន្ធពន្ធដារកម្ពុជា ដើម្បីផ្តល់ភាពប្រាកដប្រជានិងងាយស្រួលដល់វិនិយោគិនក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ តាមរយៈការធ្វើទំនើបកម្មនៃប្រព័ន្ធដាក់លិខិតប្រកាសតាមអនឡាញ ការដាក់ចេញនូវសៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ និងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ ព្រមទាំងការចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការផ្នែកពន្ធដារអន្តរជាតិ ដូចជាការចូលជាសមាជិកក្រុមសិក្សាស្តីពីរដ្ឋបាលសារពើពន្ធអាស៊ីប៉ាស៊ីហ្វិកនិងការស្រាវជ្រាវ (SGATAR) យន្តការនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការពន្ធដារ (BRITACOM) ព្រមទាំងវេទិកាសកលស្តីពីតម្លាភាពនិងការផ្លាស់ប្តូរព័ត៌មានដើម្បីគោលបំណងពន្ធ (Global Forum)។ លោកក៏បានលើកឡើងបន្ថែមទៀតជូនអង្គសិក្ខាសាលា

ជាពិសេសវិនិយោគិនចិននូវកិច្ចការសំខាន់ៗមួយចំនួនទៀតដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងធ្វើដើម្បីបង្កបរិយាកាសទាក់ទាញដល់វិនិយោគិនបរទេស ជាអាទិ៍ ការបន្តអភិវឌ្ឍហេដ្ឋារចនា សម្ព័ន្ធរូបវន្ត និងការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ជាដើម។

ជាកិច្ចបន្ទាប់ លោក **ស៊ិន សំណាង** ប្រធានការិយាល័យនីតិកម្ម នៃនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ បានធ្វើបទបង្ហាញស្តីពីប្រព័ន្ធពន្ធដារកម្ពុជា ដោយបានផ្តោតទៅលើចំណុចសំខាន់ៗ រួមមាន ការបែងចែកថ្នាក់សម្រាប់អ្នកជាប់ពន្ធតូច មធ្យម និងធំ ប្រភេទពន្ធ វិធានការទប់ស្កាត់ការចៀសវាងពន្ធ ( Anti-avoidance Rules ) និងកិច្ចសហប្រតិបត្តិការផ្នែកពន្ធដារ ផងដែរ។

ក្នុងសិក្ខាសាលានេះ ក៏មានរៀបចំវេទិកាជជែកពិភាក្សានិងសំណួរចម្លើយ ដែលភាគីពន្ធដារ កម្ពុជា មានលោក **សេង ជាសិទ្ធ** បានដឹកនាំក្នុងការបកស្រាយបំភ្លឺនូវរាល់ចម្ងល់និងបញ្ហាផ្សេងៗរបស់អ្នកចូលរួម ដែលជាវិនិយោគិនចិនពាក់ព័ន្ធនឹងអត្ថប្រយោជន៍មួយចំនួនទាក់ទិននឹងការលើកទឹកចិត្តផ្នែកពន្ធដារ ជាពិសេស ក្រោមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ ជាកិច្ចបញ្ចប់ តំណាងរដ្ឋបាលសារពើពន្ធ សាធារណរដ្ឋប្រជាមានិតចិន បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អគ្គនាយកដ្ឋានពន្ធដារ ដែលបានចូលរួមផ្តល់ជាបទបង្ហាញនិងឆ្លើយនឹងសំណួររបស់វិនិយោគចិន នៅក្នុងសិក្ខាសាលានេះ៕



*លោក **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ*





# សិក្ខាសាលាផ្សព្វផ្សាយស្តីពី "សៀវភៅណែនាំ (SOP) ស្តីពីពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រា ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើដីធ្លីមិនបានប្រើប្រាស់"



នាព្រឹកថ្ងៃពុធ ទី១៨ ខែធ្នូ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ "សៀវភៅណែនាំ (SOP) ស្តីពីពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រា ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើដីធ្លីមិនបានប្រើប្រាស់" សម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារ តាមប្រព័ន្ធអនឡាញ (Zoom Meeting) ក្រោមអធិបតីភាពឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីលោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម លោក លោកស្រី ថ្នាក់ដឹកនាំនៃនាយកដ្ឋានថ្នាក់កណ្តាល ទីចាត់ការពន្ធដាររាជធានីភ្នំពេញ សាលាជាតិពន្ធដារ អង្គភាពសវនកម្មពន្ធដារពិសេស និងសាខាពន្ធដារខេត្ត-ខណ្ឌ ព្រមទាំងមន្ត្រីរាជការពន្ធដារចំនួន **២១០ រូប**។

សិក្ខាសាលានេះ រៀបចំឡើងក្រោមប្រធានបទសំខាន់ៗចំនួន ៥ រួមទាំងមានវាគ្មិន ធ្វើបទបង្ហាញនិងបកស្រាយ រួមមាន ១.បទបង្ហាញស្តីពី "ពន្ធលើអចលនទ្រព្យ និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើអចលនទ្រព្យ" ដោយលោក **សុវណ្ណ សម្បូណ៌** ប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ ២.បទបង្ហាញស្តីពី "ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើដីធ្លីមិនបានប្រើប្រាស់" ដោយលោក **ប៉ែន ពេជ្រដារ៉ូ** អនុប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ ៣.បទបង្ហាញស្តីពី "ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ" ដោយលោក **ហុក សុខហេង** អនុប្រធានការិយាល័យនៃសាខាពន្ធដារខណ្ឌចំការមន ៤.បទបង្ហាញស្តីពី "ពន្ធប្រថាប់ត្រា និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធប្រថាប់ត្រា" ដោយលោក **ង៉ែត មីជូ** និងលោក **ជួប ចាន់ដារ៉ា** អនុប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ

ព្រមទាំងលោក **ប៉ុម វន្ថា** អនុប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និង៥.បទបង្ហាញស្តីពី "ពន្ធលើមធ្យោបាយដឹកជញ្ជូន និងបែបបទនិងនីតិវិធីនៃការអនុវត្តពន្ធលើមធ្យោបាយដឹកជញ្ជូន" ដោយលោក **យិន សុធារី** ប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ ។

ជាកិច្ចចាប់ផ្តើម លោកប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យមបានផ្តល់មតិស្វាគមន៍ និងគូសបញ្ជាក់អំពីសារៈតារនៃការរៀបចំសៀវភៅណែនាំទាំងនេះ ដោយបានលើកឡើងថា សៀវភៅទាំងអស់នេះ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំពិភាក្សាជាច្រើនលើកច្រើនសាទាំងកម្រិតបច្ចេកទេស កម្រិតអគ្គនាយកដ្ឋានពន្ធដារ កម្រិតវិស័យឯកជន និងកម្រិតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបានដាក់ឆ្លងនិងស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីដាក់ឱ្យប្រើប្រាស់និងផ្សព្វផ្សាយជាផ្លូវការជូនមន្ត្រីពន្ធដារ វិស័យឯកជន អ្នកជាប់ពន្ធ និងសាធារណជន។

បន្ទាប់ពីមតិស្វាគមន៍របស់លោកប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ឯកឧត្តមអគ្គនាយករង បានថ្លែងសុន្ទរកថាបើកសិក្ខាសាលា ដោយបានសម្តែងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់លោក លោកស្រីថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារដែលបានចូលរួមក្នុងសិក្ខាសាលានេះ គឺឆ្លុះបញ្ចាំង ឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការគោរពវិន័យការងារ និងការឈ្វេងយល់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀតនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ជាពិសេស វឌ្ឍនភាពថ្មីៗ នៃបទប្បញ្ញត្តិស្តីពីពន្ធដារដែលពាក់ព័ន្ធនឹងប្រភេទពន្ធមួយចំនួន ដូចជាពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រា ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដើម្បីទទួលបាននូវចំណេះដឹង និងចំណេះធ្វើបន្ថែមទៀតយកទៅអនុវត្តការងារ។ ឯកឧត្តមអគ្គនាយករងក៏បានសម្តែងនូវមូលវិចារណ៍ដ៏ថ្លៃថ្លាចំពោះថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ សាខាពន្ធដារខេត្ត-ខណ្ឌ អង្គភាពពាក់ព័ន្ធផ្សេងៗ និងជាពិសេសលោកប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ដែលកន្លងមកបានដឹកនាំ ចាត់ចែង សម្របសម្រួល និងសហការគ្នារៀបចំសៀវភៅណែនាំ (SOP) ចំនួន ៥ នេះ ដោយទទួលបានជោគជ័យ និងទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី**សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ដាក់ឱ្យប្រើប្រាស់និងផ្សព្វផ្សាយជាផ្លូវការ។

នៅក្នុងសិក្ខាសាលានេះដែរ ឯកឧត្តមអគ្គនាយករង បានលើកឡើងថាសៀវភៅណែនាំទាំងនេះនឹងចូលរួមលើកកម្ពស់ការប្រមូលពន្ធទាំងនេះប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងស័ក្តិសិទ្ធិភាពស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។ ឯកឧត្តមអគ្គនាយករង ក៏បានបន្តទៀតថារាជរដ្ឋាភិបាល នៅតែបន្តអនុវត្តគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធដារ ដែលក្នុងនោះរួមមាន ១.លើកលែងប្រាក់ពន្ធ និងទណ្ឌកម្មរដ្ឋបាលចំពោះពន្ធលើអចលនទ្រព្យសម្រាប់ដីកសិកម្មដែលប្រជាពលរដ្ឋកំពុងបង្កបង្កើនផល និងបន្តលើកលែងទណ្ឌកម្ម រដ្ឋបាលចំពោះអចលនទ្រព្យ ដែលពុំធ្លាប់បានចុះបញ្ជីឬបានចុះបញ្ជី និងបានប្រកាសបង់ពន្ធឬខកខានពុំបានប្រកាសបង់ពន្ធក្នុងឆ្នាំមុនៗ ដល់បំណាច់ឆ្នាំ២០២៥ ២.ពន្ធលើដីធ្លីមិនបានបើប្រាស់ត្រូវបានព្យួរការអនុវត្តរហូតដល់ដំណាច់ឆ្នាំ២០២៤ និងលើកលែងពន្ធលើដីធ្លីមិនបានប្រើប្រាស់ចំពោះដីដែលមានផ្ទៃក្រឡាតិចជាងឬស្មើ ៥ ហិកតា សម្រាប់ដីមួយកន្លែង ៣.អនុគ្រោះពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិកាន់កាប់លំនៅឋានគ្រប់ប្រភេទដែលមានលក្ខណៈជាបុរី ដែលមានតម្លៃក្រោម ឬស្មើ ៧ ម៉ឺនដុល្លារ រហូតដល់ដំណាច់ឆ្នាំ២០២៥ និង៤.បន្តពន្យារពេលការអនុវត្តពន្ធលើចំណេញមូលធន

លើរូបវន្តបុគ្គលចំពោះអចលនទ្រព្យរហូតដល់ដំណាច់ឆ្នាំ២០២៥។

បន្ថែមពីនេះ ឯកឧត្តមអគ្គនាយករង បានបញ្ជាក់ថាការរៀបចំសិក្ខាសាលានេះ គឺចូលរួមចំណែកក្នុងការកែទម្រង់ផ្នែកធនធានមនុស្ស ដែលមានការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ពីសំណាក់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឯកឧត្តម **គង់ ទិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងស្របតាមផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានសមត្ថភាព ចំណេះដឹង ទេពកោសល្យ និងឥរិយាបថល្អក្នុងការបំពេញភារកិច្ចដែលបានប្រគល់ជូនប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ ដើម្បីចូលរួមធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ បង្កើនផលិតភាព និងប្រសិទ្ធភាពការងារ។ ក្នុងការអភិវឌ្ឍធនធានមនុស្ស ស្ត្រីដែលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានយកចិត្តទុកដាក់ និងលើកទឹកចិត្តពីសំណាក់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារតាមរយៈការផ្តល់នូវវគ្គបណ្តុះបណ្តាល ដូចជាវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំស្ត្រី និងវគ្គបណ្តុះបណ្តាលផ្សេងទៀត ដើម្បីលើកកម្ពស់សមត្ថភាព និងផ្តល់ឱកាសឱ្យស្ត្រីអាចក្លាយជាថ្នាក់ដឹកនាំនៅតាមនាយកដ្ឋានថ្នាក់កណ្តាល ឬសាខាពន្ធដារខេត្ត-ខណ្ឌ។

ឯកឧត្តមបានផ្តល់អនុសាសន៍ណែនាំថា ថ្នាក់ដឹកនាំ អ្នកគ្រប់គ្រង និងមន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ទាំងអស់ ត្រូវប្រកាន់ខ្ជាប់នូវអភិក្រមការងារ ក្រមសីលធម៌វិជ្ជាជីវៈ និងអនុវត្តការងារប្រចាំថ្ងៃយ៉ាងទៀងទាត់ ដែលធានាបាននូវនិរន្តរភាពនៃលទ្ធផលការងាររបស់មន្ត្រីរាជការពន្ធដារគ្រប់រូប ហើយសបញ្ជាក់ពីប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងធនធានមនុស្សនៅអគ្គនាយកដ្ឋានពន្ធដារផងដែរ។ ឯកឧត្តមអគ្គនាយករងក៏បានគូសរំលេចថា មន្ត្រីសាធារណៈ ជាពិសេស មន្ត្រីពន្ធដារជាអ្នកផ្តល់សេវា និងអ្នកជាប់ពន្ធ ឬប្រជាពលរដ្ឋទូទៅ ជាអ្នកទទួលសេវា ត្រូវមានលក្ខណសម្បត្តិ ៤ យ៉ាង សំខាន់ៗ គឺ៖ មន្ត្រីសាធារណៈ ឬមន្ត្រីពន្ធដារល្អត្រូវមាន ១.ឥរិយាបថរួសរាយរាក់ទាក់និងមានឆន្ទៈក្នុងការផ្តល់សេវា ២.សមត្ថភាពពេញលេញលើផ្នែកច្បាប់និងបទប្បញ្ញត្តិ ជំនាញ និងបទពិសោធ ៣.ក្រមសីលធម៌វិជ្ជាជីវៈ និង៤.សិល្បៈក្នុងការពន្យល់ និងដោះស្រាយបញ្ហា។ ដោយឡែក ពលរដ្ឋល្អត្រូវមានលក្ខណសម្បត្តិ ដូចជា ១.មានក្រមសីលធម៌ល្អក្នុងសង្គម ២.គោរពច្បាប់ ៣.សិក្សា និងឈ្វេងយល់ជាប្រចាំ និង៤.សហការ សាមគ្គី និងគោរពសិទ្ធិគ្នាទៅវិញទៅមក។

ក្នុងអង្គសិក្ខាសាលានេះដែរ ឯកឧត្តមបានលើកទឹកចិត្តដល់សិក្ខាកាមដែលជាថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារទាំងអស់ យកចិត្តទុកដាក់ ខិតខំសិក្សា និងសួរនាំឱ្យបានច្រើន ដើម្បីយល់ឱ្យបានកាន់តែច្បាស់ពីខ្លឹមសារ យន្តការ នីតិវិធី និងរំហូរការងារនៃការអនុវត្តកាតព្វកិច្ចសារពើពន្ធលើប្រភេទពន្ធទាំង ៥ ខាងលើ ដើម្បីអនុវត្តការងារនិងផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យបានកាន់តែមានប្រសិទ្ធភាពខ្ពស់ និងជួយផ្សព្វផ្សាយបន្តនូវសៀវភៅណែនាំទាំងនេះជូនអ្នកជាប់ពន្ធនិងសាធារណជនឱ្យបានទូលំទូលាយ។

ជាកិច្ចបញ្ចប់ លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម បានមានមតិបិទអង្គសិក្ខាសាលា និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសិក្ខាសាលាដ៏មានសារប្រយោជន៍នេះ ព្រមទាំងជូនពរជួបប្រទះតែភាពជោគជ័យគ្រប់ភារកិច្ច មានសេចក្តីសុខក្នុងក្រុមគ្រួសារ និងសូមសមប្រកបនូវពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍៕

# សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ"



នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៩ ខែធ្នូ ឆ្នាំ២០២៤ លេខាធិការដ្ឋាននៃក្រុមការងាររៀបចំនិងអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការអនុវត្តការផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ" ក្រោមអធិបតីភាពឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីលោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ តាមរយៈប្រព័ន្ធអនឡាញ (Zoom Meeting)។

ជាកិច្ចស្វាគមន៍ លោក **ជ័យរិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម បានលើកឡើងអំពីគោលបំណងនៃការរៀបចំសិក្ខាសាលា និងខ្លឹមសារគន្លឹះនៃយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ ពាក់ព័ន្ធនឹងការលើកទឹកចិត្តផ្នែកពន្ធដារ រួមទាំងការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងរចនាសម្ព័ន្ធគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធដើម្បីភាពរីកចម្រើនទៅមុខនៃការធ្វើធុរកិច្ច ពាណិជ្ជកម្ម និងការវិនិយោគនៅកម្ពុជា។

ជាកិច្ចបន្ទាប់ ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ បានសម្តែងស្វាគមន៍យ៉ាងកក់ក្តៅ និងការវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់លោក លោកស្រី អ្នកនាង កញ្ញា ដែលបានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយដ៏មានសារៈសំខាន់នេះ។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិយុត្ត វិធាន និងនីតិវិធីនៃការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ចំពោះសហគ្រាសធុនតូចនិងមធ្យមស្ថិតក្នុងវិស័យអាទិភាព។

ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តម ក៏បានបញ្ជាក់បន្ថែមថា ក្រោមការដឹកនាំប្រកបដោយភាពស្វាហាប់ និងថាមពល របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨ ក្នុងគោលបំណងលើកកម្ពស់ការគាំពារ និងការពង្រឹងសមត្ថភាព ផលិតភាព និងភាពធន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងជំរុញ និងពន្លឿនការចូលរួមទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដើម្បីធានាឱ្យបាននូវភាពធន់ ភាពប៉ាន់ប្រមាណបាន និងភាពរីកចម្រើនទៅមុខនៃការធ្វើធុរកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងការប្រកបអាជីវកម្ម មុខរបរ និងការងារចិញ្ចឹមជីវិតនៅកម្ពុជា។ អនុវត្តតាមយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ២០២៣-២០២៨ និងអនុក្រឹត្យលេខ ២៧២ អនក្រ.បក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្តនូវប្រកាសលេខ ៨១០ សហវ.ប្រក.អពដ ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការណែនាំអនុវត្តអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ អគ្គនាយកដ្ឋានពន្ធដារក៏បានដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំលេខ ៤២២១២ អពដ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសធុនតូចនិងមធ្យម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ បន្ថែមពីនេះទៀត ឯកឧត្តម ក៏បានលើកឡើងអំពីការបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ ដើម្បីសម្រេចនូវគោលដៅដូចជា ១.បង្កើនអនុលោមភាពសារពើពន្ធតាមរយៈការធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាកម្ម ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាព ព្រមទាំងការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ២.ទំនើបភាវូបនីយកម្មនៃមុខងារស្នូល និងមុខងារគាំទ្រ ក្នុងគោលបំណងឱ្យក្លាយជារដ្ឋបាលសារពើពន្ធជំនាន់ទី២.០ បូក តាមរយៈការពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាឌីជីថល និង៣. បន្តអភិវឌ្ឍមូលធនមនុស្ស និងការអភិវឌ្ឍស្ថាប័ន។

ជាកិច្ចបន្ទាប់ ឯកឧត្តមបានអនុញ្ញាតឱ្យវាគ្មិនឧទ្ទេសនាមធ្វើបទបង្ហាញស្តីពី "ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ" ដើម្បីធ្វើការផ្សព្វផ្សាយ និងពន្យល់ណែនាំលម្អិតជូនសិក្ខាកាមអំពីការដាក់ឱ្យអនុវត្តការផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។ នៅក្នុងសិក្ខាសាលានេះដែរ សិក្ខាកាមបានចូលរួមដដែកពិភាក្សានិងមានការលើកជាសំណួរយ៉ាងច្រើនផុលផុស ព្រមទាំងទទួលបានការបកស្រាយនូវចម្ងល់ផ្សេងៗពីវាគ្មិនឧទ្ទេសនាម។

ជាកិច្ចបញ្ចប់ ឯកឧត្តម **កែន សម្បត្តិ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោក លោកស្រី អ្នកនាង កញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសិក្ខាសាលាដ៏មានសារប្រយោជន៍នេះ ព្រមទាំងជូនពរជួបប្រទះតែភាពជោគជ័យគ្រប់ភារកិច្ច ធុរកិច្ច មានសេចក្តីសុខក្នុងក្រុមគ្រួសារ និងសូមសមប្រកបនូវពុទ្ធពរទាំង បួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជារៀងរហូត៕

# សិក្ខាសាលាស្ដីពី "ពន្ធលើប្រាក់ចំណូលនិងប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) ពន្ធប៉ាតង់ និងពន្ធលើផ្ទាំងផ្សព្វផ្សាយ"



នារសៀលថ្ងៃព្រហស្បតិ៍ ទី១៩ ខែធ្នូ ឆ្នាំ២០២៤ លោកជំទាវ **ម៉ុន នារី** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ និងអញ្ជើញចូលរួមជាអធិបតីក្នុងសិក្ខាសាលាស្ដីពីពន្ធលើប្រាក់ចំណូលនិងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) ពន្ធប៉ាតង់ និងពន្ធលើផ្ទាំងផ្សព្វផ្សាយ តបតាមការអញ្ជើញរបស់សមាគមស្បែកជើងកម្ពុជា (Cambodia Footwear Association) ក្នុងគោលដៅផ្ដល់សេវាអ្នកជាប់ពន្ធពាក់ព័ន្ធនឹងពន្ធទាំងនេះ ក៏ដូចជារំលឹកពីកាតព្វកិច្ច ដើម្បីធានាបាននូវភាពត្រឹមត្រូវក្នុងការត្រៀមលក្ខណៈប្រកាសពន្ធនិងបង់ពន្ធ ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ ខាងមុខនេះ ជូនសមាជិកសមាគមស្បែកជើងកម្ពុជា។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងដោយសមាគមស្បែកជើងកម្ពុជាដោយមានការចូលរួមពីអ្នកឧកញ៉ា **លី យុនថៃ** ប្រធានសមាគមស្បែកជើងកម្ពុជា អមដោយថ្នាក់ដឹកនាំ និងសមាជិកសមាគមស្បែកជើងកម្ពុជាចូលរួមដោយផ្ទាល់ និងតាមអនឡាញ (Zoom Meeting) ចំនួន **២០០ រូប**។

ដើម្បីផ្ដល់ចំណេះដឹងបន្ថែម និងលើកកម្ពស់ការផ្ដល់សេវាអ្នកជាប់ពន្ធ ជាពិសេសសមាជិកសមាគមស្បែកជើងកម្ពុជា ក្នុងការបំពេញកាតព្វកិច្ចឱ្យស្របទៅនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធអគ្គនាយកដ្ឋានពន្ធដារដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានបន្តរៀបចំ និងបន្តផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារដល់អ្នកជាប់ពន្ធជាបន្តបន្ទាប់ដូចជា ១.ពន្ធលើប្រាក់ចំណូលនិងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) ២.ពន្ធប៉ាតង់ និង ៣.ពន្ធលើផ្ទាំងផ្សព្វផ្សាយ។

ក្នុងសិក្ខាសាលានេះ មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ បានធ្វើបទបង្ហាញ ពន្យល់ បកស្រាយលម្អិតនិងក្បោះក្បាយ អំពីខ្លឹមសារនៃប្រធានបទនីមួយៗ និងបានឆ្លើយតបនឹងសំណួររបស់សិក្ខាកាមដែលបានចូលរួមយ៉ាងសកម្ម ហើយនេះគឺជាការផ្តល់សេវាអ្នកជាប់ពន្ធ។ សមាជិកសមាគមស្បែកជើងកម្ពុជា បានយល់ដឹង និងពេញចិត្តយ៉ាងខ្លាំងលើការធ្វើបទបង្ហាញនេះ ព្រមទាំងបានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារដែលបានធ្វើបទបង្ហាញនិងឆ្លើយតបរាល់សំណួរនានាយ៉ាងក្បោះក្បាយ និងបានបញ្ជាក់ពីការទទួលនូវចំណេះដឹងថ្មី ក្នុងការបង្កើនអនុលោមភាពសារពើពន្ធ៕



*លោកជំទាវ **ប៊ុន នារី***
*អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ*



*លោក **កែវ ប៉ង់តា***
*អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ*







# សិក្ខាសាលាស្តីពី "ទស្សនកិច្ចសិក្សារបស់គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ នៅប្រទេសជប៉ុនដើម្បីសិក្សាឈ្វេងយល់ពីការរៀបចំ អភិវឌ្ឍន៍ និងធ្វើទំនើបកម្មកម្មវិធីបណ្តុះបណ្តាលអំពីពន្ធ និងការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលសារពើពន្ធនៃប្រទេសជប៉ុន"



នាថ្ងៃចន្ទ ទី៩ ដល់ថ្ងៃអង្គារ ទី១០ ខែធ្នូ ឆ្នាំ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គន់ ឋិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ លោក **ហ៊ឹម ប៊ុនធឿន** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បានដឹកនាំគណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីសិក្សាឈ្វេងយល់ពីការរៀបចំអភិវឌ្ឍន៍និងធ្វើទំនើបកម្មកម្មវិធីបណ្តុះបណ្តាលអំពីពន្ធនិងការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលសារពើពន្ធនៃប្រទេសជប៉ុន។ សមាសភាពចូលរួមរបស់គណៈប្រតិភូមានលោក **ស៊ុន ឧត្តី** នាយកសាលាជាតិពន្ធដារ កញ្ញា **ម៉ែន ម៉ានី** នាយករងសាលាជាតិពន្ធដារ និងលោក **ពៅ បូណា** ប្រធានការិយាល័យបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ធនធានមនុស្ស នៃនាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក។

នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៤ ដំណើរទស្សនកិច្ចសិក្សាបានប្រកាសបើកកម្មវិធីជាផ្លូវការ ក្រោមអធិបតីភាពលោក TANEGUSA YOSHIO អគ្គនាយកនៃមហាវិទ្យាល័យពន្ធជាតិ ដោយមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ និងសមាជិកគណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ និងថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃទីភ្នាក់ងារជាតិពន្ធជាតិ ( National Tax Agency-NTA ) និងមហាវិទ្យាល័យពន្ធជាតិ ( National Tax College-NTC )។ ទស្សនកិច្ចសិក្សារយៈពេល ២ថ្ងៃនេះ ថ្នាក់ដឹកនាំរដ្ឋបាលសារពើពន្ធនៃប្រទេសជប៉ុន បានធ្វើបទបង្ហាញជូនគណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ ដោយផ្តោតលើចំណុចសំខាន់ៗ រួមមាន៖ ការបណ្តុះបណ្តាលមន្ត្រី ការគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគណនេយ្យករពន្ធដារសាធារណៈ ( Certified Public Tax Accountant - CPTA )។ ទន្ទឹមនឹងនេះ ថ្នាក់ដឹកនាំ និងសមាជិកគណៈប្រតិភូបានធ្វើទស្សនកិច្ចសិក្សាទៅកាន់សាខា Wako និងសារមន្ទីរជាតិពន្ធដារ នៃ NTC ដើម្បីសិក្សាឈ្វេងយល់អំពីប្រវត្តិ

និងហេដ្ឋារចនាសម្ព័ន្ធនៃរដ្ឋបាលសារពើពន្ធរបស់ប្រទេសជប៉ុនផងដែរ។ ចំណេះដឹងសំខាន់ៗ ដែលគណៈប្រតិភូបានទទួលពីដំណើរទស្សនកិច្ចសិក្សានៅរដ្ឋបាលសារពើពន្ធនៃប្រទេសជប៉ុន មានដូចខាងក្រោម៖

១. **រចនាសម្ព័ន្ធនៃ NTA៖** មាន ៥ អង្គភាព គឺ ១.ទីស្នាក់ការកណ្តាល (Headquarters) មានចំនួន ៤ នាយកដ្ឋានថ្នាក់កណ្តាល ២.ការិយាល័យពន្ធតាមតំបន់ (Regional Taxation Bureaus) មានចំនួន ១២ ដែលគ្រប់គ្រងលើការិយាល័យពន្ធដារស្រុក ចំនួន ៥២៤ ៣.ក្រុមប្រឹក្សាជាតិពន្ធដារ (National Tax Council) ៤.មហាវិទ្យាល័យពន្ធជាតិ (National Tax College) និង ៥.តុលាការពន្ធជាតិ (National Tax Tribunal)។

២. **ការបណ្តុះបណ្តាលមន្ត្រី៖** មាន ២ ប្រភេទ គឺ ការបណ្តុះបណ្តាលនៅ NTC និងការបណ្តុះបណ្តាលនៅកន្លែងការងារផ្ទាល់ ដែលរៀបចំឡើងដោយ NTA ដែលបែងចែកជា ៣ កម្មវិធីបណ្តុះបណ្តាល រួមមាន ១.កម្មវិធីបណ្តុះបណ្តាលរយៈពេលវែង ដើម្បីបង្កើនចំណេះដឹង និងកម្រិតសមត្ថភាពទូទៅអំពីពន្ធសម្រាប់មន្ត្រីពន្ធដារថ្មី និងមន្ត្រីទូទៅ ដូចជា វគ្គកម្រិតមូលដ្ឋាន វគ្គកម្រិតមធ្យម វគ្គកម្រិតខ្ពស់ និងវគ្គកម្រិតថ្នាក់ដឹកនាំ ២.កម្មវិធីបណ្តុះបណ្តាលជំនាញរយៈពេលខ្លី ដើម្បីពង្រឹងជំនាញដែលចាំបាច់ក្នុងការងារដែលទទួលបន្ទុកឱ្យកាន់តែខ្លាំងពូកែក្នុងន័យពង្រឹងនិរន្តរភាពរដ្ឋបាលសារពើពន្ធ និង៣.វគ្គបណ្តុះបណ្តាលចាំបាច់ផ្សេងៗ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីឱ្យស្របតាមបរិបទអន្តរជាតិ ដូចជា ភាសា ច្បាប់ពន្ធអន្តរជាតិ និងគណនេយ្យ។ ក្របខ័ណ្ឌនៃការបង្កើតវគ្គបណ្តុះបណ្តាល មាន ៤ ជំហាន រួមមាន ១.សេចក្តីណែនាំនៃការបណ្តុះបណ្តាល ២.គោលនយោបាយអប់រំ ៣.គោលការណ៍នៃការបណ្តុះបណ្តាល និង៤.កាលវិភាគប្រចាំខែ។ ផែនការបណ្តុះបណ្តាលមន្ត្រីរួមរបស់ NTA ត្រូវបានរៀបចំឡើងដោយលេខាធិការដ្ឋាន (Commissioners Secretariat) នៃទីស្នាក់ការកណ្តាល ដែលត្រូវបានអនុវត្តដើម្បីបណ្តុះបណ្តាលមន្ត្រីនៅទីស្នាក់ការកណ្តាល NTC និងមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមតំបន់ (Regional Training Center) ទាំង១២។

៣. **ការគ្រប់គ្រងធនធានមនុស្សរបស់ NTA៖** ចែកជា ៥ ដំណាក់កាល គឺគិតចាប់តាំងពីដំណាក់កាលនៃការជ្រើសរើសរហូតដល់ដំណាក់កាលនៃការចូលនិវត្តន៍របស់មន្ត្រី មានដូចខាងក្រោម៖

- **ការជ្រើសរើសមន្ត្រី៖** បានចែកចេញជា ៤ ប្រភេទ គឺ ១.ការជ្រើសរើសបែបទូលំទូលាយ ២.ការជ្រើសរើសអ្នកជំនាញពន្ធជាតិ ៣.ការជ្រើសរើសមន្ត្រីពន្ធជាតិ និង៤.ការជ្រើសរើសមន្ត្រីពាក់កណ្តាលអាជីព។ និតិវិធីនៃការជ្រើសរើសមន្ត្រីនីមួយៗ ត្រូវគ្រប់គ្រងដោយអាជ្ញាធរជាតិគ្រប់គ្រងបុគ្គលិក (National Personnel Authority-NPA) ផ្អែកលើគោលការណ៍គុណធិបតេយ្យ (Meritocracy) តាមរយៈការប្រឡងប្រជែងដោយបើកចំហ និងស្មើភាពគ្នា។ NTA បានបង្កើតឱ្យមានការប្រឡងប្រជែងថ្មីមួយដែលផ្តោតសំខាន់ទៅលើផ្នែកវិទ្យាសាស្ត្រ វិស្វកម្ម និងឌីជីថល នៅក្នុងឆ្នាំ២០២៣ និងធ្វើការជ្រើសរើសមន្ត្រីចំនួន ១០០ រូប ជារៀងរាល់ឆ្នាំ ដើម្បីដោះស្រាយទៅលើបញ្ហាប្រឈមនៃកង្វះធនធានមនុស្សដែលមានជំនាញវិទ្យាសាស្ត្រ សម្រាប់ឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល
- **ប្រព័ន្ធវាយតម្លៃមន្ត្រី (Personal Evaluation System-PES)៖** ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៩ ដើម្បីវាយតម្លៃសមត្ថភាព និងលទ្ធផលការងារដែលសម្រេចបានរបស់មន្ត្រីម្នាក់ៗ សម្រាប់ការតំឡើងតំណែង (Promotion) ការកែតម្រូវប្រាក់ខែ តាមរយៈ "Grade-up" ឬ "Rank-up" នៃប្រាក់ខែ និងការផ្តល់ប្រាក់រង្វាន់ (Bonus)។ គោលបំណងការងាររបស់មន្ត្រីម្នាក់ៗ ត្រូវបានកំណត់ និងវាយតម្លៃដោយប្រៀបធៀបជាមួយនឹងលទ្ធផលការងារ និងសមត្ថភាពជាក់ស្តែង។ ប្រព័ន្ធនេះធានាបាននូវគណនេយ្យភាព និងជំរុញមន្ត្រីឱ្យសម្រេចបាននូវលទ្ធផលការងារដែលមាន ប្រសិទ្ធភាពខ្ពស់
- **វិន័យការងារ៖** មន្ត្រីពន្ធ ត្រូវគោរពតាម ១.ច្បាប់សេវាសាធារណៈជាតិ (National Public Service Act) ដែលបានចែងពីស្តង់ដាមូលដ្ឋានសម្រាប់វិន័យសេវាកម្ម កាតព្វកិច្ច និងការរឹតបន្តឹង ជាដើម និង ២.ក្រមសីលធម៌

សេវាសាធារណជាតិ (National Public Service Ethics Act & Code) ដែលបានចែងពីគោលការណ៍សម្រាប់មន្ត្រីប្រកាន់ភ្ជាប់ រួមមាន ការមិនទទួលសំណូក ឬអំណោយ ដែលអាចធ្វើឱ្យខូចដល់សុចរិតភាពនៃមុខងារជាមន្ត្រីពន្ធ និងនិតិវិធីនៃការរាយការណ៍

- **ទណ្ឌកម្មការងារ៖** ចែកជា ២ ប្រភេទ គឺ ១.សកម្មភាពវិន័យ (Disciplinary actions) រួមមាន ការបណ្តេញចេញការព្យួរការងារ ការកាត់បន្ថយប្រាក់ខែ និងការស្តីបន្ទោស និង ២.វិធានការកែតម្រូវ (Correcttive measures) រួមមានការដាស់តឿន(Admonition) និងការព្រមាន (Warning)
- **ការចូលនិវត្តន៍៖** នាពេលបច្ចុប្បន្នអាយុចូលនិវត្តន៍របស់មន្ត្រីពន្ធនៃប្រទេសជប៉ុន បានកែសម្រួលពីអាយុ ៦០ឆ្នាំដល់ ៦៥ ឆ្នាំ ដែលទទួលបានប្រាក់សោធននិវត្តន៍ដោយពឹងផ្អែកទៅលើ ២ ចំណុច គឺរយៈពេលនៃការបម្រើការងារ និងប្រាក់ខែនៅថ្ងៃចូលនិវត្តន៍។

៤. **ប្រព័ន្ធគណនេយ្យករពន្ធដារសាធារណៈ (CPTA)៖** ជាប្រព័ន្ធគ្រប់គ្រងភ្នាក់ងារសេវាកម្មពន្ធដាររបស់ប្រទេសជប៉ុនស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ក្រុមប្រឹក្សាជាតិពន្ធដារនៃ NTA ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រួលដល់ការប្រកាសពន្ធរបស់អ្នកជាប់ពន្ធនៅប្រទេសជប៉ុន។ CPTA ជួយលើកកម្ពស់អនុលោមភាពនៃការបង់ពន្ធ សម្រួលដល់ការស៊ើបអង្កេត និងផ្តល់ការពិគ្រោះយោបល់ ដោយធានាបាននូវប្រព័ន្ធពន្ធដារដែលមានលក្ខណៈត្រឹមត្រូវ និងតម្លាភាព។ បច្ចុប្បន្ននេះ ក្រុមប្រឹក្សាជាតិពន្ធដារមានសមាជិក CPTA សរុបចំនួន ៨១ ០០០ រូប ដើម្បីផ្តល់សេវាកម្មពន្ធដារជូនដល់អ្នកជាប់ពន្ធ។

៥. **សារមន្ទីរជាតិពន្ធដារ៖** មានការដាក់តាំងសម្ភុច្ឆ័យដោយបែងចែកតាមសម័យកាល និងតំបន់ចំនួន ២២ គិតចាប់ពីសម័យអេដុ (ឆ្នាំ១៧០២) មកដល់បច្ចុប្បន្ន។ ជាដំបូង ប្រទេសជប៉ុន បានប្រមូលពន្ធលើដីធ្លី ដោយយកពន្ធក្រោមរូបភាពជាអង្ករ មាស និងប្រាក់ រហូតមកដល់សម័យមេជិ (ឆ្នាំ១៨៤២) ទើបប្រទេសជប៉ុនបានប្រមូលពន្ធតាមរយៈប្រាក់យេនវិញ។ សម្ភុច្ឆ័យមួយចំនួនត្រូវបានដាក់បង្ហាញជាលក្ខណៈជាប់លាប់ និងមួយចំនួនជាលក្ខណៈបណ្តោះអាសន្នដោយមានការផ្លាស់ប្តូរសម្ភុច្ឆ័យពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីឱ្យមានភាពទាក់ទាញ។ តាមការបញ្ជាក់ពីអ្នកជំនាញខាងសារមន្ទីរជាតិពន្ធដារ ការរៀបចំសម្ភុច្ឆ័យ គឺត្រូវមានការប្រុងប្រយ័ត្នលើការរៀបចំពន្លឺ សីតុណ្ហភាព និងសំណើម ដើម្បីរក្សាគុណភាពសម្ភុច្ឆ័យ និងការពារការខូចខាតដោយថាហេតុទៅតាមពេលវេលា។ ដើម្បីធានាប្រសិទ្ធភាព និងដំណើរការរបស់សារមន្ទីរ អ្នកធ្វើការនៅសារមន្ទីរឬ Museum Curator គឺត្រូវបានជ្រើសរើសចេញពីនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវតាមសម័យកាលនានា។

៦. **បណ្ណសារដ្ឋាន៖** គឺជាផ្នែកមួយស្រដៀងគ្នាទៅនឹងសារមន្ទីរ និងបណ្ណាល័យ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងបណ្ណសារពន្ធ (Tax Research and Archives Center) នៃ NTC។ បណ្ណសារ ដ្ឋានទទួលបន្ទុកគ្រប់គ្រងថែរក្សាឯកសាររដ្ឋបាល គ្រឿងបរិក្ខារ និងសម្ភារចាស់ៗ របស់ NTA ដែលមានតម្លៃជាប្រវត្តិសាស្ត្រ និងគតិយុត្ត ដើម្បីអភិរក្សទុកសម្រាប់ការប្រើប្រាស់នាពេលបច្ចុប្បន្ន និងអនាគត។

ឆ្លៀតក្នុងឱកាសនោះផងដែរដើម្បីឆ្លើយតបទៅនឹងសំណួមរបស់ NTA ដែលចង់ដឹងអំពីទិសដៅអនុវត្តន៍បន្តរបស់អគ្គនាយកដ្ឋានពន្ធដារនៃប្រទេសកម្ពុជា លោក **ហ៊ីម ប៊ុនធឿន** ប្រធានគណៈប្រតិភូ បានមានមតិសង្ខេបខ្លីៗ នូវការងារសំខាន់ៗ ដែលជាគំនិតផ្តួចផ្តើមក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី។ ការងារសំខាន់ៗទាំងនេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ក្នុងការសិក្សាឈ្វេងយល់បន្ថែម ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ស្របតាមទស្សនវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ និងឆ្លើយតបទៅនឹងស្តង់ដានៃឧត្តមានុវត្តន៍អន្តរជាតិ រួមមាន៖ ១.ការពង្រឹងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងការវិភាគទិន្នន័យ ២.ផែនការយុទ្ធសាស្ត្រធនធានមនុស្ស និងផែនការអភិវឌ្ឍន៍ស្ថាប័ន ៣.និយាមនីតិវិធីប្រតិបត្តិការងារ និងក្រមសីលធម៌និងវិន័យមន្ត្រីពន្ធដារ

៤.ការគ្រប់គ្រងចាត់ចែងចំនួនមន្ត្រី ៥.ការគ្រប់គ្រងនិងវាយតម្លៃលទ្ធផលការងារ ប្រព័ន្ធលើកទឹកចិត្ត និងការលើកទឹកចិត្តមន្ត្រី និង ៦.កម្មវិធីបណ្តុះបណ្តាលអំពីពន្ធ និងការអភិវឌ្ឍសមត្ថភាពដឹកនាំនិងគ្រប់គ្រង។

ជាកិច្ចបញ្ចប់ ក្នុងដំណើរទស្សនកិច្ចសិក្សាដែលមានរយៈពេល ២ ថ្ងៃ របស់គណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារ បានបញ្ចប់នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤ ប្រកបដោយលទ្ធផលជាផ្លែផ្កា ជាមួយនឹងការទទួលបាននូវចំណេះដឹង គំនិតច្នៃប្រឌិតថ្មីៗ បទពិសោធល្អៗ សម្រាប់ជាធាតុចូលក្នុងការរៀបចំ អភិវឌ្ឍន៍ និងធ្វើទំនើបកម្មកម្មវិធីបណ្តុះបណ្តាលអំពីពន្ធ និងការគ្រប់គ្រងធនធានមនុស្សរបស់អគ្គនាយកដ្ឋានពន្ធដារ៕












# សិក្ខាសាលាស្តីពី "កាតព្វកិច្ច និងនីតិវិធីក្នុងការធ្វើបច្ចុប្បន្នភាពពន្ធដារ ស្របតាមច្បាប់ ស្តីពីសារពើពន្ធសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល"




នាព្រឹកថ្ងៃចន្ទ ទី២៣ ខែធ្នូ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ និងអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) បានសហការរៀបចំ "សិក្ខាសាលាស្តីពីកាតព្វកិច្ច និងនីតិវិធីក្នុងការធ្វើបច្ចុប្បន្នភាពពន្ធដារ ស្របតាមច្បាប់ ស្តីពីសារពើពន្ធសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល" ក្រោមអធិបតីភាពឯកឧត្តម **ម៉ិញ បានកុសល** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងលោកស្រី **ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិ នៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ដោយមានការចូលរួមពីលោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម លោក **ប៉ូ ពិសិដ្ឋ**, លោក **នុត វុត្ថា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម លោក **កែវ ប៉ង់តា** អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារ និងតំណាងពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល សរុបចំនួន **៣០០ រូប**។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបបន្ថែមនូវការយល់ដឹងអំពីការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីពន្ធដារ សំដៅពង្រឹងអនុលោមភាពសារពើពន្ធ និងលើកកម្ពស់វប្បធម៌បង់ពន្ធ និងដើម្បីឆ្លើយតបនឹងចម្ងល់ ឬសំណួរនានាពាក់ព័ន្ធនឹងពន្ធដារពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

ជាកិច្ចចាប់ផ្តើម លោកស្រី **ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិ នៃអង្គការ គ.ស.ក បានថ្លែងសុន្ទរកថាស្វាគមន៍អង្គសិក្ខាសាលា ដោយបានលើកឡើងអំពីកិច្ចសហការល្អយ៉ាងជិតស្និទ្ធរវាងអគ្គនាយកដ្ឋានពន្ធដារ ជាមួយនឹងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការបង្កើតក្រុមការងារចម្រុះក្នុងរយៈពេល ៤ ឆ្នាំ កន្លងមកនេះ។ ជាមួយនេះ លោកស្រីនាយិកាប្រតិបត្តិ បានសម្តែងនូវការកោតសរសើរចំពោះភាពជាអ្នកដឹកនាំរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការកែទម្រង់រដ្ឋបាលសារពើពន្ធ ដើម្បីពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែល្អប្រសើរ ធានាបាននូវតម្លាភាព ស័ក្តិសិទ្ធិភាព និងភាពងាយស្រួល។ លោកស្រីក៏បានពាំនាំនូវសំណួរមួយចំនួនរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីស្នើសុំការបកស្រាយ និងពន្យល់បន្ថែមពីអគ្គនាយកដ្ឋានពន្ធដារផងដែរ។

ជាកិច្ចបន្ទាប់ ឯកឧត្តម **ម៉ិញ បានកុសល** បានថ្លែងសុន្ទរកថាបើកកម្មវិធីសិក្ខាសាលា ដោយបានសម្តែងនូវអំណរគុណ ចំពោះអង្គការ គ.ស.ក លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារពាក់ព័ន្ធ ដែលបានសម្របសម្រួលរៀបចំកម្មវិធីសិក្ខាសាលាដ៏មានសារៈសំខាន់នេះឡើង។ ជាមួយគ្នានេះ ឯកឧត្តមអគ្គនាយករង បានវាយតម្លៃខ្ពស់ចំពោះសិក្ខាកាមទាំងអស់ ដែលមានវត្តមានចូលរួមនៅក្នុងកម្មវិធីសិក្ខាសាលានេះ ដែលបានឆ្លុះបញ្ចាំងឱ្យឃើញអំពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹង និងបង្កើនការយល់ដឹងបន្ថែមអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ជាពិសេសធ្វើការស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀត ចំពោះកាតព្វកិច្ចសារពើពន្ធសម្រាប់សកម្មភាពអាជីវកម្មដោយឡែកបន្ថែមលើសកម្មភាពគោលដៅសុទ្ធសាធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីចូលរួមបំពេញកាតព្វកិច្ចសារពើពន្ធក្នុងឋានៈជាអ្នកជាប់ពន្ធ ឬ/និងឋានៈជាភ្នាក់ងារកាត់ទុកឱ្យបានត្រឹមត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។ បន្ថែមពីនេះ ឯកឧត្តមអគ្គនាយករង បានគូសបញ្ជាក់អំពីការខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងការលើកកម្ពស់ និងបញ្ជ្រាបវប្បធម៌បង់ពន្ធឱ្យបានជ្រួតជ្រាបដល់គ្រប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាអ្នកជាប់ពន្ធទាំងអស់ដើម្បីឱ្យយល់ដឹងកាន់តែច្បាស់អំពីកាតព្វកិច្ចសារពើពន្ធ និងការវិវត្តឥតឈប់ឈរនៃការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ សំដៅធ្វើការប្រែក្លាយស្ថាប័នជាតិមួយនេះ ឱ្យមានលក្ខណៈទំនើបដែលអាចឆ្លើយតបទៅនឹងការវិវត្តនៃសង្គម និងសេដ្ឋកិច្ចជាតិក្នុងដំណាក់កាលប្រែប្រួលថ្មី ក៏ដូចជាបរិបទនៃសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ និងពិភពលោក។ ឯកឧត្តមអគ្គនាយករង បានជំរុញនិងលើកទឹកចិត្តសិក្ខាកាមទាំងអស់ ចូលរួមឱ្យបានសកម្មនៅក្នុងសិក្ខាសាលានេះ តាមរយៈការលើកជាមតិយោបល់ សំណួរមួយចំនួន ដើម្បីផ្តល់និងស្រូបយកធាតុចូលពាក់ព័ន្ធនៅក្នុងសិក្ខាសាលានេះ ព្រមទាំងចែករំលែក ជាចំណេះដឹង ចំណេះធ្វើ បទពិសោធអនុវត្ត និងបទប្បញ្ញត្តិ ដើម្បីជាប្រយោជន៍ ជាចំណេះដឹងសម្រាប់បំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សំដៅពង្រឹងវប្បធម៌នៃការបង់ពន្ធ និងអនុលោមភាពសារពើពន្ធ។ ឯកឧត្តមអគ្គនាយករង បានបញ្ជាក់ថាករណីបន្ទាប់ពីស្តាប់ការធ្វើបទបង្ហាញ និងវេទិកាសំណួរ-ចម្លើយបានបញ្ចប់ ប្រសិនបើសិក្ខាកាមនៅមានចម្ងល់នានា អាចធ្វើការទំនាក់ទំនងសួរនាំព័ត៌មានបន្ថែមតាមរយៈកម្មវិធី GDT Live Chat ឬតាមរយៈមជ្ឈមណ្ឌលផ្តល់ព័ត៌មានទូរស័ព្ទលេខ ១២៧៧ ដោយឥតគិតថ្លៃ ឬដោយផ្ទាល់ជាមួយនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ឬជាមួយមន្ត្រីជំនាញទទួលបន្ទុកសាខាពន្ធដារនីមួយៗ ឬអាចទាញយកនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ព្រមទាំងព័ត៌មានពន្ធដារ នៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារដែលមានអាសយដ្ឋាន www.tax.gov.kh ឬបណ្តាញទំនាក់ទំនងសង្គម Facebook, YouTube, Instagram និង Telegram របស់អគ្គនាយកដ្ឋានពន្ធដារ។

សិក្ខាសាលាបានដំណើរការដោយមានការធ្វើបទបង្ហាញស្តីពី "នីតិវិធីចុះបញ្ជី និងបច្ចុប្បន្នកម្មស្របតាមច្បាប់ស្តីពីសារពើពន្ធសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល" ដោយលោក **កែវ ប៉ង់តា** អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ ដែលមានចំណុចសំខាន់ចំនួនបី ដែលរួមមាន៖ ១.ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ២.បែបបទ និងនីតិវិធីសម្រាប់ការបំពេញកាតព្វកិច្ចចុះបញ្ជី និងបច្ចុប្បន្នកម្ម និង៣.មធ្យោបាយដាក់ពាក្យស្នើសុំ និងការតាំងឬព្យួរបង្ហាញឯកសារចុះបញ្ជីពន្ធដារ។ ជាមួយគ្នានេះ ក៏មានបទបង្ហាញមួយទៀតស្តីពី "កាតព្វកិច្ចសារពើពន្ធសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល" ដោយលោក **ប៉ូ ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ដែលមានចំណុចសំខាន់ចំនួនបួន ដែលរួមមាន៖ ១.ទិដ្ឋភាពទូទៅ ២.ការលើកលែងពន្ធលើប្រាក់ចំណូល ៣.កាតព្វកិច្ចសារពើពន្ធ និង៤.សកម្មភាពអាជីវកម្មដោយឡែក។ ទន្ទឹមនឹងនេះ ក្រោយពីបញ្ចប់ការធ្វើបទបង្ហាញទាំងពីរ សិក្ខាសាលាក៏មានរៀបចំកម្មវិធីសំណួរ ចម្លើយ ដែលអង្គសិក្ខាកាមបានលើកឡើងនូវចម្ងល់ផ្សេងៗយ៉ាងផុលផុស និងមានការឆ្លើយតបពីវាគ្មិនយ៉ាងក្បោះក្បាយ៕

# សិក្ខាសាលាតាមខេត្ត-ខណ្ឌ

នាថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តស្វាយរៀង** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "នីតិវិធីនៃការស្នើសុំកែតម្រូវលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ តាមអនឡាញ ការទូទាត់បំណុលពន្ធ និងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ា" ជូនតំណាងសហគ្រាស ក្រោមអធិបតីភាព លោក **ផន្ន ទឹម** ប្រធានសាខាពន្ធដារខេត្តស្វាយរៀង៕




នាថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកណ្តាល** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "បញ្ជីគណនេយ្យសាមញ្ញ កាតព្វកិច្ចសារពើពន្ធប្រចាំខែ និងប្រចាំឆ្នាំ និងកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច ( GDT Tax Prefiling App )" ជូនតំណាងសហគ្រាស ក្រោមអធិបតីភាព លោក **សុវណ្ណ សម្បត្តិ** អនុប្រធានសាខាពន្ធដារខេត្តកណ្តាល៕



នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកំពង់ធំ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "បញ្ជីគណនេយ្យសាមញ្ញ កាតព្វកិច្ចសារពើពន្ធប្រចាំខែ និងប្រចាំឆ្នាំ និងកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច ( GDT Tax Prefiling App )" ជូនតំណាងសហគ្រាស ក្រោមអធិបតីភាព លោក **ខឹម សុវណ្ណ** ប្រធានសាខាពន្ធដារខេត្តកំពង់ធំ៕



នាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌមានជ័យ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "អាករពិសេស អាករសម្រាប់បំភ្លឺសាធារណៈ និងអាករលើការស្នាក់នៅ" ជូនតំណាងសហគ្រាស ក្រោមអធិបតីភាព លោក **ខិន ហាប់** អនុប្រធានសាខាពន្ធដារខណ្ឌមានជ័យ៕



នាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តប៉ៃលិន** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីវិធាននិងនីតិវិធីនៃការបែងចែកចំណូលនិងចំណាយក្នុងចំណោមបុគ្គលទាក់ទិន សវនកម្មពន្ធដារ និងវិធាននៃការប្រើប្រាស់វិក្កយបត្រ" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធមធ្យម ក្រោមអធិបតីភាព លោក **ឡើន ឆ្វី** អនុប្រធានសាខាពន្ធដារខេត្តប៉ៃលិន៕



នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌដង្កោ** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ពន្ធលើអចលនទ្រព្យ និងពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ" ជូនអាជ្ញាធរមូលដ្ឋានក្នុងខណ្ឌដង្កោ ក្រោមអធិបតីភាព លោក **ឆាយ សុវណ្ណា** ប្រធានសាខាពន្ធដារខណ្ឌដង្កោ៕




នាថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តស្វាយរៀង** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "លិខិតបទដ្ឋានគតិយុត្តថ្មីៗ និងការលើកទឹកចិត្តពន្ធដារចំពោះវិស័យអចលនទ្រព្យ រួមមានពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់" ក្រោមអធិបតីភាព ឯកឧត្តម **សុខ រស់** អភិបាលរងនៃគណៈអភិបាលខេត្តស្វាយរៀង និងមានការចូលរួមពី លោក **ឥន្ទ ទឹម** ប្រធានសាខាពន្ធដារខេត្តស្វាយរៀង៕



នាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌដូនពេញ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "លិខិតបទដ្ឋានគតិយុត្តថ្មីៗ និងការលើកទឹកចិត្តពន្ធដារចំពោះវិស័យអចលនទ្រព្យ រួមមានពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់" ជូនអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលខណ្ឌដូនពេញ ក្រោមអធិបតីភាព លោក **ជា ម៉េងហួត** ប្រធានសាខាពន្ធដារខណ្ឌដូនពេញ៕



នាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ៤ នៅ **សាខាពន្ធដារខេត្តកំពង់ស្ពឺ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "លិខិតបទដ្ឋានគតិយុត្តថ្មីៗ និងការលើកទឹកចិត្តពន្ធដារចំពោះវិស័យអចលនទ្រព្យ រួមមាន ពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់" ជូនអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាល ក្រុងច្បារមន ក្រោមអធិបតីភាព លោក **ម៉ែត ចក់** ប្រធានសាខាពន្ធដារខេត្តកំពង់ស្ពឺ។



នាថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តត្បូងឃ្មុំ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "លិខិតបទដ្ឋានគតិយុត្តថ្មីៗ និងការលើកទឹកចិត្តពន្ធដារចំពោះវិស័យអចលនទ្រព្យ រួមមានពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធលើមធ្យោបាយដឹកជញ្ជូន" ជូនអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់និងមន្ត្រីពាក់ព័ន្ធ នៃរដ្ឋបាលខេត្តត្បូងឃ្មុំ ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន កុសល្យ** អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងមានការចូលរួមពី លោក **ឈឹម ទេវចន់** ប្រធានសាខាពន្ធដារខេត្តត្បូងឃ្មុំ។



នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តព្រះសីហនុ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "លិខិតបទដ្ឋានគតិយុត្តថ្មីៗ និងការលើកទឹកចិត្តពន្ធដារចំពោះវិស័យអចលនទ្រព្យ រួមមានពន្ធលើអចលនទ្រព្យ ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់" ជូនអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់និងមន្ត្រីពាក់ព័ន្ធ នៃរដ្ឋបាលខេត្តព្រះសីហនុ ក្រោមអធិបតីភាព ឯកឧត្តម **ម៉ាង ស៊ីណេត** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និងមានការចូលរួមពី លោក **សន ស៊ីផល** ប្រធានសាខាពន្ធដារខេត្តព្រះសីហនុ។



នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តបន្ទាយមានជ័យ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី"កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) និងវិធាននៃការប្រើប្រាស់វិក្កយបត្រ" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធតូច ក្រោមអធិបតីភាព លោក **ឡាយ ហុខ** អនុប្រធានសាខាពន្ធដារខេត្តបន្ទាយមានជ័យ៕



នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌទួលគោក** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការស្នើសុំកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែសម្រាប់អ្នកជាប់ពន្ធមធ្យម" ជូនតំណាងសហគ្រាស ក្រោមអធិបតីភាព លោក **អេង ទីតា** ប្រធានសាខាពន្ធដារខណ្ឌទួលគោក៕



នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ នៅ **សាខាពន្ធដារ ខេត្តប៉ៃលិន** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "វិធាននៃការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតូច សិទ្ធិនិងកាតព្វកិច្ចអ្នកជាប់ពន្ធ កាតព្វកិច្ចនៃការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ និងលិខិតបទដ្ឋានគតិយុត្តថ្មីៗស្តីពីពន្ធដារ" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធតូច និងមធ្យម ក្រោមអធិបតីភាព លោក **ឡឿន អ៊ួ** អនុប្រធានសាខាពន្ធដារខេត្តប៉ៃលិន៕



នាថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកំពង់ធំ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "លិខិតបទដ្ឋានគតិយុត្តថ្មីៗស្តីពីពន្ធដារ ក្នុងវិស័យអចលនទ្រព្យ" ជូនអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋបាលស្រុកស្ទោង និងរដ្ឋបាលស្រុកសន្ទុក ក្រោមអធិបតីភាព លោក **ខឹម សុវណ្ណ** ប្រធានសាខាពន្ធដារខេត្តកំពង់ធំ៕



នាថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌចំការមន** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី"ការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) និងកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធតូច ក្រោមអធិបតីភាពថ្នាក់ដឹកនាំសាខាពន្ធដារខណ្ឌចំការមន។



នាថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ នៅ **សាខាពន្ធដារ ខេត្តស្ទឹងត្រែង** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងពន្ធលើចំណេញមូលធន" ជូនអាជ្ញាធរពាក់ព័ន្ធនៃរដ្ឋបាលស្រុកសៀមប៉ាង ក្រោមអធិបតីភាព លោក **ថន ម៉ុនយ៉ន** ប្រធានសាខាពន្ធដារខេត្តស្ទឹងត្រែង។



នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកណ្ដាល** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ពន្ធលើប្រាក់ចំណូល" ជូនតំណាងសហគ្រាស ក្រោមអធិបតីភាព លោក **ខួន សុវណ្ណ** ប្រធានសាខាពន្ធដារខេត្តកណ្ដាល។



នាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តតាកែវ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ពន្ធលើប្រាក់បៀវត្ស ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធតាមអនឡាញ (e-Filing) លើមុខងារប្រកាសពន្ធ លើប្រាក់បៀវត្ស និងកម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (GDT Salary Tax App)" ជូនតំណាងមន្ទីរ-អង្គភាពជុំវិញរដ្ឋបាលខេត្តតាកែវ ក្រោមអធិបតីភាព លោក **ខួន ពុទ្ធី** អនុប្រធានសាខាពន្ធដារខេត្តតាកែវ។



នាថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌមានជ័យ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "អាករលើតម្លៃបន្ថែម" ជូនតំណាងសហគ្រាស ក្រោមអធិបតីភាព លោកស្រី **គាន រ៉ាមី** ប្រធានសាខាពន្ធដារខណ្ឌមានជ័យ។



នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤ នៅ **សាខាពន្ធដារ ខណ្ឌពោធិ៍សែនជ័យ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធមធ្យមដែលទើបចុះបញ្ជីថ្មី ក្រោមអធិបតីភាព លោក **មុត ណុច** ប្រធានសាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ។



នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកំពង់ធំ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "លិខិតបទដ្ឋានគតិយុត្តថ្មីៗពាក់ព័ន្ធនឹងវិស័យអចលនទ្រព្យ" ជូនអាជ្ញាធរស្រុកប្រាសាទបល្ល័ង្គ ក្រោមអធិបតីភាព លោក **អ៊ុំ គឹមសុទ្ធ** អនុប្រធានសាខាពន្ធដារខេត្តកំពង់ធំ និង លោក **ឈួន រ៉ា** ប្រធានក្រុមប្រឹក្សាស្រុកប្រាសាទបល្ល័ង្គ។



នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤ នៅ **សាខាពន្ធដារ ខេត្តព្រៃវែង** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ពន្ធលើប្រាក់បៀវត្ស ពន្ធកាត់ទុក សិទ្ធិ អំណាច កាតព្វកិច្ចរបស់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធទាក់ទិននឹងការធ្វើសវនកម្មពន្ធដារ" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធមធ្យម ក្រោមអធិបតីភាព លោក **ហ៊ឹម ឡូញ** ប្រធានសាខាពន្ធដារខេត្តព្រៃវែង។



## កម្មវិធីទូរស័ព្ទដៃពេញនិយមទាំង ១០ របស់អគ្គនាយកដ្ឋានពន្ធដារ

**កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)**
សម្រាប់បង់ពន្ធលើអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើផ្ទាំងផ្សព្វផ្សាយ

**កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)**
សម្រាប់ប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ របស់សហគ្រាសដែលជាអ្នកជាប់ពន្ធតូច

**កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track App)**
សម្រាប់តាមដានឯកសារដែលបានដាក់ស្នើមករដ្ឋបាលសារពើពន្ធ ពិនិត្យភាពត្រឹមត្រូវនៃឯកសារដែលមាន QR Code ចេញដោយអគ្គនាយកដ្ឋានពន្ធដារ

**កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (GDT Salary Tax Calculation App)**
សម្រាប់គណនាពន្ធលើប្រាក់បៀវត្សប្រចាំខែដែលត្រូវបង់

**កម្មវិធីគណនាពន្ធលើមធ្យោបាយដឹកជញ្ជូន (GDT Means of Transportation Tax Calculation App)**
សម្រាប់គណនាប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន ដែលត្រូវបង់ប្រាក់ពន្ធប្រចាំឆ្នាំ

**ព័ត៌មានពន្ធដារ (GDT News App)**
សម្រាប់ទទួលបានព័ត៌មាន វគ្គបណ្តុះបណ្តាល សិក្ខាសាលា ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត វីដេអូផ្សេងៗទៀតស្តីពីពន្ធដារ...

**កម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ (GDT Live Chat App)**
សម្រាប់សាកសួរព័ត៌មានផ្សេងៗស្តីពីពន្ធដារ (ផ្នែកពន្ធទូទៅ និង e-Tax Service)

**ប្រតិទិនពន្ធដារ (GDT Calendar App)**
អាចពិនិត្យកាលបរិច្ឆេទដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែ និងឆ្នាំ

**កម្មវិធីសទ្ទានុក្រមពន្ធដារ (Tax Glossary App)**
សម្រាប់ស្វែងរកពាក្យគន្លឹះផ្សេងៗស្តីពីពន្ធដារ

**កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)**
សម្រាប់បញ្ចូលវិក្កយបត្រ ដើម្បីចូលរួមផ្សងសំណាងឈ្នះរង្វាន់ជាច្រើនពីអគ្គនាយកដ្ឋានពន្ធដារ



# អគ្គនាយកដ្ឋានពន្ធដារ
# សូមស្វាគមន៍

**សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច លេខតំណភ្ជាប់របស់អង្គភាព**
**(ដោយមិនចាំបាច់ជ្រើសរើសភាសា)**
**ដើម្បីទាក់ទងទៅកាន់នាយកដ្ឋាន ឬសាខាពន្ធដារខេត្ត-ខណ្ឌ**

**ដោយឥតគិតថ្លៃ**

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
សារអេឡិចត្រូនិក: gdt@tax.gov.kh លេខទូរស័ព្ទ: (855) 23 266 668

## អាសយដ្ឋាននាយកដ្ឋាន សាលាជាតិពន្ធដារ ទីចាត់ការពន្ធដាររាជធានីភ្នំពេញ និងសាខាពន្ធដារខេត្ត-ខណ្ឌ

## នាយកដ្ឋានថ្នាក់កណ្ដាល សាលាជាតិពន្ធដារ និងទីចាត់ការពន្ធដាររាជធានីភ្នំពេញ

### នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង
(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ១០៩៩
សារអេឡិចត្រូនិក: admin.info@tax.gov.kh

### នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង
(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ១៨០០
សារអេឡិចត្រូនិក: dfp@tax.gov.kh

### នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង
(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ២១០០
សារអេឡិចត្រូនិក: dlpic@tax.gov.kh

### នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង
(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ២៧០១
សារអេឡិចត្រូនិក: dpt@tax.gov.kh

### នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង
(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៨០១៤
សារអេឡិចត្រូនិក: dit@tax.gov.kh

### នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង
(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៣២០១
សារអេឡិចត្រូនិក: dtci@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង
(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៣៦០១
សារអេឡិចត្រូនិក: dlt@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
អគារជាន់ទី១៩ ផ្លូវ១០២ មជ្ឈមណ្ឌលភ្នំពេញ ភូមិ១
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៤៩០០
សារអេឡិចត្រូនិក: dsmt@tax.gov.kh

### នាយកដ្ឋានសវនកម្មសហគ្រាស
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង
(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៥៦០០
សារអេឡិចត្រូនិក: dea@tax.gov.kh

### អង្គភាពសវនកម្មពន្ធដារពិសេស
អគារ Flatiron By Meridian ជាន់ទី១៨ ផ្លូវ១០២
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦០០១
សារអេឡិចត្រូនិក: USTA@tax.gov.kh

### សាលាជាតិពន្ធដារ
អគារលេខ៤១-៤៣ ផ្លូវ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក
រាជធានីភ្នំពេញ (ខាងកើតអគ្គនាយកដ្ឋានពន្ធដារ)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦៤០១
សារអេឡិចត្រូនិក: nts@tax.gov.kh

### ទីចាត់ការពន្ធដាររាជធានីភ្នំពេញ
អគារជាន់ទី១៨ ផ្លូវ១០២ មជ្ឈមណ្ឌលភ្នំពេញ ភូមិ១
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦៨០១
សារអេឡិចត្រូនិក: ppmd@tax.gov.kh

## សាខាពន្ធដារខណ្ឌ

### សាខាពន្ធដារ ខណ្ឌឫស្សីកែវ
អគារ១០២ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦
ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០០៧
សារអេឡិចត្រូនិក: russeykeo@tax.gov.kh

### សាខាពន្ធដារ ខណ្ឌដូនពេញ
ផ្ទះលេខ១៦៦ ផ្លូវលេខ១៣០ សង្កាត់ផ្សារកណ្ដាលទី២
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៣២
សារអេឡិចត្រូនិក: daunpenh@tax.gov.kh

### សាខាពន្ធដារ ខណ្ឌ៧មករា
ដីឡូលេខ០៥ ផ្លូវលេខ១៥០ សង្កាត់វាលវង់ ខណ្ឌ៧មករា
រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៥៧
សារអេឡិចត្រូនិក: 7makara@tax.gov.kh

### សាខាពន្ធដារ ខណ្ឌមានជ័យ
អគារលេខ៣៤C ផ្លូវ៣៦១ កែងផ្លូវ៦៤២ សង្កាត់ច្បារអំពៅ១
ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៨៣
សារអេឡិចត្រូនិក: meanchey@tax.gov.kh

### សាខាពន្ធដារ ខណ្ឌចំការមន
អគារលេខ២៨ ផ្លូវលេខ៤៨៨ សង្កាត់ផ្សារដើមថ្កូវ
ខណ្ឌចំការមន រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១០៩
សារអេឡិចត្រូនិក: chamkarmorn@tax.gov.kh

### សាខាពន្ធដារ ខណ្ឌទួលគោក
ផ្ទះលេខ២៤ ផ្លូវ២៨៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៣៥
សារអេឡិចត្រូនិក: tuolkork@tax.gov.kh

## សាខាពន្ធដារ ខណ្ឌដង្កោ

ផ្លូវ២១៧ ភូមិរលួស សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៦១
សារអេឡិចត្រូនិក: dangkor@tax.gov.kh

## សាខាពន្ធដារ ខណ្ឌសែនសុខ

អគារលេខ៩ ផ្លូវលេខ១០១៩(ហាណូយ) សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៨៨
សារអេឡិចត្រូនិក: sensok@tax.gov.kh

## សាខាពន្ធដារ ខណ្ឌពោធិ៍សែនជ័យ

ផ្ទះលេខ២៣៤B ផ្លូវលេខ ២០០៧ សង្កាត់កាកាប១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២១៣
សារអេឡិចត្រូនិក: porsenchey@tax.gov.kh

# សាខាពន្ធដារខេត្ត

## សាខាពន្ធដារ ខេត្តបន្ទាយមានជ័យ

ភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ(ខាងត្បូងស្ពានសៃសិនចំងាយ ៣០០ម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ៥ ឆ្ពោះទៅកាន់ស្រុកមង្គលបូរី)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧០៨
សារអេឡិចត្រូនិក: banteaymeanchey@tax.gov.kh

## សាខាពន្ធដារ ខេត្តបាត់ដំបង

ផ្ទះលេខ២ ផ្លូវជាតិលេខ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៩២
សារអេឡិចត្រូនិក: battambang@tax.gov.kh

## សាខាពន្ធដារ ខេត្តកំពង់ចាម

ផ្ទះលេខ៥ ភូមិទី១៥ ផ្លូវខេមរភូមិន្ទ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៦៥
សារអេឡិចត្រូនិក: kampongcham@tax.gov.kh

## សាខាពន្ធដារ ខេត្តកំពង់ឆ្នាំង

ភូមិឃ្លាំងប្រាក់ សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៧៣
សារអេឡិចត្រូនិក: kampongchhnang@tax.gov.kh

## សាខាពន្ធដារ ខេត្តកំពង់ធំ

ភូមិបល្ល័ង្គលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៦៩
សារអេឡិចត្រូនិក: kampongthom@tax.gov.kh

## សាខាពន្ធដារ ខេត្តកំពង់ស្ពឺ

ផ្លូវជាតិលេខ៤ ភូមិត្រពាំងលើក សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៩៩
សារអេឡិចត្រូនិក: kampongspeu@tax.gov.kh

## សាខាពន្ធដារ ខេត្តកំពត

ផ្លូវលេខ៧២៩ ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥២៦
សារអេឡិចត្រូនិក: kampot@tax.gov.kh

## សាខាពន្ធដារ ខេត្តកណ្តាល

អគារលេខ២៦ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៣៩
សារអេឡិចត្រូនិក: kandal@tax.gov.kh

## សាខាពន្ធដារ ខេត្តកោះកុង

អគារកែងផ្លូវលេខ៩០០ និងផ្លូវលេខ៩៩៥ ភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥៧៧
សារអេឡិចត្រូនិក: kohkong@tax.gov.kh

## សាខាពន្ធដារ ខេត្តក្រចេះ

ភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៣០
សារអេឡិចត្រូនិក: kratie@tax.gov.kh

## សាខាពន្ធដារ ខេត្តមណ្ឌលគិរី

ផ្លូវលេខ ៣៧៦៣ ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៨១
សារអេឡិចត្រូនិក: mondulkiri@tax.gov.kh

## សាខាពន្ធដារ ខេត្តព្រៃវែង

អាគារកែងផ្លូវលេខ៥ និងផ្លូវលេខ៣ ភូមិ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣១៨
សារអេឡិចត្រូនិក: preyveng@tax.gov.kh

## សាខាពន្ធដារ ខេត្តព្រះវិហារ

ភូមិអណ្តូងពោធិ៍ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦០៤
សារអេឡិចត្រូនិក: preahvihear@tax.gov.kh

## សាខាពន្ធដារ ខេត្តពោធិ៍សាត់

ផ្លូវជាតិលេខ៥ ភូមិមាន់ចៃ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៤៧
សារអេឡិចត្រូនិក: pursat@tax.gov.kh

## សាខាពន្ធដារ ខេត្តរតនគិរី

ផ្លូវលេខ ២០ ភូមិថ្មដា សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៥៥
សារអេឡិចត្រូនិក: ratanakiri@tax.gov.kh

## សាខាពន្ធដារ ខេត្តសៀមរាប

ផ្លូវជាតិលេខ 6 ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៤៣
សារអេឡិចត្រូនិក: siamreap@tax.gov.kh

## សាខាពន្ធដារ ខេត្តព្រះសីហនុ

វិថី ២៨មិថុនា ភូមិ០១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥៥២
សារអេឡិចត្រូនិក: preahsihanouk@tax.gov.kh

## សាខាពន្ធដារ ខេត្តស្ទឹងត្រែង

ផ្លូវភូមិស្ពានថ្ម សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៣៣
សារអេឡិចត្រូនិក: stoengtreng@tax.gov.kh

## សាខាពន្ធដារ ខេត្តស្វាយរៀង

ផ្លូវលេខ១១៤ ភូមិរពាងបន្លែ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤២១
សារអេឡិចត្រូនិក: svayrieng@tax.gov.kh

## សាខាពន្ធដារ ខេត្តតាកែវ

ភូមិ១ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៩៦
សារអេឡិចត្រូនិក: takeo@tax.gov.kh

## សាខាពន្ធដារ ខេត្តឧត្តរមានជ័យ

អគារខាងលិចសាលាខេត្ត ទល់មុខវិមានឯករាជ្យ ភូមិបុរីរដ្ឋបាល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៨១១
សារអេឡិចត្រូនិក: odormeanchey@tax.gov.kh

## សាខាពន្ធដារ ខេត្តកែប

ផ្លូវលេខ២៣៥០ ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៥៩
សារអេឡិចត្រូនិក: kep@tax.gov.kh

## សាខាពន្ធដារ ខេត្តប៉ៃលិន

ភូមិប៉ាហ៊ីត្បូង សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៨៥
សារអេឡិចត្រូនិក: pailin@tax.gov.kh

## សាខាពន្ធដារ ខេត្តត្បូងឃ្មុំ

ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ (ជាប់ខាងត្បូងសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំ)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៨៣៧
សារអេឡិចត្រូនិក: tboungkhmum@tax.gov.kh

## កម្មវិធីរៀនអំពីពន្ធដារតាមអនឡាញ (GDT E-Learning)

អគ្គនាយកដ្ឋានពន្ធដារ បានបង្កើតឱ្យមានកម្មវិធី "រៀនអំពីពន្ធដារតាមអនឡាញ (GDTE-Learning)" ដែលជាកម្មវិធីសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈវីដេអូបង្រៀនអំពីពន្ធអាករគ្រប់ប្រភេទ ដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ និងមានការចាក់ផ្សាយជារៀងរាល់សប្តាហ៍នៅថ្ងៃអង្គារ វេលាម៉ោង ១១:៣០នាទីព្រឹក។

សូមស្កេន ដើម្បីចូលទៅកាន់
(Youtube Channel)
អគ្គនាយកដ្ឋានពន្ធដារ




## កម្មវិធីពន្ធដារកម្ពុជា (GDT Cambodia Program)




កម្មវិធីពន្ធដារកម្ពុជា គឺជាកម្មវិធីដែលអគ្គនាយកដ្ឋានពន្ធដារបានរៀបចំឡើងដើម្បីចែករំលែកចំណេះដឹង ព័ត៌មាន ទាក់ទងនឹងពន្ធដារ ជាពិសេសផ្តល់ឱកាសឱ្យសាធារណជនចូលរួមមតិយោបល់ឬលើកឡើងនូវចម្ងល់នានាពាក់ព័ន្ធនឹងប្រធានបទនីមួយៗដែលធ្វើការផ្សាយផ្ទាល់តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ រៀងរាល់ថ្ងៃព្រហស្បតិ៍ វេលាម៉ោង ១១:០០ ដល់ម៉ោង ១២:០០ថ្ងៃត្រង់។

សូមស្កេន ដើម្បីចូលទៅកាន់
(Youtube Channel)
អគ្គនាយកដ្ឋានពន្ធដារ

## កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (Cambodia Salary Tax Calculation)

កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស ( Cambodia Salary Tax Calculation ) ជាកម្មវិធីទូរស័ព្ទដែលអ្នកជាប់ពន្ធ ពិសេសនិយោជិតអាចប្រើប្រាស់សម្រាប់គណនាពន្ធលើប្រាក់បៀវត្សដោយខ្លួនឯងបានយ៉ាងងាយស្រួលនិងឆាប់រហ័ស និងត្រឹមត្រូវដើម្បីធានានូវភាពត្រឹមត្រូវនៃការកាត់ពន្ធពីនិយោជក។

ក្នុងការគណនាពន្ធលើប្រាក់បៀវត្ស លោកអ្នកត្រូវបំពេញនូវព័ត៌មានចាំបាច់មួយចំនួន ដូចជា៖

- ចំនួនប្រាក់បៀវត្ស
- ចំនួនប្រាក់ឧបត្ថម្ភផ្សេងៗដែលជាកម្មវត្ថុនៃពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម
- ចំនួនសហព័ទ្ធ និងចំនួនកូនក្នុងបន្ទុក។

លោកអ្នកអាចធ្វើការទាញយក ( Download ) កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស ( Cambodia Salary Tax Calculation ) ដោយឥតគិតថ្លៃពី App Store សម្រាប់ប្រព័ន្ធ iOS និងទាញយកពី Play Store សម្រាប់ប្រព័ន្ធ Android៕




## សទ្ទានុក្រមពន្ធដារ ជាជំនួយស្មារតី និងជាមូលដ្ឋានគ្រឹះក្នុងការឈ្វេងយល់ពាក្យបច្ចេកទេស និងវាក្យសព្ទពាក់ព័ន្ធនឹងពន្ធដារ



# កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ ( GDT Taxpayer App)

សូមស្កេនដើម្បីទស្សនាវីដេអូណែនាំ
កម្មវិធីទូរស័ព្ទដៃ
សម្រាប់អ្នកជាប់ពន្ធ
GDT Taxpayer App




កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App) គឺជាកម្មវិធីទូរស័ព្ទដៃដែលផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ អាចបង់ពន្ធនៅគ្រប់ទីកន្លែងបានតាមទូរស័ព្ទលើប្រភេទពន្ធមួយចំនួនដូចជា ៖

- ពន្ធលើអចលនទ្រព្យ
- ពន្ធលើមធ្យោបាយដឹកជញ្ជូន និង
- ពន្ធលើផ្ទាំងផ្សព្វផ្សាយ។

សូមធ្វើការទាញយកកម្មវិធី GDT Taxpayer App ដើម្បីងាយស្រួលក្នុងការបង់ពន្ធ៕

# អ្នកជាប់ពន្ធតូចកាន់តែងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធ តាមរយៈកម្មវិធី ( GDT Tax Prefiling App)




ដើម្បីជួយសម្រួលដល់ការប្រកាសនិងបង់ប្រាក់ពន្ធរបស់អ្នកជាប់ពន្ធតូចអគ្គនាយកដ្ឋានពន្ធដារបានបង្កើតនិងដាក់ឱ្យប្រើប្រាស់កម្មវិធីទូរស័ព្ទដៃដែលមានឈ្មោះ កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច ( GDT Tax Prefiling App ) ដែលមានមុខងារកត់ត្រាទិន្នន័យទិញ-លក់ជួយគណនាប្រាក់ពន្ធដែលត្រូវបង់ក្នុងការប្រកាសពន្ធប្រចាំខែនិងប្រចាំឆ្នាំ ពិនិត្យមើលទិន្នន័យបំណុលពន្ធ និងបង់ប្រាក់ពន្ធ៕

សូមស្កេន ដើម្បីទាញយកកម្មវិធី
ប្រកាសពន្ធអាជីវកម្មសម្រាប់
អ្នកជាប់ពន្ធតូច
**(GDT Tax Prefiling App)**

Download on the App Store | GET IT ON Google Play

YouTube

សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពីការប្រើប្រាស់
**GDT Tax Prefiling App**

## មជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទរបស់អគ្គនាយកដ្ឋានពន្ធដារ (១២៧៧) មានចម្ងល់ពីពន្ធដារ មិនដឹងសួរនៅទីណាមែនទេ?

លោកអ្នកអាចទទួលសេវាពិគ្រោះយោបល់តាមទូរស័ព្ទដោយទាក់ទងមកលេខ ១២៧៧ ដោយឥតគិតថ្លៃ រៀងរាល់ថ្ងៃនិងម៉ោងធ្វើការ ដើម្បីសាកសួររាល់ចម្ងល់ទាំងឡាយស្តីពីពន្ធដារ ដូចជា៖

- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ
- សេវាកម្មអេឡិចត្រូនិក
- ការចុះបញ្ជីនិងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ
- ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ពន្ធប្រថាប់ត្រា
- ពន្ធលើមធ្យោបាយដឹកជញ្ជូន
- ការប្រកាសបង់ពន្ធទូទៅ និង
- ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងពន្ធដារ




## ឬលោកអ្នកអាច Chat សួរសំណួរពីពន្ធដារតាម កម្មវិធី GDT Live Chat ដោយគ្រាន់តែស្កេន QR Code ខាងក្រោម



# កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration)

**ដាក់លិខិតរដ្ឋបាលនិងឯកសារនានាមករដ្ឋបាលសារពើពន្ធបានពីគ្រប់ទីកន្លែង ដោយគ្រាន់តែប្រើប្រាស់កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration ) តាមជំហានងាយៗដូចខាងក្រោម៖**

**ជំហានទី ១**

ចូលទៅកាន់គេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ https://www.tax.gov.kh ជ្រើសរើសសេវាកម្មអេឡិចត្រូនិកពន្ធដារ និងទាញយក (**Download**) កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (**GDT e-Administration**) រួចដំឡើង (**Setup**) កម្មវិធីនេះនៅលើកុំព្យូទ័រជាការស្រេច។

**ជំហានទី ២**

ប្រើប្រាស់គណនីដែលមានស្រាប់ដូចធ្លាប់ចូលប្រើប្រាស់ប្រព័ន្ធ កម្មវិធីផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងករណីមិនទាន់មានគណនី សូមចុះឈ្មោះប្រើប្រាស់ដោយចុច "**បង្កើតគណនីថ្មី**"។

**ជំហានទី ៣**

ជ្រើសរើសប្រភេទអ្នកប្រើប្រាស់ជា អ្នកជាប់ពន្ធ ឬភ្នាក់ងារសេវាកម្មពន្ធដារ ឬអ្នកតំណាងសហគ្រាស រួចបញ្ចូលព័ត៌មាន និងឯកសារដែលកម្មវិធីតម្រូវ។

**ជំហានទី ៤**

ចុចម៉ឺនុយ "**បង្កើតលិខិតរដ្ឋបាលថ្មី**" បន្ទាប់មកបញ្ចូលព័ត៌មានអ្នកស្នើសុំ កម្មវត្ថុនៃលិខិត និងខ្លឹមសារសង្ខេប រួចជ្រើសរើសអង្គភាពដែលត្រូវទទួលលិខិត។

**ជំហានទី ៥**

ភ្ជាប់លិខិតរដ្ឋបាលនិងឯកសារយោងផ្សេងៗ (**Attachment**) ជាទម្រង់ **PDF** បន្ទាប់មកពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានដែលបានបញ្ចូលព្រមទាំងឯកសារភ្ជាប់ឡើងវិញ រួចចុចបញ្ជូនជាការស្រេច។



# ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ




ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ ត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងគោលបំណង ដើម្បីផ្តល់ភាពងាយស្រួល រហ័ស និងចំណេញពេលវេលាជូនអ្នកជាប់ពន្ធក្នុងការបង្កើតការស្នើសុំ និងបោះពុម្ពវិញ្ញាបនបត្រពន្ធដារ ដូចជា៖

- វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ
- វិញ្ញាបនបត្របញ្ជិកាគណនេយ្យត្រឹមត្រូវ
- វិញ្ញាបនបត្រអនុញ្ញាតអត្រាសូន្យនូវអាករលើតម្លៃបន្ថែម
- វិញ្ញាបនបត្រលើកលែងពន្ធលើប្រាក់ចំណូល។

សូមស្កេន QR Code ដើម្បីទស្សនា
វីដេអូណែនាំពីរបៀបប្រើប្រាស់ប្រព័ន្ធ

# ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក
## (E-Commerce Tax System)




ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ ស្របតាមយុគសម័យបរិវត្តកម្មឌីជីថល អគ្គនាយកដ្ឋានពន្ធដារ បានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce Tax System) សម្រាប់អ្នកជាប់ពន្ធប្រើប្រាស់លើមុខងារសំខាន់ៗចំនួន ៤ រួមមាន៖

- ស្នើសុំចុះបញ្ជីសហគ្រាស
- ស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មាន
- ពិនិត្យមើលប្រវត្តិនៃការបង់ពន្ធ និង
- ទាញយកលិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធផ្សេងៗ។

ដើម្បីឈ្វេងយល់កាន់តែច្បាស់ពីរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce Tax System) ដែលមានជាអាទិ៍របៀបចូលប្រើប្រាស់ប្រព័ន្ធ និងការពន្យល់ពីរបៀបប្រើប្រាស់មុខងារនីមួយៗ សូមទស្សនាវីដេអូណែនាំ សូមស្កេន QR Code ខាងលើ។

# ប្រភពព័ត៌មានអំពីពន្ធដារ




## គេហទំព័រហ្វេសប៊ុកផ្លូវការរបស់ អគ្គនាយកដ្ឋានពន្ធដារ

សូមស្វាគមន៍ការមកកាន់ប្រព័ន្ធផ្សព្វផ្សាយរបស់អគ្គនាយកដ្ឋានពន្ធដារ
សម្រាប់ការផ្សព្វផ្សាយ និងចែកចាយព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ ។

**សូមស្កេនដើម្បីទទួលបានព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ**



## ឆាណែលតេឡេក្រាម ព័ត៌មានពន្ធដារកម្ពុជា

សូមស្វាគមន៍ការមកកាន់ប្រព័ន្ធផ្សព្វផ្សាយរបស់អគ្គនាយកដ្ឋានពន្ធដារ
សម្រាប់ការផ្សព្វផ្សាយ និងចែកចាយព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ ។

**សូមស្កេនដើម្បីទទួលបានព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ**




## តើលោកអ្នកនៅតែមានចម្ងល់ អំពី ពន្ធដារ មែនទេ?

ជួយសម្រួលដល់អ្នកជាប់ពន្ធ និងសាធារណជនដែលមានចម្ងល់ពាក់ព័ន្ធនឹងពន្ធដារ
បានជជែកផ្ទាល់ជាមួយមន្ត្រីជំនាញពន្ធដារតាមអនឡាញពីគ្រប់ទីកន្លែងរៀងរាល់ម៉ោងធ្វើការ

Download on the App Store | GET IT ON Google Play

**សូមស្កេនដើម្បីទាញយកកម្មវិធី GDT LIVE CHAT**




www.tax.gov.kh/km/tax-bulletin

សូមស្កេន QR Code
ដើម្បីទទួលបានព្រឹត្តិបត្រពន្ធដារ
តាមរយៈទូរស័ព្ទដៃ




www.tax.gov.kh/km/tax-news-letter

សូមស្កេន QR Code
ដើម្បីទទួលបាន
ព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍
តាមរយៈទូរស័ព្ទដៃ




**សម្រាប់ព័ត៌មានបន្ថែមលោក-លោកស្រីអាចទំនាក់ទំនងតាមរយៈ**

Website Facebook Instagram Youtube


អាសយដ្ឋាន ៖ អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
មជ្ឈមណ្ឌលពិគ្រោះយោបល់ / **Call Center** ៖ ១២៧៧ (ដោយឥតគិតថ្លៃ) | គេហទំព័រ ៖ www.tax.gov.kh | សារអេឡិចត្រូនិក ៖ gdt@tax.gov.kh